ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 15-Dec-2015, 09:21
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣៤៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា រ៉ូប៊ីនី ក្រហ្វត៍ *(Ms. Robynne CROFT)*

លោក និកូឡូ ប៉ុងស៍ *(Mr. Niccolo PONGS)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de Wilde d'Estmael)*

លោក ចូសេហ្វ អេនឌ្រូ ប៊ូយលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល | បារាំង |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោក រ៉ិចឆ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ជឿង យ៉ាំង ច្រើត ឬ ជឿង យ៉ាំង ចែត (2-TCCP-241) | ខ្មែរ |
| លោក ព្រុំ សារុន (2-TCW-945) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ ជឿង យ៉ាំង ច្រើត ឬ ជឿង យ៉ាំង ចែត** (2-TCCP-241)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី .................................................. ទំព័រ ៣
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី.................................................. ទំព័រ ១៦
សួរដោយលោក គង់ សំអុន ផ្តើមពី .................................................. ទំព័រ ៣១

**ការសួរសំណួរទៅសាក្សី៖ លោក ព្រុំ សារុន** (2-TCW-945)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី .................................................. ទំព័រ ៤១
សួរដោយកញ្ញា សុង ឆវ័ន្ត ផ្តើមពី .................................................. ទំព័រ ៤៥
សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្តើមពី.................................................. ទំព័រ ៥៧
សួរដោយលោក ពេជ អង្គ ផ្តើមពី .................................................. ទំព័រ ៧៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត បញ្ចប់ និងផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-945។ ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្ដឹងដែលនឹងត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺលោក ជឿង យ៉ាំង ចែត លោកមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។

នៅថ្ងៃនេះផងដែរមានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-945។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ ឬជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឡើយ។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយកាលពីម្សិលមិញនេះ។ សូមអរគុណលោកប្រធាន។

[០៩:០៤:៣៨]

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ជា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់

ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំ-ការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា នៅថ្ងៃនេះថាមានអាការៈឈឺចង្កេះ វិលមុខធេងធោង ពេលអង្គុយយូរមិនអាចផ្ចង់អារម្មណ៍បានល្អ និងបានផ្តល់អនុសាសន៍សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោយសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាន និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើនៅមានសំណួរ។

[០៩:០៦:២៩]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សហព្រះរាជអាជ្ញា ហើយនិងភាគីទាំងអស់ លោកដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ពីម្សិលមិញ យើងបានបញ្ចប់ការពិភាក្សាអំពី តាពាង ហើយនិងមុខងាររបស់គាត់ ហើយខ្ញុំនឹងពិនិត្យមើលបញ្ហានេះសង្ខេបខ្លីម្ដងទៀត។ ប៉ុន្តែខ្ញុំចង់ត្រឡប់ទៅការពិភាក្សាមុនពីយើងពិភាក្សាជាមួយ តាពាង គឺនិយាយអំពីពេល អំពីហេតុការណ៍ដែលលោកបាននិយាយថា មានឧបទ្ទវហេតុ មានហេតុការណ៍កើតឡើងមួយដែលនៅពេលដែលលោកផ្ដល់សម្ភាសជាមួយមេធាវីរបស់លោក។ លោកបាននិយាយថា ការសម្លាប់សមាជិកក្រុមគ្រួសាររបស់លោក គឺនៅខែមីនា ឆ្នាំ១៩៧៥។ ហើយ៥ខែមុនហ្នឹង លោកក៏បាននិយាយទៅរកមនុស្សមួយចំនួន ប្រហែលជាអ្នកមកពីអង្គភាពគាំពារជនរងគ្រោះ។ ហើយក្នុងឯកសារនោះ D22/3175/1 មិនមានភាសាបារាំង ខ្មែរទេ អង់គ្លេស ERN 00561343។ នៅក្នុងឯកសារនោះ លោកបានរៀបរាប់ហេតុការណ៍ពីរអំពីការសម្លាប់។ ទី១ គឺការសម្លាប់ក្រុមគ្រួសាររបស់លោក។ ហើយមួយទៀត ៦ខែក្រោយមក ហើយនិងការកាប់សម្លាប់សមាជិកក្រុមគ្រួសាររបស់លោក។ នៅក្នុងរបាយការណ៍នោះ គឺថាគឺចាប់ផ្ដើមពីឆ្នាំមួយពាន់ប្រាំបួនរយ -- ដើមឆ្នាំ១៩៧៥។ ខ្ញុំចង់សួរលោកអំពីពេលវេលាជាទូទៅ។ លោកបានរៀបរាប់ប្រាប់តុលាការថា ហេតុការណ៍នោះកើតឡើងនៅក្នុងស្រុក១៨។ តើត្រឹមត្រូវដែរឬទេ ថានៅតំបន់ដែលហៅថា ស្រុក១៨នោះក៏បានរំដោះដោយខ្មែរ-ក្រហម នៅក្នុងឆ្នាំ១៩៧១? ហើយគឺថារយៈពេលមុនឆ្នាំ១៩៧៥ហ្នឹងយូរណាស់ គឺថាក្នុងឆ្នាំ១៩៧១ នោះគឺថាតំបន់នោះគ្រប់គ្រងដោយកម្មាភិបាលដែលឈ្មោះថា តាពាង ដែរឬទេ លោកដើមបណ្ដឹងរដ្ឋប្បវេណី?

[០៩:០៩:១៦]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហមេធាវីនាំមុខអន្តរជាតិ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយពាក់ព័ន្ធទៅនឹងប្រភេទនៃឯកសារដែលបានអានដោយមេធាវី។ ដូចខ្ញុំបាននិយាយជាច្រើនលើកច្រើនសាមកហើយថា របាយការណ៍ដែលធ្វើឡើងដោយអង្គភាពគាំពារជនរងគ្រោះ គឺជារបាយការណ៍ដែលពួកគាត់ធ្វើផ្ទាល់ ដោយមិនមានការ

ទាក់ទងរវាងអង្គភាពជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីទេ គឺវាគ្រាន់តែជាសេចក្តីសង្ខេបនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះតែប៉ុណ្ណោះ។ ដូច្នេះដើម្បីឲ្យបានច្បាស់ទាំងអស់គ្នា គឺថានៅពេលនោះ គឺអត់មានការទាក់ទងគ្នារវាងអង្គភាពជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះផ្ទាល់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំៗយកពាក្យសហមេធាវីនាំមុខមកប្រើ គឺថាអ្វីដែលខ្ញុំបានអាននោះ ខ្ញុំគឺមិនសួរផ្អែកទៅលើរបាយការណ៍នោះទេ។ ខ្ញុំសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ថាតើៗស្រុក១៨ត្រូវបានរំដោះដោយកងកម្លាំងរណសិរ្សរួបរួមជាតិហើយឬនៅក្នុងឆ្នាំ១៩៧១ គឺថា៤ឆ្នាំ មុនឆ្នាំ១៩៧៥។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើអ៊ីចឹងដែរឬទេលោកដើមបណ្តឹងរដ្ឋប្បវេណី?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាទ ខ្ញុំបាននិយាយថា ពេលហ្នឹងខ្ញុំនិយាយ៧៥ទេ ខ្ញុំដឹង៧៥ ខ្ញុំនិយាយរឿងហ្នឹង។ រឿងហ្នឹងខ្ញុំអត់ដឹង អត់បាននិយាយ។

[០៩:១១:១១]

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្តឹងរដ្ឋប្បវេណីអត់ទាន់ឆ្លើយតបទៅនឹងសំណួរទេ។ សំណួរមិនមែនសួរអ៊ីចឹងទេ។ លោកមេធាវី វ៉ិចទ័រ កូប៉េ តាំងសំណួរសាជាថ្មីម្តងទៀត ហើយដើមបណ្តឹងរដ្ឋប្បវេណីស្តាប់សំណួរឲ្យបានថា តើលោកដឹងឬក៏មិនដឹង។ បើដឹង គឺនឹងឆ្លើយបន្តទៅទៀតនូវសំណួរដែលពាក់ព័ន្ធនឹងបញ្ហានោះ។ លោកឆ្លើយ ស្តាប់សំណួរសិន ឲ្យច្បាស់សិន សឹមឆ្លើយតបឲ្យចំទៅនឹងសំណួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹង ម្សិលមិញលោកបាននិយាយអំពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងស្រុកកំពង់លែង។ ហើយលោកបាននិយាយថា នៅទីនោះគេហៅថាស្រុក១៨ ផងដែរ។ តើត្រឹមត្រូវដែរឬទេស្រុក១៨ ស្រុកកំពង់លែងនោះត្រូវបានរំដោះដោយខ្មែរក្រហមនៅឆ្នាំ១៩៧១?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ខ្ញុំនិយាយស្រុកកំពង់លែង ស្រុក១៦។ មេធាវីខ្ញុំសួរថាមានស្រុកណាមកហ្នឹងទៀតទេ ខ្ញុំថា ស្រុក១៨ ក៏មកហ្នឹងដែរ មកទាំងអស់ឡើងស្រុក១៦ហ្នឹងដែរ។

**ស៖** តាមពិត ខ្ញុំបានឮថាកំពង់លែង ក៏ជាស្រុក១៨ដែរពីម្សិលមិញនោះ។ អ៊ីចឹងលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្គាល់លេខាស្រុកកំពង់លែងដែរឬទេឆ្នាំ១៩៧២? តើអ្នកណាជាគណៈស្រុក ឬក៏គេហៅថាលេខាស្រុកនៅឆ្នាំ៧២នោះ?

[០៩:១៣:១៣]

**ឆ៖** កាលហ្នឹងខ្ញុំវាតូច ខ្ញុំអត់ចំណាំបាន ខ្ញុំអត់ស្គាល់។

**ស៖** តើលោកធ្លាប់ឈ្មោះបុរសម្នាក់ទៀតឈ្មោះ អ៊ុក ដែរឬទេ នៅឆ្នាំ១៩៧២ហ្នឹងគាត់ជាលេខាស្រុក១៨?

**ឆ៖** ខ្ញុំអត់ស្គាល់។

**ស៖** តើលោកធ្លាប់ឮឈ្មោះមនុស្សម្នាក់ឈ្មោះថា ប៊ុន ថន ហៅ ចាន់ ដែលគាត់បានធ្វើជាប្រហែលជាប្រធានស្រុក៣១ ដែលនៅក្នុងនោះគាត់ ស្រុក១៨នៅក្នុងតំបន់៣១ (សូមកែតម្រូវ) គឺតំបន់៣១?

**ឆ៖** ខ្ញុំនិយាយត្រង់ ខ្ញុំតូចណាស់ ខ្ញុំអត់ដឹងអ្នកធំៗទេ កាលហ្នឹងខ្ញុំអត់ដឹងរឿងធំទេ។ ប៉ុន្តែថា អ្នកធំៗ ដូចឪពុកខ្ញុំខ្លះក៏អត់ដឹងផង ព្រោះអត់កាលហ្នឹងអត់ ច្រឡូកច្រឡំ ថារកស៊ីតែម្តង អត់មានដឹងអ្នកធំៗទេ។

**ស៖** ខ្ញុំយល់លោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះខ្ញុំត្រឡប់ទៅ តាពាង ម្តងទៀត។ តើលោកដឹងទេ តាពាង ខ្លួនឯងហ្នឹងក៏គាត់ជាជនជាតិវៀតណាម ឬក៏ជាជនជាតិខ្មែរ?

**ឆ៖** ខ្ញុំជួបគាត់មែន។ ជួបគាត់ឆ្ងាយណាស់ ខ្ញុំមិនដឹងសញ្ជាតិចិន សញ្ជាតិខ្មែរ ឬយួនទេ ប៉ុន្តែថា ខ្ញុំឈរមុខគាត់ អត់ដឹង មើលតែមុខគាត់ គឺគ្របមុខចូលដីបាត់ហើយ អត់ហ៊ានមើលទៀតទេ អ្នកធំៗអត់ហ៊ានមើលមុខទេ។

[០៩:១៥:១៨]

**ស៖** តើលោកធ្លាប់ឮអ្នកណាម្នាក់និយាយថា គាត់ធ្លាប់ធ្វើការជាបុគ្គលិក ជាមន្ត្រីនៅក្នុងរដ្ឋាភិបាលវៀតណាមដែរឬទេ?

**ផ៖** អត់, អត់ទេ។

**ស៖** ឥឡូវយើងសន្មតថាអាចជាព័ត៌មានត្រឹមត្រូវ លោកដើមបណ្ដឹងរដ្ឋប្បវេណី។ ស្រុក១៨ក៏ត្រូវបានស្ថិតនៅក្នុងដៃខ្មែរក្រហមរួចហើយ។ តើអាចទៅរួចដែរឬទេ ថាហេតុការណ៍ដែលបានកើតឡើងហ្នឹងដែលលោកបានរៀបរាប់ហ្នឹង គឺកើតឡើងយូរណាស់ហើយមុនឆ្នាំ១៩៧៥?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំទាន់អាលឆ្លើយតប!

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ សូមអភ័យទោសលោកមេធាវី កូប៉េ ដែលខ្ញុំរំខានលោកក្នុងការសួរសំណួរ។ ក៏ប៉ុន្តែខ្ញុំចង់បានការបញ្ជាក់មួយ ថាតើលោកមានមូលដ្ឋានអ្វីក្នុងការសួរសំណួរដោយអះអាងថា តាពាង នេះគាត់ជាទាហានវៀតណាមនោះ?

[០៩:១៦:៥៧]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកចៅក្រម ឡាវែន៍ ដូចដែលលោកចៅក្រមកត់សម្គាល់គឺថា អ្នកស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតមិនដែលបានស៊ើបអង្កេតហេតុការណ៍ដែលកើតមានឡើងនៅខែមីនា ឆ្នាំ១៩៧៥ នោះទេ។ ដូច្នេះ យើងធ្វើការសិក្សាស្រាវជ្រាវដោយខ្លួនឯង ដើម្បីពិនិត្យផ្អែកលើឯកសារសំណុំរឿង។ ខ្ញុំមិនគិតថា ខ្ញុំគិតថា ស្រុក១៨នេះគឺបានស្ថិតនៅក្នុងដៃខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧១ ហើយ តាពាង គឺថាអាចជាសមាជិកនៅក្នុងរដ្ឋាភិបាលវៀតណាមកាន់កាប់កន្លែងហ្នឹង។ នេះគឺជាព័ត៌មានដែលយើងចេញពីសំណុំរឿង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានច្បាស់ទៅនឹងសំណួររបស់ខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ នៅក្នុងសំណុំរឿង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

នេះមិនមែនជាចម្លើយទេលោកមេធាវី។

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែលោកចៅក្រមគប្បីតែបានឃើញចម្លើយដូចដែលខ្ញុំឆ្លើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ ប្រសិនបើលោកចង់សួរសំណួរនោះ សូមលោកបង្ហាញមូលដ្ឋានឲ្យបានច្បាស់ដើម្បីឲ្យអង្គជំនុំជម្រះបានយល់ផង។

[០៩:១៨:២៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរសំណួរបន្ថែម ពីព្រោះថាខ្ញុំមិនទទួលព័ត៌មានត្រឹមត្រូវ។ តើលោកយោងទៅរកសំណុំរឿងជាក់លាក់ណាមួយ ឬក៏សំណុំរឿងរួមទូទៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រាកដនោះ ប្រាកដដូចម្តេច?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាសំណុំរឿងកំណត់នៅក្នុងឯកសារ E3។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកត្រូវតែបញ្ជាក់ឯកសារយោងជាឯកសារ E3 ដើម្បីឲ្យបានច្បាស់ពីមូលដ្ឋានដែលលោកសួរ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថា E3/1852។

[០៩:១៩:២៣]

**ប្រធានអង្គជំនុំ៖**

បញ្ជាក់លេខ ERN ភាសាទាំងបីភាសាដូចអ្វីដែលធ្លាប់បានធ្វើផង។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺមានតែជាភាសាអង់គ្លេសទេ លោកប្រធាន 00818933 នៅខាងចុង។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

លោកប្រធាន ខ្ញុំសូមកត់សម្គាល់ដើម្បីកំណត់ត្រាតុលាការ គឺថាមិនបានបញ្ជាក់ឯកសារត្រឹមត្រូវទេ ឯកសារមេធាវីដែលបានយោងទៅនោះ គឺចម្លើយសារភាពរបស់ ស-២១ ជាឯកសារ។ ហើយបើសិនជាលោកចង់សួរសំណួរនេះគឺថា ឯកសារដែលជាឯកសារស្ថិតនៅក្នុងការសង្ស័យអំពីព័ត៌មាននោះ ពីព្រោះថាព័ត៌មាននោះបានឡើងដោយអំពើទារុណកម្ម ហើយអាចនឹងជាការសន្និដ្ឋានរបស់មេធាវីការពារក្តីផ្អែកលើឯកសារនេះឯង ដើម្បីយកមកចោទសួរតាមការសង្កេតរបស់យើងខ្ញុំ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្លឹមសារសំខាន់របស់សំណួររបស់ខ្ញុំគឺថា ស្រុក១៨ តាមពិតមិន--

[០៩:២០:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២១:១៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ ការតាំងសំណួររបស់លោក ហើយដូចជាមិនបង្ហាញនូវស្ថានភាព និងមូលដ្ឋាននៃការតាំងសំណួរច្បាស់លាស់ទេ។ ហើយចុងក្រោយលោកក៏និយាយមិនបានច្បាស់លាស់នូវឯកសារ ដែលជាមូលដ្ឋាននៃការផ្តល់មូលដ្ឋានក្នុងការតាំងសំណួរនេះដែរ។ លោកមិនអាច មិនគប្បីធ្វើដូច្នេះទេ នៅក្នុងកិច្ចដំណើរការសវនាការនៅទីនេះ ក្នុងការស្វែងរកការពិតនោះ។ យើងសង្ឃឹមជឿជាក់ថាលោកមិនអាច មិនគប្បីធ្វើអ៊ីចឹងទៀតទេ។ លោកអាចតាំងសំណួរផ្សេងទៀត ដោយមិនឲ្យផ្អែកលើមូលដ្ឋាននៃការតាំងសំណួរ ដោយផ្អែកលើឯកសារដែលបានមកពីការធ្វើទារុណកម្មនៅ ស-២១ នោះទេ។ ខ្លឹមសារៗនៃឯកសារដែលបានមកពីការអំពើធ្វើទារុណកម្មទាំងឡាយដែលនៅក្នុង បានមកពីមន្ទីរសន្តិសុខ ស-២១ ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដថា តើដែលថាព័ត៌មាននេះ ចេញមកពីអំពើទារុណកម្មទេ ប៉ុន្តែមូលដ្ឋានសំខាន់ដែលខ្ញុំផ្អែកសំណួរនោះគឺៗសៀវភៅរបស់លោក ប៉ែន ឃៀរនិន ដែលថាភូមិភាគបស្ចិមត្រូវបានរំដោះរួចហើយឆ្នាំ១៩៧១។ ហើយបក្សកុម្មុយនីស្តកម្ពុជា--

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ តើលោក ប៉ែន យៀរនិន ហ្នឹងផ្អែកលើប្រភពដដែល គឺចម្លើយសារភាពនៅ ស-២១ ឬក៏យ៉ាងណា? បើសិនជាផ្អែកលើឯកសារផ្សេងនោះ សូមលោកប្រាប់ផង។

[០៩:២៣:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាមានប្រភពជាច្រើនទៀត លោកចៅក្រម ឡាវែន៍ គឺថាមាន ហើយផែនទីដោយអ្នកស៊ើបការណ៍សហរដ្ឋអាមេរិក មុនឆ្នាំ១៩៧៥ គឺថាលើកលែងតែទីក្រុងធំ ភ្នំពេញ គឺថាភាគច្រើននៃកម្ពុជាគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងទ័ពរណសិរ្សរួបរួមជាតិ។ ហើយ ប៉ែន យៀរនិន ក៏បានយោងលើផែនទីនោះដែរ គឺថាផ្អែកតំបន់បស្ចិម ភូមិភាគបស្ចិមនេះ ក៏ស្ថិតនៅក្នុងកណ្តាប់ដៃរបស់រណសិរ្សរួបរួមជាតិ រាប់ទាំងស្រុកកំពង់លែងផងដែរ គឺស្រុក១៨ គឺថាតំបន់៣១។ ហើយ ប៉ែន យៀរនិន គឺមិនបានផ្អែកលើឯកសារមន្ទីរ ស-២១ ជាចម្លើយសារភាពទេ។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

*(គ្មានការបកប្រែ)*--

**ប្រធានអង្គជំនុំ៖**

លោកសរុបការងារឲ្យបានច្បាស់លាស់ទៅ ចៀសវាងដើបម្តងហើយម្តងទៀតដូច្នេះ។ លោកនិយាយឲ្យបានច្បាស់លាស់ ហើយនិយាយឲ្យបានក្បោះក្បាយតែម្តងទេ យើងមិនអនុញ្ញាតឲ្យលោកនិយាយដដែល បញ្ហាដដែលនេះម្តងទៀតទេ។ និយាយឲ្យច្បាស់លាស់ ហើយតែម្តងហ្នឹងបានហើយ!

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំសូមឲ្យមានការបំភ្លឺខ្លី គឺថាទាក់ទងទៅនឹងមូលដ្ឋាននៃការតាំងសំណួរ ខ្ញុំជឿថា អ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយពីខាងដើម គឺថាព្រឹកមិញនេះ គឺថាកំពង់លែងនៅក្នុងស្រុក១៦ ដែលត្រឹមត្រូវ។ ដូច្នេះការពិភាក្សាហ្នឹង គឺថាអាចនឹងធ្វើនៅពេលក្រោយតាមរយៈការដាក់ឯកសារ។ ខ្ញុំគិតថា វិសាលភាពដែលសួរសំណួរនោះ គឺមិនត្រឹមត្រូវទេ ដែលមេធាវីគាត់ធ្វើបែបនោះៗ។

[០៩:២៥:០០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំឆ្លើយដោយសង្ខេប ហើយខ្ញុំអាចឆ្លើយបាន ប៉ុន្តែខ្ញុំអាចនឹងសួរបន្តទៅដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងឯកសារព័ត៌មានបន្ថែមរបស់គាត់ គាត់ក៏និយាយដែរថា ស្រុកកំពង់លែងនេះនៅក្នុង គេហៅថា ស្រុក១៨។ ហើយក៏គាត់បានបញ្ជាក់ប្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ដែរថា ស្រុកនេះ ជាស្រុក១៨។ ដូច្នេះវាច្បាស់បែបនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ប៉ុន្តែសំណួររបស់ខ្ញុំសួរទៅដើមបណ្តឹងរដ្ឋប្បវេណី តើត្រឹមត្រូវដែរឬទេលោក ដែលថា កន្លែងដែលលោកបានរស់នៅកាលនោះ គឺត្រូវបានរំដោះរួចហើយ ដោយកងកម្លាំងខ្មែរក្រហមនៅក្នុងឆ្នាំ ១៩៧១?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ៩៧១ហ្នឹង ខ្ញុំនៅឫស្សីដង្គួចទេ។ មិនទាន់មកកំពង់ឆ្នាំងយើងនេះទេ។ ខ្ញុំមកកំពង់ឆ្នាំងហ្នឹង មក៧៥ មុនចូលឆ្នាំខ្មែរមួយខែ។ ចូលឆ្នាំខ្មែររួច៧ថ្ងៃក្រោយ បានគេថា ជយោ! សម្តេចឪហ្នឹង! ផ្ទះនៅនៅដុតចោល។ អ្នកណាលើគោក នៅលើគោក អ្នកណានៅទឹក នៅទឹក។ បានគេជម្លៀសខ្ញុំទៅ ចូលជើងគ្រោះហ្នឹង។

[០៩:២៦:៣០]

**ស៖** នេះជាសំណួរចុងក្រោយនៅក្នុងប្រធានបទនេះ។ តើអាចទេ លោកយោងទៅរកឆ្នាំខ្មែរនៅក្នុងឆ្នាំ១៩៧១, ១៩៧២ ឬ១៩៧៣, ៧៤ តើអ៊ីចឹង ឬក៏យ៉ាងដូចម្តេច?

**ឆ៖** ហ្នឹងខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងឆ្នាំ៩៧១*(ស៊ីក)*អី ខ្ញុំឫស្សីដង្គួចដដែល១ហ្នឹង នៅភូមិខ្ញុំដដែល អត់ទាន់មានទៅណាទេ។

**ស៖** ខ្ញុំចូលទៅប្រធានបទមួយទៀត លោកដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលលោកបានឮពីខាងដើម គឺថាហេតុការណ៍ដែលលោកបាននិយាយនោះ គឺថាមិនទាន់បានស៊ើបអង្កេតដោយតុលាការនេះនៅឡើយទេ ពីមុន ហើយយើងមានតែសក្ខីកម្ម មានតែចម្លើយរបស់លោកដើម្បីជាបង្អែក។ តើមានអ្នកណាម្នាក់នៅក្នុងជុំវិញភូមិ ឬក៏ជុំវិញដែលកន្លែងលោករស់នៅ ឬក៏ថាឈ្មោះ តាលី ឬក៏អ្នកណាផ្សេងទៀត ដែលលោកបានប្រាប់រឿងរ៉ាវនេះ ដែលរៀបរាប់ ដែលគេអាចដឹងហេតុការណ៍ដូចដែលលោករៀបរាប់ពីម្សិលមិញ ដើម្បីជាព័ត៌មានស៊ីសង្វាក់ជាមួយនឹងលោកបានទេ? តើមានអ្នកណាដែលអាចប្រាប់ពីហេតុ

ការណ៍ដែលលោកបានដឹងហ្នឹងដែរឬទេ?

**ឆ៖** ឥឡូវ គាលី ខ្ញុំនិយាយត្រង់ មានតែ គាលី ស្គាល់ទេ ប៉ុន្តែងាប់បាត់អស់ហើយ គាត់ខូចបាត់ហើយ អត់មាននៅរស់ទៀតទេ។ នៅណាទៀត ខ្ញុំអត់ដឹង អស់ស្គាល់ទេ។ អត់ស្គាល់អ្នកណាមួយទេ។

[០៩:២៨:១៨]

**ស៖** នៅពេលដែលត្រឡប់មកប្រទេសកម្ពុជាឆ្នាំ១៩៨២ តើលោកនៅចាំទេថា អ្នកណាអាចដឹងរឿងរ៉ាវ ឬបានឃើញហេតុការណ៍ណាមួយដែលលោកបានរៀបរាប់ គឺថាទោះបីជាដឹងផ្នែកណាក៏ដោយ ដែលយើងអាចទៅសួរដើម្បីបញ្ជាក់ពីអ្វីដែលលោកដឹងហ្នឹងថាជាហេតុការណ៍ គេបានដឹងអ៊ីចឹងដូចលោកដែរ? តើមានអ្នកណា មនុស្សណាដែលលោកស្គាល់អាចប្រាប់អ៊ីចឹងបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយៗៗ! ចាំក្បាលមីក្រូហ្វូនប្រតិបត្តិសិនណ៎ះ!

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ព្រោះខ្ញុំអត់ទាន់ដឹងទេ ពីរឿងខ្ញុំនៅឡើងហ្នឹង ខ្ញុំក្រណាស់ ខ្ញុំទៅរកស៊ី ធ្វើកម្មករគេ *(ឮមិនច្បាស់)* គេតែម្តង។ ខ្ញុំអត់ដឹងគេពីណា។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** កាលពីម្សិលមិញ លោកដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរមួយចំនួនសួរមកលោក។ សួរអំពីការបាត់បង់ការចងចាំរបស់លោក នៅក្នុងឯកសារ E3/5261 លោកនិយាយថា៖ "ខ្ញុំភ្លេច ប្រហែលជា៣០ភាគរយនៃអ្វីៗដែលខ្ញុំបានដឹង ដោយសារតែខ្ញុំមានរបួស"។ នៅពេលដែលលោកភ្លេចអ្វីៗប្រហែលជា៣០ភាគរយនោះ គឺ៣០ភាគរយ។ ហេតុអ្វីបានជាលោកអះអាងថាភ្លេច៣០ភាគរយ? ម៉េចក៏មិន៥០ភាគរយ ឬក៏ម៉េចក៏មិនអត្រាខុសពីហ្នឹង ម៉េចក៏លោកប្រាកដថាភ្លេចតែ៣០ភាគរយ?

**ឆ៖** ពីព្រោះខ្ញុំហ្នឹង ខ្ញុំនិយាយត្រង់អ៊ីចឹងតែម្តង។ ខ្ញុំសរសៃប្រសាទខ្ញុំហើយ វាឡើងហើយ ខ្ញុំបានភ្លេចហើយ។ អាណាសំខាន់ ខ្ញុំចេះ ខ្ញុំដឹងខ្លួនខ្ញុំផ្ទាល់។ ខ្លួនខ្ញុំៗដឹងហ្នឹង ខ្ញុំដឹង និយាយតែប៉ុណ្ណឹង។

[០៩:៣០:៣៦]

**ស៖** នៅក្នុងវាក្យខណ្ឌដែលនោះ លោកនិយាយអំពីបញ្ហាសរសៃប្រសាទ ឬក៏បញ្ហាខួរក្បាលជាពិសេសនៅពេលដែលខ្ញុំធ្វើការច្រើន ដែលលោកនិយាយថាមានបញ្ហាខួរក្បាលហ្នឹង តើលោកមានបញ្ហាអីនៅពេលដែលធ្វើការហត់ខ្លាំងហ្នឹង គឺមានថាមានបញ្ហាខួរក្បាល បញ្ហាហ្នឹង អាការៈពិតប្រាកដ

នេះយ៉ាងម៉េច?

**ឆ៖** ការខ្ញុំធ្វើការខ្លាំង ធ្ងន់ធ្ងរ ហត់ វាឡើងតឹងសរសៃកខ្ញុំតែម្តង តឹងតែម្តង រឹងសរសៃក ហើយវិលមុខតែម្តង អត់ឃើញអី ងងឹតបណ្តោយ។

**សៈ** ខ្ញុំយល់ ប៉ុន្តែអ្វីដែលលោករៀបរាប់ គឺអ្វីដែលហៅថាជារបួសលើរាងកាយ ប៉ុន្តែលោកនិយាយអំពីការរងរបួស វិបត្តិខាងផ្លូវចិត្ត ខាងសតិ ខាងបញ្ហាខួរក្បាលហ្នឹង តើលោកអាចរៀបរាប់មើលបញ្ហាអី?

**ឆ៖** បញ្ហាហ្នឹងខ្ញុំត្រូវបីខ្នងពូថៅហ្នឹងហើយ។ រឿងបញ្ហាអីចឹងតែម្តង អត់មានបញ្ហាអីទេ។

**សៈ** ខ្ញុំសូមបន្តទៅរកហេតុការណ៍ដែលលោកបានរៀបរាប់។ នៅក្នុងរបាយការណ៍ នៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលខ្ញុំបានយោងទៅរកនោះ ដែលបុគ្គលិកមកពីអង្គភាពជនរងគ្រោះដែលលោកបានប្រាប់ពួកគាត់ គាត់បានកត់ត្រា។ នៅក្នុងរបាយការណ៍នេះ ក៏បានធ្វើបញ្ជាក់ពីភាពខុសគ្នារវាងហេតុការណ៍ពីរដែលលោកបានរៀបរាប់។ ទី១ គឺនៅដើមឆ្នាំ១៩៧៥ ដែលមានការអះអាងថា សមាជិកក្រុមគ្រួសាររបស់លោកត្រូវបានសម្លាប់។ ហើយមួយទៀត នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ ប្រហែលជាអ្នកភូមិ៤០នាក់ត្រូវបានគេសម្លាប់។ នៅក្នុងរបាយការណ៍នេះមានការរៀបរាប់ថាលោកត្រូវបានស្ថិតនៅក្នុងផ្នែកក្រុមមនុស្ស៤០នាក់នោះដែរ ដែលគេវ៉ៃលោកចំក បំបាក់ក។ គឺមិនមែនថាៗលោកនៅក្នុងហេតុការណ៍ដើមឆ្នាំ១៩៧៥ ដែលគេវ៉ៃសមាជិកក្រុមគ្រួសារលោកទេ។ តើពេលដែលគេវ៉ៃចំករបស់លោកបីពូថៅនោះ គឺលោកនៅជាមួយសមាជិកក្រុមគ្រួសាររបស់លោក ឬក៏ពេលដែលគេវ៉ៃលោកបីពូថៅហ្នឹងហើយ គឺលោកនៅជាមួយអ្នកប្រជាជន៤០នាក់ផ្សេងទៀត ក្រោយមកទេ?

[០៩:៣៣:៤៥]

**ឆ៖** មិនមែនដូចអីចឹងទេ។ ខ្ញុំនិយាយថា ការខ្ញុំងាប់ជាមួយម៉ែខ្ញុំហ្នឹងនៅរណ្តៅជាមួយគ្នា។ ដល់ខ្ញុំព្យាបាល ខ្ញុំទៅផ្ទះ តាលី ហ្នឹង ខ្ញុំព្យាបាលរួចហើយ ខ្ញុំបាន តាលី ហ្នឹងគាត់ឲ្យថា លាក់ខ្លួនត្រឹមបួនប្រាំថ្ងៃទៅ គាត់ធ្វើសំបុត្រស្នាមអី គាត់ទៅប្រទេសវៀតណាមហ្នឹង គាត់ឲ្យខ្ញុំដោយសារតាមទៅ។ បានខ្ញុំរត់ទៅចូលព្រៃហ្នឹង ខ្ញុំឃើញប្រហែល៤០នាក់ ប្រហែលខ្មែរខ្លះ យួនខ្លះ ទាញទៅមួយខ្សែ។ ហើយខ្ញុំរត់ចូលនៅព្រៃ ខ្ញុំចាំស្អី បើខ្ញុំមិនដឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង និយាយថាប៉ុណ្ណឹងទេ។

**សៈ** ដូច្នេះខ្ញុំសូមអានជូនលោកស្តាប់អំពីសេចក្តីដកស្រង់ចេញពីឯកសារមួយនេះ។ ទី១ គឺទាក់ទងទៅនឹងការអះអាងថា មានការសម្លាប់ក្រុមគ្រួសាររបស់លោកនៅដើមឆ្នាំ១៩៧៥ នៅខែកក្កដា

ឆ្នាំ១៩៧៥ ប្រហែលជាមានមនុស្ស៤០នាក់ រួមទាំងលោកផងត្រូវបានគេយកទៅតំបន់ភ្នំមួយដែលស្ថិតនៅក្រោមការគ្រប់គ្រង តាពាង។ នេះជាអង្គភាពជនរងគ្រោះកត់ត្រា។ តើត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ ពីព្រោះថា លោកមិនបានស្ថិតនៅក្នុងក្រុមមនុស្ស៤០នាក់ហ្នឹងទេ នៅពេលដែលគេវៃលោកបីពូថៅ ត្រង់កហ្នឹង។ តើអ៊ីចឹងត្រឹមត្រូវឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ ខ្ញុំលែងនិយាយថា ៤០នាក់ហ្នឹងៗ កាលហ្នឹងខ្ញុំមានរបួសហើយ មានរបួសលើកញ្ចឹងកខ្ញុំហើយ។ ខ្ញុំរត់ទៅព្រៃហើយ មួយខែពីរខែក្រោយហ្នឹង មួយខែក្រោយហ្នឹង។ រួចហើយ តាលី ហ្នឹងគាត់ឲ្យដំណឹង ខ្ញុំដឹង រត់ទៅព្រៃពួនទៅ មួយថ្ងៃពីរថ្ងៃទៅ ចាំមកវិញ។ បានខ្ញុំរត់ទៅព្រៃ ពួនហ្នឹង ខ្ញុំឃើញគេទាញ៤០នាក់ទៅទៀត ប្រហែល៤០នាក់។ ខ្ញុំនៅព្រៃ ខ្ញុំមើលមក បានខ្ញុំរត់ចូលព្រៃជ្រៅតែម្តង។ ខ្ញុំនិយាយតែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

[០៩:៣៥:៥៥]

**ស៖** បាទ ច្បាស់ហើយលោកដើមបណ្តឹងរដ្ឋប្បវេណី។ ម្សិលមិញលោកក៏បាននិយាយអំពី ជនជាតិវៀតណាមគឺ ២.០០០គ្រួសារ ដែលត្រូវបានគេផ្លាស់ប្តូរទីលំនៅ ទីកន្លែង។ តើលោកបានដឹងថា មានរឿងអីកើតឡើងដែលថា វៀតណាម ២.០០០ គ្រួសារហ្នឹង ក្រោយមកគេយកពួកអ្នកហ្នឹងទៅណា? ហើយពួកគាត់ហ្នឹងធ្វើអីនៅកន្លែងណាទេ លោកបានដឹងទេ?

**ឆ៖** ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែក្រុម អាហ្នឹងចែកជា -- ឡើងហ្នឹងចែកជាក្រុមអស់ហើយ ក្រុមទៅដូចថាទៅ ខាងច្រណូក ក្រុមខ្លះទៅដារ ក្រុមណាទៅភ្នំកង្កែបអ៊ីចឹងទៅ។ យើងដឹងអី ខ្ញុំនៅភ្នំកង្កែប ខ្ញុំដឹងភ្នំកង្កែប។ ហើយក្រុមណានៅនឹងទឹក គេរកត្រី អីជូនឲ្យគាត់ទៅ។ យើងមិនបានប៉ានទៅណាឆ្ងាយកាលហ្នឹង សម័យហ្នឹង អត់អ្នកណាប៉ានទៅឆ្ងាយ។ ហើយខ្ញុំដឹងណា។

**ស៖** ប្រហែលជាខ្ញុំមិនបានបញ្ជាក់ច្បាស់ទេ ប៉ុន្តែ លោកនិយាយក្នុងព័ត៌មានបន្ថែមរបស់លោក គឺមេធាវីរបស់លោកបានសម្អាស គឺថាមានប្រហែលជា វៀតណាមប្រហែល២.០០០គ្រួសារត្រូវបានគេជម្លៀសទៅលើភ្នំ ចេញពីភូមិដារ។ អ៊ីចឹងគឺថា មានប្រជាជនវៀតណាមប្រហែល២.០០០គ្រួសារដែលជម្លៀសទៅលើភ្នំហ្នឹង។ តើមានអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះ? តើលោកបានដឹងទេ?

**ឆ៖** ខ្ញុំអត់ដឹង។

**ស៖** ឥឡូវនេះ ខ្ញុំនឹងបន្តចូលទៅពេលដែលលោកឡើងជិះសាឡង់ទៅបន្តទៅមុខទៀត ហើយនិងពីរឿងដែលលោកនិយាយថា ប្រជាជនវៀតណាមត្រូវបានគេយកប្តូរ ទៅដូរនឹងអំបិល និងអង្ករ។

សូមលោកពន្យល់ម្តងទៀត ហេតុអ្វីក៏លោកគិតថា រូបលោក ហើយនិងអ្នកផ្សេងទៀតគេយកលោកទៅដូរនឹងអំបិល និងអង្ករ? តើមូលហេតុអីដែលនាំឲ្យលោកអាចនិយាយបែបនេះបាន?

[០៩:៣៨:៤៣]

**ធ៖** ហេតុតែខ្ញុំទៅចូលសាឡង់ហើយ ដូចថា អង្គការខាងសាឡង់ហ្នឹងគេនិយាយអ៊ីចឹង គេនិយាយផ្ទាល់ភ្នែក ផ្ទាល់មុខ ផ្ទាល់ខ្ញុំតែម្តង។ គេថា "រូបអ្នែង! រស់សព្វថ្ងៃហ្នឹងបានអង្ករ អំបិលដូរអ្នែងទេ"។ អាហ្នឹងឮតាមគេនិយាយអ៊ីចឹង ខ្ញុំឮនិយាយអ៊ីចឹង អង្គការខាងសាឡង់។

**ស៖** អ៊ីចឹងខ្ញុំចង់សួរថា តើអ្នកណាដែលនិយាយឲ្យលោកឮ ពាក្យដែលលោកថា អម្បាញ់មិញហ្នឹង?

**ធ៖** ខាងវៀតណាមគេ សាឡង់ខាងវៀតណាម។

**ស៖** ដូច្នេះគឺអង្គការខាងវៀតណាម ឬក៏ជនជាតិវៀតណាមទេ ដែលនិយាយថា រូបលោក ហើយនិងវៀតណាមផ្សេងទៀត គេយកទៅដូរអង្ករ ហើយនិងដូរអំបិល។ គឺមិនមែនភាគីខាងខ្មែរ មិនមែនខាងខ្មែរទេ អ្នកនិយាយប្រាប់លោក គឺខាងវៀតណាមទេ។ តើអ៊ីចឹងឬទេ?

**ធ៖** ត្រូវ អ៊ីចឹងហើយ។

**ស៖** ខ្ញុំគិតថា លោកមិនដឹងថាតើជនជាតិវៀតណាមនេះ មិនដឹងថាគាត់នេះ បានដឹងមកពីណានោះទេ។ ត្រឹមត្រូវដែរឬទេ?

**ធ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** សូមបញ្ជាក់ឲ្យច្បាស់ គឺថាលោកមិនត្រូវបានគេយកទៅដោះដូរ ឬក៏ថាគ្មានអ្នកណាម្នាក់ ឬកម្មាភិបាលខ្មែរណាម្នាក់ប្រាប់ថា លោកនេះត្រូវគេយកទៅដោះដូរទៅនឹងរបស់អ្វីនោះមួយទេ លោកមិនដែលបានគេប្រាប់ថាអ៊ីចឹងទេ មែនទេ?

**ធ៖** បាទ។

**ស៖** ឥឡូវនេះ ខ្ញុំរៀបសំណួរខ្ញុំជាចុងក្រោយ។ តើត្រឹមត្រូវដែរឬទេ ដែលថាលោកនេះមិនដឹងថាមានមូលហេតុអ្វីទេ មិនដឹងថាឪពុកម្តាយរបស់លោកនេះត្រូវបានគេចោទប្រកាន់អំពីអ្វីទេ ដែលត្រូវតាពាង យកទៅសម្លាប់នោះ អ៊ីចឹងមែនទេ?

**ធ៖** រឿងហ្នឹងអត់ដឹងទេ អត់ដឹងមែន។ ដឹងយកទៅសម្លាប់ៗ អត់ដឹងរឿងប្រកាន់ប្រកុយអីទេ។

[០៩:៤១:៤០]

**ស៖** ដូច្នេះ តើលោកយល់ស្របជាមួយខ្ញុំទេ ថាមិនមានភ័ស្តុតាងអ្វីទាល់តែសោះ ដែលបញ្ជាក់ថាការដែលគេយកឪពុកម្តាយលោកទៅសម្លាប់ ដោយសារតែឪពុកម្តាយលោកជាជនជាតិវៀតណាមនោះទេ?

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញឃើញនាំមុខដូចច្រើន បីបួនសំណួរហើយៗនៅបន្តទៀត។ យើងឃើញថាមេធាវីមានកម្រិតបច្ចេកទេសខ្ពស់ណាស់ ប៉ុន្តែការតាំងសំណួរចុងក្រោយនេះ គឺប្រភេទសំណួរនាំមុខដែលមិនគួរឲ្យជឿថាមេធាវីនឹងប្រើប្រាស់បែបនេះទេ។ អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងទម្រង់នៃការតាំងសំណួរនេះ។ ពិតណាស់ការដែលសួរត្រឹមត្រូវ គឺសួរថាតើគាត់មានការដឹងថាមូលហេតុអ្វីបានជាឪពុកម្តាយគាត់ត្រូវបានគេយកទៅសម្លាប់ចោលជាការគ្រប់គ្រាន់--

[០៩:៤២:៣៦]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញារងអន្តរជាតិ ដូចជាយើងបានសូមដាស់តឿនលោក លោកងើបឈរ! យើងដាស់តឿនលោកសាជាថ្មីម្តងទៀត ថាលោកមិនគប្បីប្រើវេទិកានេះបង្រៀនភាគីម្ខាងទៀតឲ្យរៀនតាំងសំណួរទេ។ លោកអាចជំទាស់បាន សំអាងហេតុនៃមូលហេតុជំទាស់បាន ប៉ុន្តែលោកមិនគប្បីប្រើវេទិកាបង្រៀនភាគីម្ខាងទៀតឲ្យសួរ ណែនាំឲ្យសួរតាំងសំណួររបៀបណានោះទេ។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើត្រឹមត្រូវទេដែលថាខ្លួនលោកផ្ទាល់នេះមិនមានព័ត៌មានអ្វីទាល់តែសោះពាក់ព័ន្ធទៅនឹងមូលហេតុនៃការសម្លាប់ឪពុកម្តាយរបស់លោកនេះ តើអ៊ីចឹង ឬក៏មិនមែនទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ! ប្រភេទសំណួរនាំមុខៗ បីបួនហើយណា។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

[០៩:៤៤:១៦]

**ប្រធានអង្គជំនុំ៖**

បាទតទៅនេះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរលោក ជឿង យ៉ាំង ចែត។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនក្នុងឋានៈខ្ញុំជាមេធាវី។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** កាលពីសវនាការម្សិលមិញនៅម៉ោង១១:០៩នាទី លោកបាននិយាយអំពីការចាកចេញរបស់គ្រួសារជាច្រើនពីភូមិកណ្តាលទៅកាន់ភូមិដារ ដោយនិយាយថា ពេលនោះគឺមានមនុស្សប្រហែល ១.០០០នាក់។ លោកក៏បាននិយាយថាផងដែរ ក្នុងចំណោមគ្រួសារទាំងអស់ហ្នឹង មានអ្នកខ្លះជាជនជាតិវៀតណាម និងអ្នកខ្លះជាជនជាតិខ្មែរ។ ដូច្នេះខ្ញុំចង់ដឹងថា លោកដឹងថាមានគ្រួសារទាំងអស់១.០០០គ្រួសារហ្នឹង លោកដឹងបានដោយរបៀបណា?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាទ ខ្ញុំប្រហែលៗ។ ខ្ញុំមិនថាទៅរាប់គ្រួសារទេ ប្រហែលៗ ១.០០០គ្រួសារ។

**ស៖** លោកសន្មតហ្នឹង សន្មតដោយរបៀបណា? លោកមានមូលដ្ឋានអ្វីបានជាហ៊ានសន្មតថាមាន១.០០០គ្រួសារហ្នឹង?

[០៩:៤៦:០២]

**ឆ៖** សន្មតម៉េច ឡើងតាមក្រុមហ្នឹង ប្រហែលមួយក្រុមអីចឹង ៥០គ្រួសារ ៤០គ្រួសារ វាច្រើនក្រុមហើយ បានខ្ញុំប្រហែល១.០០០គ្រួសារ ខ្ញុំប្រហែល។ ហើយខ្ញុំឃើញផ្ទាល់ភ្នែកខ្ញុំ តែប៉ុណ្ណឹង។

**ស៖** ក្រុមគ្រួសារទាំងអស់ហ្នឹងស្ថិតនៅកន្លែងណាដែរ ពេលដែលលោកថាប្រហែល១.០០០គ្រួសារហ្នឹង?

**ឆ៖** មកពីទៅ ចូលជើងគ្រោះ ជាប់ទាំងអស់គ្នា។ បានគេស៊ីញេដូចខ្ញុំប្រាប់អ៊ីចឹងដែរ គេស៊ីញេឈ្មោះហ្នឹង អ្នកណាទៅឡើងលើ ឡើងលើ អ្នកណានៅនឹងទឹក ធ្វើត្រីឲ្យគេ ធ្វើ។ អ៊ីចឹងដើម្បីឡើងលើហ្នឹង ក្រុមណាតាមក្រុមហ្នឹង។

**ស៖** ខ្ញុំយល់ហើយថា គេបំបែកក្រុមគ្រួសារទាំងអស់ហ្នឹងឲ្យទៅធ្វើអ្វីផ្សេងៗ ក៏ប៉ុន្តែខ្ញុំចង់ដឹងថា ពេលដែលលោកនិយាយថា ប្រហែល១.០០០គ្រួសារហ្នឹង លោកឃើញគ្រួសារទាំងអស់ហ្នឹងនៅកន្លែងណា?

**ឆ៖** ការជុំគ្នាហ្នឹង ចូលពីកំពង់ឆ្នាំងជុំគ្នា នៅជើងគ្រោះហ្នឹង ជើងគ្រោះហ្នឹងគេហៅមាត់ទឹកហើយ នៅមាត់ទឹកជើងគ្រោះ នៅមាត់ទឹកហើយ។ បានឡើងទៅលើភ្នំហ្នឹង គេហៅតាមចម្រៀងគេដូចថា ភ្នំកង្កែប ភ្នំដារ ភ្នំដូចថា ចណ្ដូកអ៊ីចឹង។ តាមឈ្មោះគេអ៊ីចឹង។

[០៩:៤៧:៤១]

**ស៖** តាមរយៈចម្លើយដែលលោកបានឆ្លើយជូនព្រះរាជអាជ្ញា និងមេធាវី កូប៉េ ខ្ញុំថា តាពាង -- ប្រសិនបើខ្ញុំច្រឡំ សូមលោកកែខ្ញុំ -- តើ តាពាង ហ្នឹងជាអ្នកជម្លៀសប្រជាជនទាំងអស់ហ្នឹង។ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំនិយាយត្រង់អ៊ីចឹង ដឹង តាពាង អង្គាល់ហ្នឹងជូនខ្ញុំឡើងហ្នឹង គាត់ថា មួយក្រុមខ្ញុំអ៊ីចឹងៗ គាត់ឲ្យខ្ញុំធ្វើរោងនៅហ្នឹង ដឹងតែម្ដងទេ។ ខ្ញុំអត់ដឹងរឿង តាពាង ទៅសម្លាប់គេហើយទៅណា ខ្ញុំអត់ដឹង។

**ស៖** ប្រហែលជាខ្ញុំសួរមិនច្បាស់។ ខ្ញុំមិនបាននិយាយថា តាពាង សម្លាប់មនុស្សទេ ខ្ញុំគ្រាន់តែសួរគាត់ -- ខ្ញុំសួរលោកថា គាត់ហ្នឹងជាអ្នកបញ្ជាឲ្យជម្លៀសប្រជាជនពីកណ្ដាលទៅភូមិដារហ្នឹង មែនទេ?

**ឆ៖** មែនហើយ គាត់ហ្នឹងហើយ។

**ស៖** អម្បាញ់មិញនេះ ខ្ញុំអត់បានទទួលការបកប្រែនូវចម្លើយរបស់លោកទេ ប្រហែលជាមានបញ្ហា។ អ៊ីចឹងលោកឆ្លើយថា តាពាង ហ្នឹងជាអ្នកបញ្ជាឲ្យជម្លៀស។ ដូច្នេះខ្ញុំសួរបន្តទៅទៀតថា ហេតុអ្វីបានជាលោកដឹងថា តាពាង ហ្នឹងហើយជាអ្នកបញ្ជាឲ្យជម្លៀស?

**ឆ៖** អង្គាល់ហ្នឹងម៉ែឪខ្ញុំនិយាយ។ អង្គាល់ហ្នឹងម៉ែឪខ្ញុំនៅរស់ ជម្លៀសឡើងហ្នឹង ម៉ែឪខ្ញុំថា តាពាង ជម្លៀសយើងទៅហើយ ក្រុមយើងទៅហើយ។ ខ្ញុំដឹងអ៊ីចឹង ម៉ែឪ ប្រាប់ឪខ្ញុំ។

[០៩:៤៩:៣០]

**ស៖** លោកដឹងថាមានការប្រកាសរួមអ្វីមួយនៅក្នុងភូមិកំណើតរបស់លោក ដើម្បីប្រាប់អំពីការជម្លៀសហ្នឹងទេ? ឬក៏មានការរៀបចំផ្សេងយ៉ាងម៉េចទៀត ដើម្បីឲ្យប្រជាជនដឹងថាខ្លួនហ្នឹងត្រូវគេជម្លៀសនោះ?

**ឆ៖** កាលហ្នឹងដឹងអីទេ អត់ៗមានប្រកាស ដូចសម័យឥឡូវប្រកាសណា។ ដូចខ្ញុំជម្រាបអ៊ីចឹងមកទាំងម៉ោងប្រាំមួយយប់តែម្ដង ជយោសម្ដេចឪ! ផ្ទះអ្នកណានៅ ដុតចោល។ អ្នកលើគោកតាមលើគោក អ្នកនឹងទឹកតាមនៅទឹក។ អ៊ីចឹងលើគោកគេដេញទៅណា យើងមិនដឹង នៅនឹងទឹក គេដេញតាមទន្លេ នៅនឹងគេដុតផ្ទះចោល។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ អត់មាននរណាប្រកាសអីទៀត។

**ស៖** ដូច្នេះគឺគេគ្រាន់តែមកដល់ហើយ គេប្រាប់ថាត្រូវជម្លៀសទៅកន្លែងនោះអ៊ីចឹងតែម្ដងមែនទេ?

**ឆ៖** បាទ ត្រូវអ៊ីចឹងហើយ។ ជម្លៀសហ្នឹងគេស្រែកតែម្ដង គេស្រែកថា "លើគោកនៅលើគោក នៅនឹងទឹកតាមទឹក"។

**ស៖** អ្នកណាដែលជាអ្នកមកប្រាប់ថា ឲ្យជម្លៀសទៅអ្នកនៅលើគោកនៅលើគោក អ្នកនៅលើទឹកទៅលើទឹកហ្នឹង?

**ឆ៖** អង្គាល់ហ្នឹងគឺថា ខ្មែរក្រហម អត់មានពីណាទៀត។ ខ្មែរក្រហមបណ្ដោយ ពាក់អាវខ្មៅខោខ្មៅ ក្រមាចងក។

[០៩:៥១:១៩]

**ស៖** នៅក្នុងព័ត៌មានបន្ថែមរបស់លោក ដែលធ្វើឡើងដោយមេធាវីរបស់លោក គឺឯកសារ E3/5631, ERN ជាភាសាបារាំងគឺ 00898372, ERN ជាភាសាខ្មែរគឺ 00897513, ជាភាសាអង់គ្លេស 00678292 នៅកថាខណ្ឌទី២។ ខ្ញុំសូមដកស្រង់៖ "មានគ្រួសារវៀតណាមប្រហែល២.០០០គ្រួសារដែលត្រូវបានគេផ្លាស់ទីមកឲ្យនៅលើភ្នំក្នុងភូមិដារ។ គ្រួសារខ្មែរចំនួន ២០០គ្រួសារក៏ត្រូវបានគេជម្លៀសមកផងដែរ។ គេបញ្ជូនក្រុមគ្រួសារទាំងនេះមករស់នៅលើភ្នំគឺដើម្បីមកធ្វើការ។ នៅសល់ប្រហែល១.០០០គ្រួសាររស់នៅក្នុងភូមិបណ្ដែតទឹក ដើម្បីទៅនេសាទឲ្យពួកខ្មែរក្រហម។" សូមបញ្ចប់ការដកស្រង់។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសួរលោកចង់ដឹងថា អម្បាញ់មិញនេះគឺលោកឆ្លើយថាប្រហែលជាមាន១.០០០គ្រួសារ ក៏ប៉ុន្តែនៅក្នុងឯកសារដែលបានមកពីការសម្ភាសរបស់លោកជាមួយនឹងមេធាវីរបស់លោកហ្នឹង លោកថាមានគ្រួសារវៀតណាមនោះប្រហែល២.០០០គ្រួសារ។ ដូច្នេះ

លោកអាចបញ្ជាក់ម្តងទៀតបានទេ ថាតួលេខមួយណាដែលត្រឹមត្រូវនោះ ១.០០០ ឬក៏ ២.០០០គ្រួសារ?

**ឆ៖** ក្នុងពីរលេខវាត្រឹមត្រូវទាំងអស់ហើយ អាពីរលេខហ្នឹង។ ពីព្រោះ២.០០០គ្រួសារហ្នឹង គេមិនទាន់ជម្លៀសឡើងលើគោកទេជាមួយប្រជាជនខ្មែរហ្នឹង គេមិនទាន់ជម្លៀសឡើងគោកទេ។ បើនៅនឹងទឹកប្រហែល ១.០០០ហ្នឹង ត្រូវហើយ។ ១.០០០ហ្នឹងឡើងលើគោកហើយ ១.០០០គ្រួសារហ្នឹងឡើងលើគោកហើយ ពីរហ្នឹងវាត្រឹមត្រូវ។ ហើយការមេធាវីខ្ញុំសួរខ្ញុំហ្នឹង វាដើម្បីខ្ញុំថានៅជុំហ្នឹង២.០០០គ្រួសារ ប្រហែល ២.០០០គ្រួសារ បើជម្លៀសឡើងលើគោកហ្នឹងប្រហែល ១.០០០គ្រួសារ។

**ស៖** មុនពេលជម្លៀសហ្នឹងមានក្រុមគ្រួសារសរុបទាំងអស់ហ្នឹងគឺ ២.០០០គ្រួសារទាំងខ្មែរទាំងវៀតណាមមែនទេ?

**ឆ៖** បាទ មែនហើយ។

[០៩:៥៣:៥០]

**ស៖** ដូច្នេះតួលេខ ២.០០០គ្រួសារវៀតណាមហ្នឹង គឺថាមិនត្រឹមត្រូវទេនៅក្នុងព័ត៌មានបន្ថែមរបស់លោកនេះអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនទេ។ ខ្ញុំនិយាយប៉ុណ្ណឹង ខ្ញុំដឹងប៉ុនណា ខ្ញុំនិយាយប៉ុណ្ណឹងទេ ត្រឹមប៉ុណ្ណឹង។

**ស៖** ខ្ញុំពិបាកយល់ តែខ្ញុំទទួលយកចម្លើយនេះទៅចុះ។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទផ្សេងទៀត។ លោកបានឆ្លើយថា ពេលដែលគេជម្លៀសហ្នឹងគឺថា ផ្ទះមួយចំនួនហ្នឹងត្រូវបានគេដុតចោល។ ដូច្នេះពេលគេដុតផ្ទះហ្នឹង គឺពេលដែលលោកចាកចេញពីភូមិលោកហ្នឹងមែនទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ចៅក្រម ហ្វេនស៍ លោកថាសៀវភៅគ្រួសារហ្នឹងគឺលោករក្សាទុកនៅផ្ទះលោក ហើយពេលដែលគេដុតផ្ទះហ្នឹង ក៏សៀវភៅគ្រួសារហ្នឹងក៏គេដុតចោលអស់ដែរ។ អ៊ីចឹងមែនទេ?

**ឆ៖** មែនហើយ។ របស់របរនៅនឹងផ្ទះហ្នឹងដុតចោលអស់ហើយ នៅអីទៀត។

**ស៖** ខ្ញុំយល់ផងដែរថា គេគឺអាជ្ញាធរនៅសម័យនោះពិនិត្យមើលសៀវភៅគ្រួសារដែលហៅថា "ឡាំងតាយ" ហ្នឹង។ លោកអាចបញ្ជាក់បានទេ នៅពេលណាដែលគេមកពិនិត្យមើលសៀវភៅគ្រួសារហ្នឹង?

[០៩:៥៥:៥៩]

**ឆ៖** អង្កាល់ហ្នឹងខ្ញុំអត់ចំណាំទេ អត់ចំណាំបាន ខ្ញុំអត់ដឹង។

**ស៖** ដូច្នេះ ពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញាថា គេពិនិត្យមើលឡាំងតាយរបស់លោកហ្នឹង លោកនិយាយសំដៅទៅពេលណាដែរ?

**ឆ៖** ពេលនៅកំពង់ឆ្នាំង ភូមិកណ្តាលហ្នឹង។

**ស៖** អ៊ីចឹងលោកនិយាយអំពីសៀវភៅគ្រួសារហ្នឹង សៀវភៅគ្រួសារអី? សៀវភៅគ្រួសាររបស់លោកផ្ទាល់ ឬក៏យ៉ាងម៉េច?

**ឆ៖** ដូចខ្ញុំជម្រាបម្សិលមិញអ៊ីចឹង ឪខ្ញុំគ្រប់អាយុធ្វើឡាំងតាយ បងខ្ញុំក៏គ្រប់អាយុធ្វើឡាំងតាយ ធ្វើសម័យឡាំងតាយហ្នឹង សម័យមុនៗទៀត ប៉ុន្តែពេលដល់ប្រើហ្នឹង ដល់សម័យខ្មែរក្រហមអត់ប្រើឡាំងតាយឡាំងអីទេ គ្រាន់តែកត់ឈ្មោះចូលៗ វាអត់ធ្វើអត្តសញ្ញាណប័ណ្ណអីដូចយើងទេ ដូចសម័យឥឡូវទេ ប៉ុន្តែគ្រាន់តែកត់ឈ្មោះម្ចាស់គ្រួសារហ្នឹងទេ ហើយគ្រួសារប៉ុន្មាននាក់កត់យកប៉ុណ្ណឹងទេ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** ក៏ប៉ុន្តែកាលពីម្សិលមិញ ពេលដែលលោកឆ្លើយទៅនឹងសហព្រះអាជ្ញានោះ ខ្ញុំយល់ថា ខ្មែរក្រហមហ្នឹងមកឆែកឡាំងតាយ។ អ៊ីចឹងនៅពេលនេះលោកនិយាយថា គឺអត់មានការឆែកឆេរអីទេ។ អ៊ីចឹងខ្ញុំយល់យ៉ាងម៉េច? ខ្ញុំដូចជាវង្វេងហើយ។

[០៩:៥៧:៥៨]

**ឆ៖** ដូចខ្ញុំនិយាយថា សម័យខ្មែរក្រហមគេអត់ធ្វើឡាំងតាយឲ្យយើង ឡាំងតាយនេះ គឺសម័យលន់ នល់ ណោះ។ អាហ្នឹងគេប្រើពាក្យលន់ នល់ វិញ សម័យហ្នឹង។ ដល់ពេលចូលសម័យខ្មែរក្រហមហ្នឹង គេធ្វើសំបុត្រគ្រួសារវិញ ដូចថាមេគ្រួសារ គ្រួសារហ្នឹងប៉ុន្មាននាក់ គេនិយាយតែប៉ុណ្ណឹងទេ។ ហើយគេឆែកឡាំងតាយហ្នឹង បានគេធ្វើសំបុត្រគ្រួសារហ្នឹង មេគ្រួសារស្អី? កូនគ្រួសារស្អី? គេដាក់តែប៉ុណ្ណឹង។

**ស៖** កាលពីម្សិលមិញ នៅម៉ោង០៣:០៦:១៧វិនាទី គេសួរលោកដូចតទៅ៖ "ហើយចុះខ្មែរក្រហម ពួកគេមានឆែកមើលឡាំងតាយទេ ឬក៏គេមានសួររកឡាំងតាយទេ? ពេលនោះលោកឆ្លើយថា៖ បាទ គេពិនិត្យមើលឡាំងតាយរបស់យើង គេមើលទាំងអស់។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោក ថាតើចម្លើយរបស់លោកម្សិលមិញនេះយ៉ាងម៉េច? លោកកែប្រែ ឬក៏យ៉ាងម៉េច? លោកថាគេមកហ្នឹងអត់មានពិនិត្យមើលឡាំងតាយទេ គេគ្រាន់តែមកសួរសំណួរទេ។ ថាអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ផ៖** ខ្ញុំនិយាយម្សិលមិញ ខ្ញុំនិយាយរឿងខ្មែរក្រហមហ្នឹងមកសួរឡាំងតាយហើយ។ ត្រូវសួរឡាំងតាយហ្នឹង គេត្រូវមើលយើងឡាំងតាយ បានដឹងជនជាតិវៀតណាម? ជនជាតិខ្មែរ? ហើយជនជាតិចាម? ហ្នឹងខ្ញុំនិយាយតែប៉ុណ្ណឹង។ ដល់ដូចថា ដល់សម័យខ្មែរក្រហមហ្នឹង គេមកយកឡាំងតាយហ្នឹងគឺថា អាយុស្អី? ឈ្មោះអី? ឈ្មោះ អា, ឈ្មោះ បេ អីអ៊ីចឹង គេដាក់ហ្នឹងហើយ។ គេដាក់ហ្នឹង ទៅតាមទៅមួយគ្រួសារហ្នឹងប៉ុន្មាននាក់? ដូចគ្រួសារខ្ញុំបួនប្រាំនាក់ គេដាក់បួនប្រាំនាក់, ប្រាំពីរប្រាំបីនាក់ គេដាក់ប្រាំពីរប្រាំបីនាក់។

[១០:០០:០០]

**ស៖** ខ្ញុំយល់ហើយថាគេចង់ដឹងចំនួនសមាជិកគ្រួសាររបស់លោក ក៏ប៉ុន្តែខ្ញុំសួរលោកម្តងទៀត តើពេលនោះ លោកមានបានបង្ហាញឡាំងតាយរបស់លោកហ្នឹងទៅអ្នកណាទេ ពេលលោកទៅដល់ភ្នំនោះ?

**ផ៖** ឡាំងតាយអី ដល់ភ្នំហ្នឹងឡាំងតាយអីទៀត! ឡាំងតាយអី ឆេះផ្ទះនៅកំពង់ឆ្នាំងអស់ហើយ ឡាំងតាយណាដល់ភ្នំ។

**ស៖** អ៊ីចឹងបានជាខ្ញុំសួរថា នៅពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញាកាលពីម្សិលមិញនេះ ថាខ្មែរក្រហមមកពិនិត្យមើលឡាំងតាយរបស់លោកហ្នឹង លោកនិយាយហ្នឹង លោកសំដៅទៅពេលណា?

**ផ៖** កាលពេលខ្ញុំនិយាយហើយអំមិញ ដល់ឥឡូវនិយាយថា កាលពេលនៅកំពង់ឆ្នាំងៗហ្នឹង គេៗសួរយើងដូចថា ឡាំងតាយហ្នឹង គេមើលអី? គេមើលគ្រួសារប៉ុន្មាននាក់ គេធ្វើអាហ្នឹងហើយ គេធ្វើដូចថាគ្រួសារយើងឈ្មោះអី គេដាក់ឈ្មោះហ្នឹង កូនចៅឈ្មោះអីគេដាក់ហ្នឹងហើយ។ អាហ្នឹងគេកាន់លើដៃគេហើយ គេកាន់លើដៃគេ គេមិនឱ្យយើងដឹងទេ។ គ្រាន់យើងប្រាប់ហ្នឹង ឡាំងតាយគេឲ្យវិញហើយ យើងទុកនៅផ្ទះ។ ដល់គេបណ្តេញយើងចេញហ្នឹង គេបញ្ជូនយើងទៅគេដេញចេញ គេដុតផ្ទះហ្នឹងចោលបាត់ហើយ។

[១០:០១:២៦]

**កញ្ញា លីម៉ា ង្វៀន៖**

លោកចៅក្រម ភ័ស្តុតាងដែលបានមកពីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ពីម្សិលមិញគឺថា ឡាំងតាយនេះ ជាសៀវភៅបន្ទុកគ្រួសាររបស់គាត់។ គាត់បាននិយាយថា យើងត្រូវបង្ហាញទៅដល់ពួកគេ។

មានព្រឹត្តិការណ៍កើតឡើងពីរ ទី១គឺថា បញ្ជូនចេញពីភូមិកំណើតទៅភូមិគួយ ទៅភូមិកណ្តាល។ ហើយការផ្លាស់លំនៅទី២គឺជា -- លើកទី៤ គឺចេញពីភូមិគួយទៅភូមិដារ នៅជិតភ្នំកង្កែប។ ដូច្នេះសំណួរនេះមិនចាំបាច់ទេ សំណួរទាំងនេះគឺថាបានឆ្លើយរួចមកហើយ ហើយក៏មិនត្រូវសួរដើម្បីឲ្យមានការច្របូកច្របល់បែបនេះដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

មេធាវីគាត់ឃើញថាមានការច្របូកច្របល់ ក៏ប៉ុន្តែខ្ញុំៗព្យាយាមបង្ហាញឲ្យភាពច្បាស់លាស់។ នេះគឺជាភារកិច្ចរបស់យើង នៅពេលដែលមានចម្លើយណាដែលមិនសូវច្បាស់ យើងសួរដើម្បីឲ្យបញ្ជាក់ឲ្យបានច្បាស់។ ខ្ញុំបានព្យាយាមសួរយ៉ាងម៉េចឲ្យច្បាស់លាស់ជាមួយសាក្សី ដោយរំឭកអំពីចម្លើយរបស់គាត់កាលពីមុនដើម្បីឲ្យគាត់បានឆ្លើយឲ្យបានច្បាស់។ ហើយសំណួរចម្លើយរបស់មេធាវីបានខ្ញុំចាប់ -- ចម្លើយរបស់សហ -- (សុំទោស) ចម្លើយរបស់ដើមបណ្តឹងបានជា បានខ្ញុំចាប់អារម្មណ៍។ ចំពោះការពន្យល់របស់មេធាវីហ្នឹង ដូចជាមិនមានប្រយោជន៍អីទេ។ ក៏ប៉ុន្តែខ្ញុំបានស្តាប់ឮចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួចមកហើយ ដូច្នេះខ្ញុំសូមបន្តទៅមុខទៀត។

[១០:០៣:១៦]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** កាលពីម្សិលមិញ គឺនៅម៉ោង១១:១៣នាទី លោកដើមបណ្តឹងរដ្ឋប្បវេណី លោកបាននិយាយអំពីមរណភាពរបស់ឪពុកម្តាយលោក។ លោកថាម្តាយរបស់លោក ពេលគេចាប់ខ្លួនលោកនោះគឺម្តាយលោកសន្លប់ ហើយលោកគិតថាប្រហែលជាគាត់ត្រូវបានគេសម្លាប់ចោលនៅក្នុងផ្ទះ។ លោកអាចបញ្ជាក់ពីចំណុចហ្នឹងបានទេ ហើយអាចនិយាយអំពីការចាប់ខ្លួនគ្រួសាររបស់លោកហ្នឹងម្តងទៀតបានទេ?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាន ខ្ញុំជម្រាបឲ្យបានដឹង ពីព្រោះខ្ញុំម្សិលមិញ ខ្ញុំបាននិយាយដែរ។ ម៉ោងប្រាំបីពេលព្រឹកហ្នឹងមកដល់ផ្ទះខ្ញុំហើយ ពាក្យខ្មែរក្រហម គេមិនថាសុំអី ស្ទើរៗចេញពីផ្ទះ ចងៗមួយៗៗ។ មួយៗហ្នឹងមនុស្សមួយខ្សែមួយ។ ចងគ្រួសារខ្ញុំអស់ហើយ ចងចូលមួយខ្សែ ហើយគ្រួសារអែបមួយខាងទៀត ប្អូននាក់ទេ ប្តីប្រពន្ធពីរ កូនពីរ ចងមួយខ្សែទៀត។ គេយកទៅហ្នឹង ជិតរណ្តៅហ្នឹង ប្រហែល១០០ម៉ែត្រទេ គេមិនឲ្យនៅជិតរណ្តៅទេ។ ម្តងមួយៗ យកទៅសម្លាប់ហ្នឹង ដឹងសម្លាប់យ៉ាងណាយ៉ាងណាទេ ខ្ញុំអត់

ឃើញផ្ទាល់ភ្នែកខ្ញុំទេ ប៉ុន្តែដល់យកខ្ញុំទៅវាយចំរណ្ដៅហ្នឹង ខ្ញុំឃើញម៉ែឪខ្ញុំដេកងាប់នៅរណ្ដៅទាំងអស់។

**ប្រធានអង្គជំនុំ៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី មិនឆ្លើយតបនឹងសំនួរទេ លោកស្ដាប់សំណួរឲ្យច្បាស់ហើយឆ្លើយតបខ្លីទៅចំនឹងសំណួរបានហើយ។ ជៀសវាងលោកអត្ថាធិប្បាយច្រើន គេនឹងយកសេចក្ដីអត្ថាធិប្បាយរបស់លោកយកមកសួរផ្ទុញលោក ដូចអ្វីដែលគេបានសួរកន្លងមកនេះ។ នេះជានីតិវិធីនៃការសួរដេញដោលតាមផ្លូវតុលាការ ហើយវាអត់ប្រយោជន៍ ពីព្រោះលោកមិនឆ្លើយតបទៅនឹងសំណួរដែលភាគីសួរទេ។

មេធាវីតាំងសំណួរចុងក្រោយរបស់លោកស្រីម្ដងទៀត ព្រោះគាត់ទំនងស្ដាប់សំណួររបស់លោកស្រីមិនយល់ទេ អម្បាញ់មិញនេះ។ ឆ្លើយហ្នឹង គឺឃ្លាតឆ្ងាយ មិនចំទៅនឹងសំណួរដែលសួរទេ។

[១០:០៥:៣៨]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី កាលពីម្សិលមិញ គឺនៅម៉ោង១១:១៣នាទី លោកបាននិយាយអំពីការចាប់ខ្លួនក្រុមគ្រួសាររបស់លោក។ ហើយលោកបាននិយាយថា ម្ដាយរបស់លោកហ្នឹងត្រូវបានសម្លាប់នៅក្នុងផ្ទះតែម្ដង។ តើលោកអាចបញ្ជាក់ចម្លើយនេះម្ដងទៀតបានទេ ថាម្ដាយរបស់លោកហ្នឹង ពិតជាត្រូវបានគេសម្លាប់នៅក្នុងផ្ទះមែន ឬក៏មិនមែន?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ខ្ញុំថាសន្លប់ទេ សម្លាប់អី! អត់មានសម្លាប់ទេ។ សន្លប់ៗខ្លួននៅនឹងផ្ទះហ្នឹងហើយ រួចក៏ចាប់ចងដែរ។ មិនមែនថា អត់នេះទេ ទាញទៅអស់មួយខ្សែ អត់មានងាប់នៅក្នុងផ្ទះហ្នឹងទេ។ សន្លប់ខ្លួនតែបន្តិចទេ។ ខ្ញុំបាននិយាយអ៊ីចឹងដែរ។

**ស៖** លោកអាចប្រាប់បានទេ អ្នកណាជាអ្នកមកចាប់ក្រុមគ្រួសារលោក ហើយមានគ្នាប៉ុន្មាននាក់?

**ឆ៖** ឈ្មោះខ្ញុំមិនដឹងទេ រឿងឈ្មោះ ខ្ញុំមិនដឹងទេ។ មកប្រាំបីនាក់ កាំភ្លើងប្រាំបីដើម គល់ពីងពង់មួយគល់ អាថៅមួយកូនអាថៅមួយ។

[១០:០៦:៥៧]

**ស៖** លោកធ្លាប់ស្គាល់អ្នកទាំងប្រាំបីនាក់ហ្នឹងពីមុនមកទេ?

ធ៖ អត់ដែលស្គាល់ទេ។

ស៖ ដូច្នេះលោកមិនដឹងថា ពួកហ្នឹងជាទាហាន ជាឈ្លប ហើយធ្វើការនៅភូមិ នៅឃុំ នៅស្រុក អី លោកអត់ដឹងទេ មែនទេ?

ធ៖ ដឹងធ្វើការនៅភូមិហ្នឹងតែម្តង ការពារនៅហ្នឹង មិនមែននេះទេ ខ្មែរក្រហមបណ្តោយ អត់មានសេនាជន កាលហ្នឹងអត់មានសេនាជន សេនាអីទៀត។

ស៖ ហើយលោកអាចបែងចែកយ៉ាងម៉េចបាន រវាងអ្នកមូលដ្ឋាន ហើយនិងឈ្លបហ្នឹង?

ធ៖ មូលដ្ឋានហ្នឹង គេពាក់ខោអាវខ្មៅហើយ ក្រមាបង់កហើយ។

ស៖ ចុះឈ្លបវិញ ពួកគាត់ពាក់សម្លៀកបំពាក់ខោអាវពណ៌អីដែរ?

ធ៖ ពណ៌ធម្មតាៗ។

ស៖ ពណ៌ធម្មតាហ្នឹង មានន័យថាម៉េច លោកអាចរៀបរាប់បន្តិចបានទេ?

ធ៖ ដូចជាប្រជាជនសព្វថ្ងៃ ចង់ពាក់អាវពណ៌អីក៏បាន ពណ៌អីក៏បាន។

ស៖ តាមរយៈចម្លើយរបស់លោក លោកមានន័យថា ឈ្លបហ្នឹងពាក់ខោអាវធម្មតា ដូចប្រជាជនសព្វថ្ងៃ ហើយអ្នកមូលដ្ឋានហ្នឹង គេពាក់ខោអាវពណ៌ខ្មៅ ហើយមានបង់កក្រមា។ លោកចង់និយាយអ៊ីចឹង មែនទេ?

ធ៖ បាទ។

[១០:០៩:៣២]

ស៖ លោកបានឆ្លើយថា គេបានបញ្ជូនលោកទៅដារ ប្រហែលជាចម្ងាយ១គីឡូម៉ែត្រ។ អ៊ីចឹងមានន័យថា គឺលោកដើរហ្នឹង ចម្ងាយប្រហែលជា១គីឡូម៉ែត្រជាមួយក្រុមគ្រួសារលោក ហើយលោកបន្ទាប់មកលោកបានឃើញរណ្តៅសាកសពហ្នឹង មែនទេ?

ធ៖ ខ្ញុំដើរជាមួយក្រុមគ្រួសារខ្ញុំ ដើរជាមួយមួយខ្សែហ្នឹង ហើយចងខ្ញុំ កន្លែងរណ្តៅហ្នឹងមួយខាងហ្នឹងប្រហែល១០០ម៉ែត្រ អត់ឲ្យឃើញ ឃើញតែគ្នាជុំទេ។ ទាញទៅមួយៗហ្នឹង ទៅសម្លាប់ហ្នឹង ខ្ញុំអត់ឃើញមុខទេ ទៅដល់ យកខ្ញុំចុងក្រោយទាំងអស់ហ្នឹង ចូលរណ្តៅ។

ស៖ ខ្ញុំចង់ដឹងថា រណ្តៅដែលលោកឃើញហ្នឹង មានចម្ងាយ១គីឡូម៉ែត្រពីភូមិដារ មែនទេ?

ធ៖ មែនហើយ។

ស៖ ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីពេលដែលលោកភ្ញាក់ឡើង ហើយលោកនៅរស់រានមាន

ជីវិត ហើយលោកបានចេញពីរណ្ដៅ--

**ប្រធានអង្គជំនុំ៖**

បាទ បានហើយ។ បាទ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់ និងសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** មុនពេលឈប់សម្រាក យើងបាននិយាយអំពីពេលដែលលោកចេញអំពីរណ្ដៅ ហើយលោកឆ្លើយថា បន្ទាប់មកលោកបានរត់ទៅផ្ទះ តាលី។ ហើយកាលពីម្សិលមិញនៅម៉ោង ១១:២៩នាទី លោកថា ខ្ញុំសូមដកស្រង់ ខ្ញុំដើរទាំងយប់ទាំងថ្ងៃទៅដល់ភូមិមួយ (ជាភាសាបារាំង គឺមិនមានប្រាប់ឈ្មោះភូមិទេ ក៏ប៉ុន្តែជាភាសាខ្មែរគឺថាភូមិជើងគ្រោះ) រួចលោកទៅផ្ទះ តាលី។ ដូច្នេះតើលោកអាច

បញ្ជាក់ថាបានទេថា លោកប្រើពេលមួយយប់មួយថ្ងៃដើម្បីទៅដល់ផ្ទះ តាលី ហើយលោកអាចបញ្ជាក់បានទេថា ផ្ទះតាលី ស្ថិតនៅត្រង់ណា?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាទ នៅជើងគ្រោះហ្នឹង នៅជើងគ្រោះ។ ខ្ញុំដល់កន្លែងជើងគ្រោះហ្នឹងតែម្តង ដល់ផ្ទះគាត់ហ្នឹង។

[១០:៣៣:១៩]

**ស៖** លោកពិតជាដើរអស់មួយយប់មួយថ្ងៃ មែនទេ ដើម្បីទៅដល់ផ្ទះ តាលី?

**ឆ៖** បាទ មែនហើយ។

**ស៖** ខ្ញុំសួរសំណួរនេះដើម្បីឲ្យបានយល់ច្បាស់ ពីព្រោះថាយើងមានឯកសារផ្សេងគ្នាពាក់ព័ន្ធទៅនឹងរឿងរ៉ាវរបស់លោក។ ឯកសារទី១ ដែលខ្ញុំចង់យោងនោះ គឺឯកសារ E3/6695 គឺនៅផ្នែក(ខ) នៃទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដែលលោកបានសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។ សំណួរដំបូងខ្ញុំ ខ្ញុំចង់សួរលោកថា ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានបានបំពេញទម្រង់បែបបទណាមួយ ដោយមានជំនួយពីបុគ្គលណាម្នាក់ទេ? លោកមាននៅចាំទេកាលពីលោកដាក់ពាក្យសុំនោះ លោកមានបានបំពេញបែបបទអីទេ?

**ឆ៖** ខ្ញុំមានបំពេញបែបបទខ្ញុំ សុំពាក្យប្តឹងនោះ លោក ស្រូយ។

**ស៖** នៅក្នុងពាក្យសុំនោះ លោកបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់ គឺឯកសារ ERN ជាភាសាបារាំង 01139845, ERN ជាភាសាខ្មែរគឺ00561340, ជាភាសាអង់គ្លេសគឺ0106664 *(ស៊ីក)*។ ខ្ញុំសូមដកស្រង់៖ “គឺប្រហែលជាម៉ោងប្រាំមួយល្ងាច ខ្ញុំភ្ញាក់ឡើង បន្ទាប់មកខ្ញុំដើរទៅព្រៃលិចទឹកមួយនៅមាត់បឹង ខ្ញុំហែលទៅគេចខ្លួននៅជិតភ្នំមួយនៅកណ្តាលព្រៃ។ ក្រោយមក ខ្ញុំបានឃើញទូកមួយ ហើយខ្ញុំរត់ទៅភូមិសំរោងសែន ដោយខ្ញុំហូបតែត្រកួនព្រៃតែប៉ុណ្ណោះ។” សូមបញ្ចប់ការដកស្រង់។ នៅក្នុងទម្រង់បែបបទបំពេញពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីនេះ លោកមិនបាននិយាយថា លោកបានទៅផ្ទះ តាលី ទេ។ ដូច្នេះ លោកអាចបញ្ជាក់ឲ្យបានច្បាស់បានទេថា ក្រោយពីលោកដឹងខ្លួនហ្នឹង លោកពិតជាបានដើរសំដៅទៅផ្ទះ តាលី នោះមែនទេ?

[១០:៣៦:១៦]

**ឆ៖** ខ្ញុំដឹងខ្លួន ដើរទៅផ្ទះ តាលី ហ្នឹងហើយ មែន។

**ស៖** អម្បាញ់មិញនេះ លោកបានបញ្ជាក់ថា លោកបានដើរអស់មួយយប់មួយថ្ងៃដើម្បីទៅដល់ផ្ទះតាលី។ ក៏ប៉ុន្តែនៅក្នុងព័ត៌មានបន្ថែមរបស់លោក គឺឯកសារ E3/5631 ដែលលោកបានសម្ភាសជាមួយមេធាវីរបស់លោក គឺនៅទំព័រជាភាសាបារាំង 00898372, ជាភាសាខ្មែរគឺ 00897514 និងអង់គ្លេស 00678292។ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "ខ្ញុំបានចេញពីរណ្តៅ ហើយខ្ញុំដើរអស់មួយម៉ោង រហូតទៅដល់ផ្ទះជនជាតិវៀតណាមមួយរូបគឺ តាលី។ គាត់បានលាក់ខ្ញុំនៅក្នុងផ្ទះគាត់ ហើយគ្រួសារគាត់បានជួយព្យាបាលរបួសស្នាមរបស់ខ្ញុំ។ ខ្ញុំលាក់ខ្លួន និងស្នាក់នៅទីនោះប្រហែល ២ខែកន្លះ។" ដូច្នេះ តើលោកអាចឆ្លើយឱ្យបានច្បាស់បានទេ ថាលោកដើរអស់មួយយប់មួយថ្ងៃ ឬក៏ដើរតែប្រហែលមួយម៉ោង? តើចម្លើយមួយណាដែលត្រឹមត្រូវពិតប្រាកដនោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាទ មួយយប់មួយថ្ងៃ បានដល់ផ្ទះ តាលី។

[១០:៣៨:៣៦]

**ស្ហរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ចុះហេតុអីបានជានៅក្នុងទម្រង់ព័ត៌មានបន្ថែមរបស់លោកនេះ លោកបានសរសេរថា តែមួយម៉ោង?

**ឆ៖** ហ្នឹង ខ្ញុំអត់ដឹង។

**ស៖** នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺឯកសារ E3/6695 គឺមានសរសេរថា ភូមិសំរោងសែន។ ដូច្នេះតើនៅពេលណាមួយនោះ ក្រោយពីលោកបានទៅផ្ទះ តាលី ហើយនោះ លោកមានធ្លាប់ទៅភូមិសំរោងសែនហ្នឹងទេ?

**ឆ៖** ទៅព្យាបាលនៅៗ តាលី ហ្នឹង កាលហ្នឹងដល់គេ តាលី ហ្នឹងគាត់ធ្វើទៅឱ្យខ្ញុំមួយរយៈបួនប្រាំថ្ងៃហ្នឹង បួនប្រាំថ្ងៃ ឱ្យខ្ញុំចៀសផុតពីផ្ទះគាត់ហ្នឹង នឹងអាលគាត់ធ្វើសំបុត្រ ឱ្យធ្វើបែបបទទៅស្រុកវៀតណាម។ អ៊ីចឹងដើម្បីខ្ញុំទៅ ឡើងទៅសំរោងសែនវិញ។ សំរោងសែន ខ្ញុំបង្កប់ខ្លួននៅហ្នឹង៧ថ្ងៃ បានខ្ញុំហែលមកផ្ទះគាត់។

**ស៖** អ្វីដែលខ្ញុំមិនយល់នោះ គឺថាតើសំរោងសែននៅឯណា? តាមរយៈចម្លើយនៅក្នុងសវនាការ

គឺថា ពេលដែលលោកងើបពីរណ្ដៅហើយ លោកទៅផ្ទះ តាលី តែម្ដង។ អ៊ីចឹងខ្ញុំគិតថា លោកនៅផ្ទះ តាលី ហ្នឹងអស់រយៈពេល២ខែកន្លះ។ អ៊ីចឹងពេលណាដែលលោកទៅនៅសំរោងសែនហ្នឹង?

**ឆ៖** ពេលអា២ខែកន្លះហ្នឹង បានខ្ញុំនិយាយ ខ្ញុំជម្រាប។ ដូច តាលី ធ្វើសំបុត្រឲ្យ ខ្ញុំគេចខ្លួន បានខ្ញុំទៅសំរោងសែន ជិះកូនទូកមួយជាមួយគេហ្នឹង ដើរទៅសំរោងសែនហ្នឹង។ មួយអាទិត្យបានខ្ញុំមកផ្ទះ តាលី វិញ។

[១០:៤០:៥៣]

**ស៖** ដូច្នេះសំរោងសែន នេះគឺជាភូមិមួយដែលលោកបានដើរទៅ ដើម្បីទៅជិះទូកអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែនហើយ ជិះទូក សំរោងសែន បានជិះទូក បានទៅបាន។

**ស៖** តាមរយៈសក្ខីកម្មរបស់លោកនៅក្នុងសវនាការ ខ្ញុំយល់ថា ជាដំបូងហ្នឹងលោកជិះទូកជាមួយគ្រួសារ តាលី ហើយបន្ទាប់មកគេបញ្ជូនលោកពីទូកហ្នឹងឡើងទៅជិះសាឡាង់។ តើអ៊ីចឹងមែនទេ?

**ឆ៖** មិនមែនអ៊ីចឹងទេ។ ខ្ញុំទៅដូចថា តាលី គាត់និយាយឲ្យខ្ញុំ ឲ្យខ្ញុំហ្នឹងនៅ តាលី ហ្នឹង២ខែជាងហើយ ដូចខ្ញុំជម្រាបអ៊ីចឹង។ ដល់ខ្ញុំ -- តាលី ហ្នឹងគាត់ខ្លាចទៅ ប៉ះពាល់លើគាត់ ពីព្រោះគ្រួសារគាត់ប្រាំបីនាក់ទេ ដល់ខ្ញុំទៅប្រាំបួននាក់។ អ៊ីចឹងដើម្បីគាត់ឲ្យខ្ញុំចៀស ចៀសមុខនៅហ្នឹងទៅ លាក់ខ្លួននៅសំរោងសែនហ្នឹង ជិះទូកតូចហ្នឹង ដោយសារគេជិះទូកតូចហ្នឹងទៅសំរោងសែន។ ដល់មួយអាទិត្យក្រោយហ្នឹង តាលី ហ្នឹងគាត់ឲ្យខ្ញុំដឹង យកដំណឹងថា ពីរបីថ្ងៃទៀតទៅហើយ បានខ្ញុំដោយសារមក បង្កប់ខ្លួន តាលី នេះបានជិះទូក តាលី ហ្នឹងទៅស្រុកយួន ឡើងសាឡាង់ហ្នឹង។

**ស៖** ក៏ប៉ុន្តែកាលពីម្សិលមិញនេះ ពេលដែលលោកឆ្លើយទៅនឹងសំណួររបស់ភាគីហ្នឹង គឺយើងយល់ថា លោកជិះទូករបស់ តាលី។ ដល់ពេលនេះ លោកឆ្លើយថាលោកជិះសាឡាង់ហ្នឹងនៅសំរោងសែនទៅវិញ។ អ៊ីចឹងលោកអាចពន្យល់បានទេ ខ្ញុំមិនយល់?

[១០:៤៣:០១]

**ឆ៖** ខ្ញុំនិយាយដូចថា ឮមិនច្បាស់។ ខ្ញុំនិយាយថា៧ថ្ងៃក្រោយហ្នឹង ខ្ញុំនៅសំរោងសែនហ្នឹង មុន តាលី ហ្នឹងគាត់ឲ្យខ្ញុំគេចមុខហ្នឹង ៧ថ្ងៃក្រោយ តាលី ហៅខ្ញុំចូលមកជើងគ្រោះហ្នឹង។ មួយថ្ងៃពីរថ្ងៃ ខ្ញុំចេញជាមួយ តាលី ហ្នឹងទៅ។ ដល់មាត់ទន្លេបួនមុខនេះ ខ្ញុំបានឡើងសាឡាង់។

**ស៖** តាលី ហ្នឹងហើយមែនទេ ជាអ្នកចេញសំបុត្រអនុញ្ញាតឲ្យលោកដើម្បីទៅវៀតណាមហ្នឹង?

**ឆ៖** មិនមែនទេៗ។ គាត់ប្រជាជនដូចខ្ញុំអ៊ីចឹង អ្នកស្រុកឫស្សីជង្គួចដូចខ្ញុំអ៊ីចឹង។ មិនមែនទេ។

**សៈ** អម្បាញ់មិញនេះ លោកនិយាយអំពីសំបុត្រមួយដែល តាលី ផ្ញើឲ្យលោក។ អ៊ីចឹងលោកនិយាយអំពីសំបុត្រអ្វី ពេលដែល តាលី ផ្ញើទៅហ្នឹង?

**ឆៈ** អំមិញខ្ញុំនិយាយថា តាលី ហ្នឹងគាត់ផ្ញើសំបុត្រទៅស្រុកវៀតណាមហ្នឹង គេមកដូចថា ផ្ញើគ្រួសារគាត់ប៉ុន្មាននាក់ អ៊ីចឹងហ្នឹងគាត់ផ្ញើគ្រួសារហ្នឹង របស់គាត់ទេ ប៉ុន្តែខ្ញុំមិនដឹងថាពីណាផ្ញើផង។ គាត់ក៏ប្រាប់ខ្ញុំថា គាត់ផ្ញើសំបុត្រគ្រួសារហ្នឹង គាត់ទៅវៀតណាមហ្នឹង ផ្ញើប្រាំបីនាក់គ្រួសាររបស់គាត់ទេ។ ហើយខ្ញុំចូលម្នាក់ទៀត ប្រាំបួននាក់ វាលើសៗហើយ អ៊ីចឹងខ្ញុំត្រូវគេចខ្លួនហ្នឹង ៧ថ្ងៃ។ បានខ្ញុំមកវិញមួយថ្ងៃពីរថ្ងៃ បានចេញដំណើរទៅជាមួយគាត់។ ជិះ មិនជិះទូកជាមួយគាត់ផង នៅឃ្លុបទូក ឃាត់កន្លែងគេឆែកឆេរមនុស្សហ្នឹង រួចបានគាត់ឲ្យខ្ញុំឡើងលើហ្នឹង ជួយចែវ ជួយអុំដល់មាត់ ប្អូនមុខនេះ – ទន្លេប្អូនមុខនេះ បានខ្ញុំឡើងសាឡង់។

[១០:៤៥:00]

**សៈ** ខ្ញុំយល់អំពីចំណុចនេះ ក៏ប៉ុន្តែចំណុចដែលខ្ញុំមិនយល់ច្បាស់ហ្នឹង គឺសំបុត្រដែលលោកថាលោកទទួលពី តាលី នោះ។ លោកអម្បាញ់មិញនេះលោកថា លោកទទួលបានសំបុត្រមួយពី តាលី គឺ តាលី ផ្ញើសំបុត្រឲ្យលោក។ ខ្ញុំចង់ដឹងថាសំបុត្រហ្នឹងជាសំបុត្រអី?

**ឆៈ** ខ្ញុំអត់បាននិយាយរឿងថា តាលី ផ្ញើសំបុត្រទេ។ ខ្ញុំថាៗ តាលី ផ្ញើសំបុត្រ។ សំបុត្រ តាលី ហ្នឹងផ្ញើខាងអង្គការហ្នឹង អង្គការគេផ្ញើឲ្យ តាលី ហ្នឹងទេ។ មិនខ្ញុំថា តាលី ផ្ញើសំបុត្រឲ្យខ្ញុំទេ។

**សៈ** អ៊ីចឹងមិនអីទេ។ លោកថា តាលី ជាប្រជាជនធម្មតា ហើយគឺជាជនជាតិវៀតណាម។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆៈ** បាទ ត្រឹមត្រូវហើយ។

**សៈ** អ៊ីចឹងសំបុត្រដែល តាលី ផ្ញើហ្នឹងគឺជាសំបុត្រដើម្បីអនុញ្ញាតឲ្យគ្រួសារ តាលី ទាំងមូលហ្នឹងទៅវៀតណាម មានន័យថា តាលី ហ្នឹងគាត់ស្នើទៅអង្គការដើម្បីទៅវៀតណាមមែនទេ?

**ឆៈ** អារឿង តាលី គាត់ស្នើមិនស្នើទេ ប៉ុន្តែគាត់ថាគាត់ផ្ញើសំបុត្រ បានគាត់បានទៅបាន។ ហ្នឹងខ្ញុំឮតាមគាត់និយាយទេ។ ឲ្យខ្ញុំលាក់ខ្លួនហ្នឹង អត់ឲ្យនៅទូកគាត់ហ្នឹង។ ខ្ញុំអត់ដឹងពីណាផ្ញើ ពីណាផ្ញើយ៉ាងម៉េចទេ រឿងហ្នឹងខ្ញុំអត់ដឹង។

**សៈ** នៅក្នុងឯកសារព័ត៌មានបន្ថែមរបស់លោកគឺ E3/5631, ERN ជាភាសាបារាំង 00898373, ERN ជាភាសាអង់គ្លេស 00678293 និង ERN ជាភាសាខ្មែរ 00897515។ លោកបាន

សរសេរដូចតទៅ ពាក់ព័ន្ធនឹងរបៀបនៃការចរចាដើម្បីឡើងជិះសាឡង់។ លោកបានឆ្លើយដូចតទៅ៖ "រដ្ឋាភិបាលវៀតណាមនិងខ្មែរក្រហមបានដូរអង្ករ អំបិលជាមួយ ដើម្បីផ្តល់សុវត្ថិភាពដល់ប្រជាជនវៀតណាមវិលត្រឡប់ទៅកាន់វៀតណាម។ យើងត្រូវនៅក្បែរៗទូក ហើយយើងមិនបានអនុញ្ញាតឲ្យដើរទៅណានោះទេ។ ទូកនិងសាឡង់ទាំងអស់ផ្សេងទៀតត្រូវឈប់នៅផ្សារអ្នកលឿងចំនួន៣ថ្ងៃ"។ តើលោកបានចាំទេថា លោកបានឆ្លើយបែបហ្នឹងទៅមេធាវីរបស់លោក?

[១០:៤៨:០០]

**ឆ៖** ខ្ញុំចាំអ៊ីចឹង។ រឿងខ្ញុំៗចាំថា ខ្ញុំមកដល់អ្នកលឿងហ្នឹង បានខាងអង្គការខាងខ្មែរយើងនេះឲ្យជាប់ជាមួយអង្គការវៀតណាមនោះ គេនិយាយយ៉ាងម៉េច ខ្ញុំអត់ដឹងទេ ប៉ុន្តែឲ្យខ្ញុំឡើងលើគោកហ្នឹង គេសងខាងគេរាប់ហើយ រាប់មនុស្ស។ អ៊ីចឹងរាប់ហ្នឹង ខ្ញុំក៏មិនដឹងប៉ុន្មានទេ ហើយឡើងលើគោកហ្នឹងអង្គុយស្ងៀមនៅនឹងទៅ។ ហើយគេដូរអង្ករ ដូរអំបិលអីយ៉ាងម៉េច ខ្ញុំមិនដឹងដែរ។ ដល់គេហៅចូលសាឡង់ហ្នឹងទៅស្រុកយួនវិញហ្នឹង បានអង្គការខាងសាឡង់វៀតណាម គេនិយាយដូច ខ្ញុំអំមិញនិយាយដែរ គេថា "អស់លោកអើយរស់ហ្នឹងដើម្បីអង្ករ អំបិលទេ" ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** នៅក្នុងឯកសារនេះមាននិយាយអំពីផ្សារអ្នកលឿង។ លោកធ្លាប់ស្គាល់ផ្សារហ្នឹងពីមុនមកទេ?

**ឆ៖** ខ្ញុំអត់ធ្លាប់ស្គាល់ទេ។ ម៉ែឪខ្ញុំកើតលើហ្នឹង អាយុខ្ញុំប៉ុណ្ណឹង មិនទាន់ទៅភ្នំពេញបានផង មិនដឹងស្គាល់អ្នកលឿងយ៉ាងម៉េច។

**ស៖** ចុះសាឡង់ដែលលោកជិះហ្នឹង ជាសាឡង់ដែលធ្លាប់ដឹកមនុស្ស ឬក៏ជាសាឡង់គេសម្រាប់ដឹកទំនិញ?

[១០:៤៩:៣១]

**ឆ៖** ការងារហ្នឹងខ្ញុំអត់ចាំបាន សាឡង់ហ្នឹង ខ្ញុំដឹង សាឡង់ដឹងដាក់មនុស្ស ឬដាក់ស្អីៗ ខ្ញុំមិនដឹងទេ។ បានតែទៅហ្នឹងរស់ហ្នឹង ខ្ញុំអរហើយ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ខ្ញុំអត់ដឹងអីទេ។

**ស៖** ប្រធានបទចុងក្រោយដែលខ្ញុំចង់ពិភាក្សាជាមួយលោក គឺពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកនៅក្នុងឯកសារ E3/5631។ កាលពីម្សិលមិញ លោកបានឆ្លើយទៅនឹងសហភាតារបស់ខ្ញុំថា ឯកសារហ្នឹងគេបានអានឲ្យលោកស្តាប់ឡើងវិញ។ ដូច្នេះ ពេលដែលគេអានឲ្យលោកស្តាប់នោះ លោកមានបានកែព័ត៌មានមួយចំនួនដែលមិនត្រឹមត្រូវទេ?

**ឆ៖** ទេ ខ្ញុំអត់កែអីទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ក៏ប៉ុន្តែមេធាវី គង់ សំអុន គាត់មានសំណួរមួយចំនួនតូចទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទ សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ខ្ញុំចង់សួរខ្លីៗទេ។ ដំបូងខ្ញុំចង់សួរពីការទម្លាក់គ្រាប់បែក។ តើលោកធ្លាប់បានឮទេក្នុងចន្លោះពេលពីឆ្នាំ៧១ រហូតដល់ឆ្នាំ៧៥ នៅពេលដែលលោកនៅកំពង់លែង មុនពេលដែលលោកថាលោកចេញពីភូមិឫស្សីដង្គួចមកខាងកំពង់ឆ្នាំង? លោកធ្លាប់មានឮការទម្លាក់គ្រាប់បែកដោយយន្តហោះឬក៏ការបាញ់គ្រាប់ផ្លោងធំៗទេ?

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** បាទ សម័យហ្នឹងខ្ញុំដឹង។ ខ្ញុំដឹងណាស់ គ្រាប់បែកហ្នឹង ខ្ញុំដឹង បោះពីលើក្បាលខ្ញុំ។ ប៉ុន្តែខ្ញុំហ្នឹងជីករណ្តៅនៅក្រោម យកឈើគល់ធំៗដាក់លើមាត់រណ្តៅ យកដីកប់ផង ហើយមានកប៉ាល់ហោះមកដាក់គ្រាប់បែក ខ្ញុំរត់ចូលរណ្តៅអស់ហើយ។ សម័យហ្នឹងខ្ញុំដឹង។

[១០:៥១:៥៧]

**ស៖** បាទ លោកចាំបានថា ការទម្លាក់គ្រាប់បែកហ្នឹង ច្រើនប៉ុនណា ញឹកញាប់ប៉ុនណាទេ?

**ឆ៖** បាទ ខ្ញុំដឹងតែភូមិខ្ញុំទេ។ នៅឯណាទៀត ច្រើនមិនច្រើន ខ្ញុំអត់ដឹងទេ។ ខ្ញុំដឹងតែនៅភូមិខ្ញុំនៅយូរៗមកអ៊ីចឹង ដាក់ពីរបីគ្រាប់ទៅ។

**ស៖** បាទ ខ្ញុំនិយាយនេះ គឺនិយាយក្នុងភូមិរបស់លោកហ្នឹងកន្លែងដែលលោករស់នៅហ្នឹង ថាតើការទម្លាក់គ្រាប់បែកហ្នឹងញឹកញាប់ទេ?

**ឆ៖** ការខ្ញុំដឹងតែពីរដងទេ។ តែពីរដង បោះក្នុងភូមិខ្ញុំតែពីរដង ខ្ញុំដឹងនៅហ្នឹងតែពីរដង បោះ

គ្រាប់បែក។

**ស៖** បាទ សូមអរគុណ។ ចុះលោកដឹងពីភូមិនៅក្បែរៗភូមិលោកដែរទេ មានការទម្លាក់គ្រាប់បែកទេ?

**ឆ៖** ឮៗមែន ឮផ្ទុះមែន ប៉ុន្តែមិនដឹងប៉ុន្មានគ្រាប់ទេ ឮផ្ទុះនោះ។ កាលឮផ្ទុះ រួចទៅចូលរណ្ដៅអស់ហើយ អត់ដឹងស្អីទៀតទេ នៅរណ្ដៅ។

**ស៖** បាទ សូមអរគុណ។ លោកអាចបែងចែក ឬក៏ស្គាល់ភាពខុសគ្នាក្នុងការគ្រប់គ្រងរដ្ឋបាលក្នុងភូមិរបស់លោក រវាងរដ្ឋបាលរបស់សាធារណរដ្ឋខ្មែរ ហើយនិងរដ្ឋបាលរបស់ខាងរណសិរ្សរួបរួមជាតិដែរទេ? លោកអាចបែងចែកពីរក្រុមហ្នឹងបានទេ?

**ឆ៖** កាលខ្ញុំហ្នឹង បែងចែកមិនបានទេ ខ្ញុំវាតូចពេក ហើយខ្ញុំខ្លាចទាហានណាស់ ខ្ញុំអត់បែងចែកបានទេ។ ខ្ញុំនៅនឹក -- រឿងចាំអីខ្ញុំចាំបាន ប៉ុន្តែបែងចែកច្បាស់មិនបានទេ ពីព្រោះខ្ញុំខ្លាចទាហានផង។

[១០:៥៤:១០]

**ស៖** បាទ សូមអរគុណ។ តើកម្មាភិបាល ឬក៏មន្ត្រីដែលមានឯកសណ្ឋានយ៉ាងដូចម្ដេចដែលលោកបានឃើញនៅក្នុងតំបន់របស់លោកហ្នឹង នៅក្នុងភូមិរបស់លោក?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ។ កាលហ្នឹង ខ្ញុំអត់ដឹងទេ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឯកសារ E3/5631 ត្រង់ទំព័រទី១ទាំងបីភាសា។ ខ្ញុំបានស្ដាប់ឮការផ្ដល់សក្ខីកម្មរបស់លោកកន្លងមកថា លោកបានចេញពីភូមិឫស្សីដង្ហួច មកភូមិកណ្ដាលនៅទីរួមខេត្តកំពង់ឆ្នាំង ក៏ប៉ុន្តែនៅក្នុងឯកសារនេះលោកឆ្លើយថា លោកចេញពីភូមិឫស្សីដង្ហួចទៅកាន់ភូមិដារ ឃុំដារនៅភ្នំកិប ឬក៏ភ្នំកង្កែបដែលលោកបានហៅកន្លងមក។ អ៊ីចឹងខ្ញុំចង់សួរថា តើមួយណាត្រឹមត្រូវ? តើលោកបានមកខេត្តកំពង់ឆ្នាំងនៅទីរួមខេត្តកំពង់ឆ្នាំង ភូមិកណ្ដាលហ្នឹងទេ ឬមួយក៏លោកទៅភ្នំដារនោះតែម្ដង នៅពេលដែលចេញពីភូមិឫស្សីដង្ហួច?

**ឆ៖** ឯកសារមួយហ្នឹង នៅភូមិកណ្ដាលហ្នឹងត្រូវហើយ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងឡាំងតាយដែលលោកបាននិយាយកន្លងមក លោកអាចបញ្ជាក់ពីទំហំ និងពណ៌របស់វាបានទេ?

**ឆ៖** កាលហ្នឹងខ្ញុំអត់ចាំបានទេ ពីព្រោះឡាំងតាយហ្នឹង ម៉ែឪខ្ញុំគាត់និយាយ ខ្ញុំឮតែម៉ែឪខ្ញុំនិយាយទេ ប៉ុន្តែគាត់លាក់ណាស់ ឡាំងតាយហ្នឹងគាត់លាក់ណាស់។ អាសំបុត្រឡាំងតាយហ្នឹង ថ្លៃណាស់កាល

ហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ខ្ញុំអត់ដឹងពណ៌អីៗ។

[១០:៥៦:៣១]

**ស៖** បាទ អ៊ីចឹងមានន័យថា លោកមិនដែលបានឃើញឡាំងតាយហ្នឹងទេ គឺលោកបានឮតាមរយៈឪពុកម្ដាយលោកជាអ្នកប្រាប់លោក ពីការលាក់ឡាំងតាយហ្នឹង។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកបានឆ្លើយច្រើនលើកហើយទាក់ទងនឹងការដែលលោករត់ចេញពីភូមិ -- ពីស្រុកកំពង់លែង ជាមួយនឹងគ្រួសាររបស់ តាលី។ លោកបានផ្ដល់ព័ត៌មានថា តាលី ជាអ្នកប្រាប់លោកពីព័ត៌មានដែលជនជាតិវៀតណាមអាចត្រឡប់ទៅប្រទេសវៀតណាមវិញ។ ខ្ញុំចង់សួរលោកថា តើលោកដឹងព័ត៌មាននេះ ជាលក្ខណៈបុគ្គលតែជាមួយ តាលី ទេ ឬក៏មានការផ្សព្វផ្សាយជាសាធារណៈដែលលោកអាចដឹងពីខាងក្រៅបានដែរ?

**ឆ៖** បានជាដឹង បាន តាលី ប្រាប់ខ្ញុំទេ។ ខ្ញុំដឹង តាលី ប្រាប់ខ្ញុំដំណឹង តែប៉ុណ្ណឹង។

**ស៖** តើលោកដឹង ឬក៏តាលីមានប្រាប់លោកពីការរៀបចំចុះឈ្មោះជាមុនដើម្បីទៅឡើងសាឡាងដែលលោកនិយាយថា ជាសាឡាង ឬក៏ជាសាឡង់នៅភ្នំពេញនោះដែរទេ មានការរៀបចំជាមុនដែរទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងមានន័យថា ការឡើងជិះសាឡង់ហ្នឹង ឲ្យតែជនជាតិវៀតណាមគឺអាចមកឡើងជិះសាឡង់នៅភ្នំពេញដែលលោកបញ្ជាក់ថា នៅទន្លេបួនមុខ។ តើអ៊ីចឹងត្រឹមត្រូវទេ?

[១០:៥៩:១៥]

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកមកដល់ទន្លេបួនមុខ លោកមានបានឡើងមកលើគោកដែរទេ?

**ឆ៖** អត់ទេ។ ខ្ញុំកៀបទូកៗ រួច តាលីៗហ្នឹងកៀប អែបសាឡង់ឡើងហ្នង។ ខ្ញុំអត់ឡើងលើគោកអីបាន។

**ស៖** បាទ លោកអាចបញ្ជាក់បានទេ ថាមានទូកអ្នកណាខ្លះទេ ដែលនៅជុំវិញសាឡង់ហ្នឹង?

**ឆ៖** បាទ ខ្ញុំឃើញទូកច្រើនណាស់ មិនដឹងទូកណាៗ ខ្ញុំចំណាំមិនបាន។ មិនដឹងទូកណាៗ ទូកច្រើន។

**ស៖** លោកអាចបញ្ជាក់ពីតាំងជាក់លាក់បានទេថា កន្លែងណាដែលជាកន្លែងដែលលោកឡើងលើសាឡង់ហ្នឹង នៅទន្លេបួនមុខហ្នឹង ទីតាំងជាក់លាក់ លោកអាចប្រាប់បានទេ?

**ឆ៖** ខ្ញុំចំណាំបាន បានខ្ញុំមិនដឹងគេហៅហ្នឹងឈ្មោះអីផង អាកោះកណ្តាលហ្នឹង អាទន្លេបួនមុខមានកោះកណ្តាលមួយហ្នឹង គេដឹង គេហៅយ៉ាងម៉េច ខ្ញុំអត់ដឹង។ មិនដឹងគេដាក់ឈ្មោះហ្នឹង ឈ្មោះម៉េចខ្ញុំមិនដឹងទេ រឿងហ្នឹង ដឹងចតនៅចំកណ្តាលកោះហ្នឹងហ្នង។

**ស៖** អ៊ីចឹង តាមអ្វីដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ គឺសាឡង់ហ្នឹង គឺចតនៅលើ នៅជាប់ហ្នឹងកោះ មិនមែនជាប់នៅផ្នែកខាងដីទេ បានន័យថា នៅទល់ខាងមុខព្រះបរមរាជវាំង។ តើអ៊ីចឹងមែនទេ?

[១១:០១:២០]

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកឡើងទៅដល់លើសាឡង់ លោកឃើញមានមនុស្សប៉ុន្មាននាក់នៅក្នុងហ្នឹង?

**ឆ៖** ច្រើនណាស់ ដូចថា ខ្ញុំប្រហែលទេ ប៉ុន្តែតែយើងរាប់មិនបាន យើងប្រហែលថា ហាហុកសិបនាក់ទេ។ ហើយខ្ញុំឡើងភ្លាម ទៅភ្លាមហើយ តែហាហុកសិបនាក់ទេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំចង់បញ្ជាក់អំពីសាឡង់ ឬក៏សាឡាងហ្នឹង។ លោកចាំពីទំហំ ឬក៏ជាប្រវែងបណ្តោយ កម្ពស់ បានទេ?

**ឆ៖** អត់ចាំបានទេ។ អត់ចាំបាន ទទឹងប៉ុន្មាន បណ្តោយប៉ុន្មាន ជម្រៅប៉ុន្មានអត់ អត់ចាំបាន។

**ស៖** លោកអាចប្រហែលបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ប្រហែលសាឡង់ហ្នឹង ដូចសាឡង់ គេដាក់ដីខ្សាច់រាល់ថ្ងៃអ៊ីចឹង ប៉ុន្តែនៅលើស្មើហ្នង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកអាចរៀបរាប់ពីទ្រង់ទ្រាយរបស់វា ថាវាមានជញ្ជាំងបាំងបិទ ឬក៏ជាប្រភេទជាទូកជាសាឡាង ជាទូក គេហៅថា ទូកចម្លង ឬក៏ប្រភេទជាសាឡង់ដែលសម្រាប់ទាញអូសកប៉ាល់ជាដើម?

លោកអាចបញ្ជាក់បានទេ ជាប្រភេទអ្វីដែរ ដែលលោកហៅថា "សាឡង់ ឬក៏សាឡាង" ហ្នឹង?

[១១:០៣:២២]

**ឆ៖** ខ្ញុំបញ្ជាក់នៅក្រោយហ្នឹង មានដំបូលតែមួយកំណាត់ក្រោយទេ ប៉ុន្តែមុខអី អត់មានអី។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** មានសញ្ញាជាអក្សរ ឬក៏ទង់ជាតិអីទេ? ខ្ញុំដឹងថា លោកមិនចេះអក្សរខ្មែរទេ ប៉ុន្តែអាចលោកចាំពីទង់ជាតិ ឬក៏អ្វីដែលជាសញ្ញាសម្រាប់សម្គាល់នៅលើសាឡាងហ្នឹងដែរទេ?

**ឆ៖** អង្កាល់ហ្នឹងខ្ញុំរត់ពីងាប់ ខ្ញុំអត់ដាក់ចិត្តទៅចំណាំទង់ជ័យ ហើយចំណាំរឿងអក្សរទេ។ ខ្ញុំអត់បានទុកចិត្តអាហ្នឹង។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកទៅដល់អ្នកលឿង លោកថា គេបានឲ្យចេញពីសាឡង់ហ្នឹង ហើយក៏មានការជញ្ជូនអំបិល និងអង្ករ ជាការផ្ទេរៗសាឡាង បានន័យថា ផ្ទេរអីវ៉ាន់។ លោកដឹងពីចំនួន ឬក៏ជាទម្ងន់សរុប អាចប្រហាក់ប្រហែលនូវទម្ងន់ជាអំបិល ឬជាអង្ករហ្នឹង ចំនួនប៉ុនណាបានទេ នៅពេលហ្នឹង?

**ឆ៖** ខ្ញុំចំណាំមិនបានទេ ពីព្រោះខ្ញុំចំណាំមិនបានទេ។ បានជាខ្ញុំ -- ដូចខ្ញុំប្រាប់អ៊ីចឹងដែរថា ខ្ញុំឡើងលើគោក រួចគេរាប់រួចហើយ គេឲ្យចុះសាឡង់ទៅ ដឹងតែទៅអ៊ីចឹងតែម្តង។

[១១:០៥:០៩]

**ស៖** សូមអរគុណ។ លោកមានឃើញមន្ត្រីទាំងពីរសាឡង់ហ្នឹង បានន័យថា ទាំងសាឡង់ខាងវៀតណាម ទាំងសាឡង់ខាងខ្មែរ មានការពិភាក្សាគ្នា ឬក៏កាន់លិខិតស្នាមអីដើម្បីដោះដូរគ្នា ដើម្បីជជែកគ្នាដែរទេ នៅពេលហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់ឃើញទេ។

**ស៖** បាទ សូមអរគុណ។ នៅពេលដែលលោកទៅដល់អ្នកលឿងហ្នឹង តើលោកឃើញមានទូកជនជាតិវៀតណាមដទៃទៀតមកដល់ថ្មីៗទៀតទេ ដើម្បីឡើងទៅលើកប៉ាល់ដែលត្រូវចេញដំណើរពីអ្នកលឿងទៅចូរដុកហ្នឹង?

**ឆ៖** បាទ មានឃើញ។ ប៉ុន្តែខ្ញុំចំណាំ ច្រើនតិច ខ្ញុំមិនចំណាំមិនបាន ប្រហាក់ប្រហែល២០ទូក ៣០ទូកអីហ្នឹង បានមកពីក្រោយខ្ញុំហ្នឹង។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងអ្នកដែលជិះទូកមកជួបលោកនៅកន្លែងសាឡង់នៅអ្នកលឿង

ហ្នឹង ឡើងនៅលើកប៉ាល់ជាមួយលោកដែរ។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** អាហ្នឹងខ្ញុំអត់ឃើញទេ។ ឃើញតែគេជាប់ទូកហ្នឹងកំពុងពិភាក្សាគ្នាហ្នឹង ពិភាក្សាសងខាងហ្នឹង ហើយខ្ញុំឡើងសាឡាង់ហ្នឹង គេបញ្ជូនខ្ញុំទៅចូលដល់ចូវដុកវិញ។

**ស៖** បាទ អរគុណ។ នៅពេលដែលលោកទៅដល់ប្រទេសវៀតណាម លោកអាចបញ្ជាក់បានទេថា លោករស់នៅក្នុងទីតាំងកន្លែងណា ហើយស្ថិតនៅក្រោមការគ្រប់គ្រងយ៉ាងដូចម្តេច?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

[១១:០៧:២៣]

**លោក ជឿង យ៉ាំង ចែត៖**

**ឆ៖** ខ្ញុំនៅ*(ឮមិនច្បាស់)* នៅៗហ្នឹងគេរុញឲ្យខ្ញុំឡើងសាលារៀន*(ឮមិនច្បាស់)*។ ហើយគេចិញ្ចឹមខ្ញុំ៧ថ្ងៃនៅសាលារៀនហ្នឹង គេបាន គេស៊ីញៀសំបុត្រអី គេបានគេបញ្ជូនទៅទឹកជូ ទឹកផឹកមិនបាន ទឹកហ្នឹងគេហៅថាទឹកជូ។ ហើយគេឲ្យនៅហ្នឹង។

**សួរដោយលោក គង់ សំអុន៖**

**ស៖** ការរស់នៅកន្លែងនោះ វាជាការរស់នៅលាយលំជាមួយនឹងពលរដ្ឋវៀតណាមដទៃទៀត ឬក៏ជាជំរំប្រមូលផ្តុំដែលមានអ្នកពីកម្ពុជាទៅ?

**ឆ៖** នៅជំរំវៀតណាម ដាក់ជំរំផ្សេងអ៊ីចឹង អត់មាននៅជាមួយខាងវៀតណាមក្រោមអ៊ីចឹងបានទេ ដាក់ជំរំផ្សេង។

**ស៖** បាទ សូមអរគុណ។ លោកនៅទីនោះរហូតដល់ឆ្នាំ៨២តែម្តង ឬក៏លោកមានការផ្លាស់ប្តូរទីកន្លែងរស់នៅនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំបាទប្រាប់ឲ្យត្រង់ ខ្ញុំអត់មានម៉ែឪម្តាយទេ អត់មានបងប្អូនសាច់ញាតិអីទេ។ ខ្ញុំមានតែម្នាក់ខ្ញុំទេ ហើយខ្ញុំធ្វើការមិនបាន ខ្ញុំទៅឃ្វាលក្របីឲ្យគេទេ។

**ស៖** បាទ សំណួររបស់ខ្ញុំសួរថា តើលោកនៅកន្លែងជំរំដែលគេដាក់ឲ្យលោកនៅម្តុំនោះ រហូតតាំងពីឆ្នាំ៧៥ ដល់ឆ្នាំ៨២នោះ ឬក៏លោកមានការផ្លាស់ប្តូរទីកន្លែងរស់នៅដែរនៅក្នុងចន្លោះពេលហ្នឹង?

**ឆ៖** ខ្ញុំនៅជំរំហ្នឹងមែន ប៉ុន្តែខ្ញុំទៅភូមិគេ ខ្ញុំស៊ីឈ្នួលគេបាត់ហើយ ខ្ញុំអត់នៅជំរំហ្នឹងទៀតទេ ខ្ញុំទៅឃ្វាលក្របីឲ្យគេហើយ ខ្ញុំដឹងទៅឃ្វាលក្របី អត់ដឹងអីទៀតទេ។

[១១:០៩:២៣]

**ស៖** លោកទៅឃ្វាលក្របី លោកត្រឡប់មកស្នាក់នៅក្នុងជំរំនោះវិញទេ ឬមួយក៏លោកមិនចូលក្នុងជំរំនោះវិញទេ?

**ឆ៖** ខ្ញុំទៅឃ្វាលក្របីគេ ឃ្វាលមួយឆ្នាំអ៊ីចឹងតែម្តង នៅផ្ទះគេបណ្តោយ។ មួយឆ្នាំអ៊ីចឹងគេឲ្យ ២០តៅស្រូវ មួយឆ្នាំអ៊ីចឹង២០តៅស្រូវ ខោអាវបីកំប្លេ។ ខ្ញុំដឹងតែប៉ុណ្ណឹងៗទេ ខ្ញុំអត់មានអីទេ។ តែម្នាក់ខ្ញុំ ខ្ញុំនៅជំរំជាមួយគេម៉េចកើត។

**ស៖** បាទ សូមអរគុណ។ លោកមានឃើញ ឬក៏ជួបជនជាតិវៀតណាម ឬក៏អ្នកណាដែលត្រូវគេបញ្ជូនពីកម្ពុជាទៅនៅនឹងជំរំនោះដែរឬទេ ក្នុងចន្លោះពេលដែលលោកនៅក្នុងប្រទេសវៀតណាមហ្នឹង?

**ឆ៖** ខ្ញុំទៅឃ្វាលក្របីឲ្យគេ ខ្ញុំនៅជាមួយគេ ខ្ញុំអត់បានមកទៅណាទេ ខ្ញុំមិនដឹងទេ ប៉ុន្តែឮដូចថា វៀតណាមនៅប្រទេសក្រោមៗហ្នឹង នៅមុនខ្ញុំហ្នឹង គេថា ពួកអ្នែងមកច្រើនណាស់ ប៉ុនគេឲ្យទៅខេត្តនេះមួយ ខេត្តនេះមួយអស់ហើយ គេចែកតាមខេត្តអស់។ ខ្ញុំឮតែប៉ុណ្ណឹង ខ្ញុំបាន ភ្នែក ខ្ញុំអត់ឃើញ។

**ស៖** អ៊ីចឹងតាមអ្វីដែលលោកមានប្រសាសន៍អម្បាញ់មិញនេះ គឺថាមានអ្នកដែលមកពីកម្ពុជាទៅដល់ក្នុងជំរំហ្នឹងមុនលោក។ តើអ៊ីចឹងត្រឹមត្រូវទេ?

[១១:១១:០២]

**ឆ៖** អត់ទេ។ មកមានខ្ញុំទៅមុនគេទាំងអស់ មកហ្នឹង។ គេដាក់ជំរំហ្នឹងមុនគេទាំងអស់ ខ្ញុំមកបានមុនគេហ្នឹង ជំរំហ្នឹង។

**ស៖** បាទ អ៊ីចឹងបានន័យថា លោកទៅដល់ជំរំហ្នឹងមុនគេ ហើយមានអ្នកមកបន្តបន្ទាប់ទៀតពីតាមក្រោយលោក។ តើអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**លោក គង់ សំអុន៖**

បាទសូមអរគុណ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយលោក ជឿង យ៉ាំង ចែត ជាចុងក្រោយនេះ លោកអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទាំងឡាយពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលត្រូវបានចោទ

ប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និងខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលនាំឲ្យលោកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងជំងឺចិត្ត និងជាសមូហភាពពីជនជាប់ចោទ និងស្ថានភាពព្យសនកម្មដែលមានចំពោះលោកជាអាទិ៍ គឺការខូចខាតរាងកាយ សម្ភារៈ ផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ប្រសិនបើលោកមានបំណងថ្លែងរៀបរាប់ដូច្នេះ។ សូមអញ្ជើញ!

[១១:១២:៤០]

**លោក ជឿង យ៉ាំង ចែត៖**

សូមទោសលោកប្រធាន។ រៀបរាប់ និយាយលោកប្រធាននិយាយឲ្យម្តងទៀត ឲ្យខ្ញុំយល់មើល ខ្ញុំស្តាប់មិនទាន់។

**ប្រធានអង្គជំនុំ៖**

លោកមានសិទ្ធិក្នុងនាមឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ គឺលោកអាចថ្លែងរៀបរាប់អំពីស្ថានភាពព្យសនកម្មទាំងឡាយ ដែលលោកបានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបាននាំឲ្យលោកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្ថានភាពព្យសនកម្ម ឬអន្តរាយដែលកើតមានចំពោះលោកនោះ គឺមានជាអាទិ៍ ដូចខូចខាតខាងរាងកាយ ខូចខាតខាងសម្ភារៈ ឬក៏ផ្លូវចិត្ត ហើយជាបច្ច័យ ឬក៏ជាផលវិបាកផ្ទាល់ពីបទឧក្រិដ្ឋដែលជាព្យសនកម្មផ្ទាល់ខ្លួន និងកើតមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ១៧ មេសា ៧៥ ដល់ថ្ងៃទី០៦ ខែមករា ៧៩ ប្រសិនបើលោកមានបំណងថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់លោកនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចធ្វើទៅបាន។

**លោក ជឿង យ៉ាំង ចែត៖**

ដូចរៀបរាប់ជូនលោកប្រធាន ខ្ញុំចង់អ៊ីចេះ។ ដូចសួរគាត់ សុំសួរគាត់ម្តង។ សួរគាត់ ដូចជារឿងខ្ញុំហ្នឹងវេទនា ម៉ែឪខ្ញុំ ជូរចត់ ងាប់ អត់មានបងប្អូន ទៅតែម្នាក់ខ្ញុំ ខ្ញុំវេទនា ហើយខ្ញុំរបួសលើក្បាលខ្ញុំទៀត ខ្ញុំវេទនាដល់យ៉ាង។ ហើយគាត់ បើឧទាហរណ៍ ខាងគាត់ធ្វើអ៊ីចឹង គាត់វេទនាដូចខ្ញុំអ៊ីចឹងទេ? ខ្ញុំសួរប៉ុណ្ណឹងលោកប្រធាន។

[១១:១៤:៣៣]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងមានន័យថាលោក មិនថ្លែងរៀបរាប់ទេ គឺលោកសុំតាំងសំណួរចំពោះជនជាប់ចោទទាំងពីររូប ដែលមានខ្លឹមសារដូចដែលលោកបានរៀបរាប់អម្បាញ់មិញនេះ។ អ៊ីចឹងមែនទេ?

**លោក ជឿង យ៉ាំង ចែត៖**

បាទ ត្រូវអ៊ីចឹងហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ជឿង យ៉ាំង ចែត។ អង្គជំនុំជម្រះសូមជម្រាបលោកថា នៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្តាប់ជនជាប់ចោទទាំងពីររូបដែលឆ្លើយបញ្ជាក់ ដែលខ្លួនគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទៅនឹងសំណួរ ហើយអង្គជំនុំជម្រះក៏បានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់ នៅតែរក្សាជំហររបស់ខ្លួន បន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបលើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ផ្សេងទៀតពីជនជាប់ចោទ ឬពីសហមេធាវីការពារក្តីឲ្យជនជាប់ចោទ។ ហើយនៅក្នុងសវនាការថ្ងៃនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និង/ឬសហមេធាវីការពារក្តីរបស់ជនជាប់ចោទ មានការទទួលខុសត្រូវក្នុងជូនដំណឹងមកអង្គជំនុំជម្រះឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទអាចសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបនឹងសំណួរ ដោយអង្គជំនុំជម្រះ ឬក៏ភាគីពាក់ព័ន្ធ នៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់ជនជាប់ចោទទាំងពីររូបពីការលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។ ដូច្នេះការប្រកាន់ជំហរនៅស្ងៀមមិនឆ្លើយតបនេះ អង្គជំនុំជម្រះមិនមានលទ្ធភាពក្នុងការបង្ខំឲ្យគាត់ឆ្លើយតបនឹងសំណួររបស់លោកទេ។ នេះតាមច្បាប់នៅ អ.វ.ត.ក. ក៏ដូចជាច្បាប់ជាតិ និងច្បាប់អន្តរជាតិដែរ។

អង្គជំនុំជម្រះអរគុណលោក ជឿង យ៉ាំង ចែត។ យ៉ាងម៉េចទៅ?

[១១:១៦:៤២]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំពិភាក្សាជាមួយមេធាវី លីម៉ា ង្វៀន មើលទៅហាក់ដូចជា

លោកដើមបណ្តឹងរដ្ឋប្បវេណីមិនបានយល់អំពីសិទ្ធិ ដែលលោកប្រធានអនុញ្ញាតឲ្យគាត់និយាយអំពីព្យសនកម្ម ឬក៏មិនបានយល់អំពីអ្វីដែលលោកប្រធានបានផ្តល់ឱកាសឲ្យគាត់និយាយ។ ហើយលោកស្រី លីម៉ា ង្វៀន ចង់ស្នើសុំលោកប្រធានអនុញ្ញាតផ្តល់ឱកាលឲ្យគាត់និយាយអំពីព្យសនកម្មនេះម្តងទៀត។ ក៏ប៉ុន្តែមុននឹងអនុញ្ញាតឲ្យគាត់និយាយអំពីព្យសនកម្ម កញ្ញា លីម៉ា ង្វៀន ចង់សុំរយៈបីនាទី ដើម្បីជជែកជាមួយកូនក្តី ដើម្បីឲ្យគាត់យល់អំពីកម្មវត្ថុនេះឲ្យបានច្បាស់លាស់។ ហើយខ្ញុំគិតថានេះបញ្ហាសំខាន់ ហើយជាពេលចុងក្រោយដែលគាត់មានឱកាសចូលនៅក្នុងសវនាការនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ។ អង្គជំនុំជម្រះសួរបញ្ជាក់ច្បាស់លាស់ហើយ។ បើលោកចង់ណែនាំកូនក្តីរបស់លោក គឺណែនាំមុនពេលដំណើរការសវនាការ។ យើងបានសួរពីរដងហើយ។

អង្គជំនុំជម្រះអរគុណលោក ជឿង យ៉ាំង ចែត។ សវនាការស្តាប់សក្ខីកម្ម និងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដែលលោកបានដាក់ពាក្យសុំតាំងជាដើមបណ្តឹងរដ្ឋប្បវេណីនោះ បានដល់ទីបញ្ចប់ហើយ។ សក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក. នេះលែងមានភាពចាំបាច់ទៀតហើយ។ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ និងបានសេចក្តីសុខសេចក្តីចម្រើន។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូន ជឿង យ៉ាំង ចែត វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយតទៅទៀតនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-945។ ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការកោះអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-945 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១១:២១:០៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី! តើលោកឈ្មោះអ្វី? កុំអាលទាន់ឆ្លើយតបលោកសាក្សី! លោករង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ ដោយឲ្យសញ្ញាភ្លើងក្រហម នោះទើបប្រព័ន្ធដំណើរការនៃការសំឡេងរបស់លោកចែកចាយទៅភាគីពាក់ព័ន្ធ ជាពិសេសទៅដល់អ្នកបកប្រែភាសា បកប្រែភាសាសម្ដីរបស់លោកហ្នឹងជាបីភាសា -- ជាពីរភាសាទៀត គឺអង់គ្លេស ហើយនិងភាសាបារាំង។ តើលោកឈ្មោះអី សាក្សី?

**លោក ព្រុំ សារុន៖**

**ឆ៖** បាទ ឈ្មោះ ព្រុំ សារុន។

**ស៖** អរគុណលោក ព្រុំ សារុន។ តើលោកចងចាំទៀតថា លោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ឆ្នាំមមែ ខែចេត្រ ថ្ងៃអង្គារ។

**ស៖** លោក ត្រូវជាឆ្នាំបារាំង ឆ្នាំណាដែរ មួយពាន់ប្រាំបួនរយប៉ុន្មានដែរ? លោកឆ្លើយបានទេ តើលោកកើតនៅឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មាន?

**ឆ៖** ៥៥។

[១១:២២:៤២]

**ស៖** ១៩៥៥ ឬក៏ ១៩៤២? អង្គាល់ពីនៅក្នុងសារតារនៃការស៊ើបអង្កេត លោកបានឆ្លើយថា លោកកើតនៅខែមករា ឆ្នាំ១៩៤២?

**ឆ៖** ៤២។

**ស៖** ហើយជាក់ស្ដែង ឥឡូវឆ្នាំនេះ លោកអាយុប៉ុន្មានហើយ?

**ឆ៖** ៧៤ឆ្នាំ។

**ស៖** បាទ អរគុណ។ ហើយលោក ព្រុំ សារុន ទីកន្លែងកំណើតរបស់លោក លោកកើតនៅទីកន្លែងណា?

**ឆ៖** នៅភូមិក្រពើខាងជើង ឃុំភ្នំសំពៅ ស្រុកបាណន់។

**ស៖** ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** នៅភូមិក្រពើខាងជើងដដែល ស្រុកកំណើតខ្ញុំ។ បច្ចុប្បន្ននៅហ្នឹងឯង។

**ស៖** ហើយលោកប្រកបមុខរបរអ្វី សព្វថ្ងៃនេះ?

ឆ៖ ធ្វើស្រែ។

ស៖ បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះ? ម្ដាយបង្កើតរបស់លោកឈ្មោះអ្វី?

ឆ៖ ប្អូរ ព្រុំ, ស៊ិន ភួង ម្ដាយ។

ស៖ ចុះប្រពន្ធរបស់លោកឈ្មោះអ្វី? ហើយលោកមានកូនប៉ុន្មាននាក់?

ឆ៖ មានប្រាំពីរនាក់។

ស៖ ប្រពន្ធរបស់លោកឈ្មោះអ្វី?

[១១:២៤:៥៧]

ឆ៖ ឈ្មោះ មីបងឈ្មោះ សុខា--

ស៖ ប្រពន្ធៗរបស់លោកឈ្មោះអ្វី?

ឆ៖ ញ៉ែម នឿម។

ស៖ លោក ព្រុំ សារុន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ទេ។ ហើយក៏មិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងក្ដីនេះដែរ។ តើពិតមែនដែរទេ?

ឆ៖ ខ្ញុំមិនដែលទាក់ទងស្គាល់ទេ។ មិនដែលស្គាល់ វាល់ដែលគ្នាផង។

ស៖ មិនមែនស្គាល់ មួយប៉ុន្តែញាតិលោហិត បានន័យថាមានញាតិលោហិតអីមានការពាក់ព័ន្ធនឹងរឿងក្ដីតាមនៅសាលាក្ដីនេះដែរទេ?

ឆ៖ អត់មានពាក់ព័ន្ធអីទេ។

ស៖ តើលោកបានធ្វើសម្បថនៅមុនចូលមកកាន់កន្លែងផ្ដល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

ឆ៖ បានស្បថហើយម្សិលមិញ។

[១១:២៦:៤១]

ស៖ បាទអរគុណលោក ព្រុំ សារុន។ ជាបន្តទៅនេះយើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចចំពោះលោកក្នុងឋានៈលោកជាសាក្សីនៅចំពោះអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោក ព្រុំ សារុន ក្នុងឋានៈលោកជា

សាក្សីនៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ចលោក ព្រុំ សារុន ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះលោកត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចមកហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈជាសាក្សីត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬមានធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏ធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក ព្រុំ សារុន តើលោកធ្លាប់ផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ ក្នុងរយៈពេលកន្លងមក? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា នៅពេលណា?

[១១:២៨:១៣]

**ផៈ** យូរដែរហើយ។ ធ្លាប់ធ្វើម្តងដែរនៅភូមិខ្ញុំ ស៊ើបអង្កេតអំពីខ្ញុំដឹងថា តាដោក ហើយនិងកូនគាត់ហ្នឹងគេវ៉ៃចោលក្នុងឃុំភ្នំសំពៅ ព្រោះគេហៅមកប្រជុំ។

**សៈ** បាទ អរគុណ។ ហើយលោកចាំទេថា ការធ្វើហ្នឹងធ្វើនៅពេលណាដែរ?

**ផៈ** ឆ្នាំរំដោះបាន ឆ្នាំអីទេ។

**សៈ** អង្កាល់ធ្វើសម្ភាស តើលោកធ្វើសម្ភាស តើធ្វើឆ្នាំណា ប្អូនប្រាំឆ្នាំកន្លងមកនៅ ឬដូចឆ្នាំមួយពាន់ប្រាំ -- ឆ្នាំ២០០០ ឬក៏ឆ្នាំណា? លោកចាំទេ? ចាំទេ?

**ផៈ** ភ្លេចអស់ហើយ។

**សៈ** បាទ មិនចាំក៏មិនអីដែរ។ ហើយនៅមុនពេលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យមើល ឬបានអាន ឬក៏ស្តាប់ការអានឲ្យស្តាប់នូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុននៅនឹងភូមិកំណើតរបស់លោក ឬក៏កន្លែងដែលលោករស់នៅសព្វថ្ងៃនេះរបស់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ភ្លេចអស់ហើយ យូរណាស់ហើយដែលហើយ។

**ស៖** លោកចេះអក្សរទេ? លោកចេះអក្សរទេ?

**ឆ៖** ចេះអក្សរ តែមើលមិនដាច់ទេឥឡូវហ្នឹង វង្វេងអស់ហើយ។

[១១:៣០:១៥]

**ស៖** ហើយលោកបាន ត្រូវគេអានកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុននោះ នៅនឹងផ្ទះរបស់លោកហ្នឹងឲ្យលោកស្តាប់ទេកាលពីម្សិលមិញ ឬក៏កាលពីមុនចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ? តើលោកធ្លាប់បានគេអានឯកសារហ្នឹងឲ្យស្តាប់ឡើងវិញទេ?

**ឆ៖** ប្រពន្ធខ្ញុំអាន ប៉ុន្តែវាភ្លេចអស់បាត់ហើយ មិនចាំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗ លោក ព្រុំ សារុន។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ ហើយអង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងមួយកន្លះ រសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូង

ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ព្រុំ សារុន មុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញា រួមនិងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ ក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

**កញ្ញា សុង ឆវ័ន្ត៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ សុង ឆវ័ន្ត ជាតំណាងសហព្រះរាជអាជ្ញាជាតិ ហើយនៅរសៀលនេះ ខ្ញុំមានសំណួរមួយចំនួន ដើម្បីសាកសួរទៅលោក។ លោកសាក្សី ខ្ញុំចង់ចាប់ផ្តើមសំណួរទាក់ទងទៅនឹងថ្ងៃ១៧ មេសា ១៩៧៥។ តើលោកនៅថ្ងៃទី១៧ មេសា ១៩៧៥ហ្នឹង លោករស់នៅទីណា ហើយធ្វើអ្វីដែរនៅពេលនោះ?

[១៣:៣៣:២៨]

**លោក ព្រុំ សារុន៖**

**ឆ៖** នៅឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង។

**ស៖** លោកធ្វើការអ្វីដែរនៅពេលនោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយសាក្សី!

**លោក ព្រុំ សារុន៖**

**ឆ៖** ខ្ញុំធ្វើមេកងតូច ពេលនោះ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចុះភូមិភ្នំសំពៅ ស្រុកបាណន់ នៅពេលដែលលោករស់នៅក្នុងឆ្នាំ១៩៧៥ហ្នឹង លោកចាំបានទេថា ស្ថិតនៅក្នុងតំបន់ ឬក៏ភូមិភាគណាដែរ?

**ឆ៖** ក្នុងតំបន់៣។ ពេលនោះគេហៅតំបន់៣។

**ស៖** ស្ថិតក្នុងភូមិភាគណាដែរ លោកនៅចាំបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់ឆ្លើយ សាក្សី! ឆ្លើយ!

[១៣:៣៥:១០]

**លោក ព្រុំ សារុន៖**

**ឆ៖** ស្ថិតនៅភូមិភាគពាយ័ព្យ។ ភូមិពាយ័ព្យ។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** ចាស អរគុណ។ មុននេះលោកប្រាប់ថា ក្រោយ១៧ មេសា ១៩៧៥ហ្នឹង លោកត្រូវបានគេចាត់តាំងឲ្យធ្វើមេកងតូច។ ខ្ញុំចង់សួរលោកបញ្ជាក់ថា លោកនៅចាំបានទេថា មេកងតូចហ្នឹង ស្ថិតនៅក្នុងកង ឬស្ថិតនៅក្នុងវរៈ ឬក៏កងពលណាដែរ សូមលោកជួយបញ្ជាក់កន្លែងនេះផង?

**ឆ៖** មេកងតូចលេខ១ នៅភូមិក្រពើជើង ឃុំភ្នំសំពៅដដែល។ គេតែងតាំងឲ្យធ្វើមេកងតូចគ្រាន់តែក្តោបក្តាប់គេធ្វើការងារ។

**ស៖** ចុះលោកនៅចាំបានទេថា ប្រធានរបស់លោកឈ្មោះអ្វីដែរ? ហើយគាត់មានឋានៈអ្វីដែរ?

**ឆ៖** ឈ្មោះ តាហុង មេកងធំ នៅនឹងភូមិក្រពើជើងហ្នឹងដែរ។

**ស៖** តើ តាហុង ដែលជាមេកងធំហ្នឹង លោកនៅចាំបានទេថា គាត់មេកងធំលេខប៉ុន្មាន?

**ឆ៖** កងធំលេខ១។

[១៣:៣៧:៤០]

**ស៖** លោកសាក្សី ខ្ញុំចង់សួរបញ្ជាក់លោកបន្តិច ដោយសារមានចម្លើយដែលលោកបានឆ្លើយពីមុន ជាមួយនឹងអ្នកស៊ើបអង្កេតហ្នឹង មានបញ្ហាមិនសូវស្របគ្នា។ នៅពេលដែលលោកឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេត តាមចម្លើយរបស់លោកនៅឯកសារE3/5178 នៅ ERN ជាភាសាខ្មែរគឺ 00197916, ERN ជាភាសាអង់គ្លេសគឺ 00274177 និងជាភាសាបារាំង 00274184។ ពេលដែលអ្នកសម្ភាសពេលដែលអ្នកស៊ើបអង្កេតរបស់ការិយាល័យចៅក្រមស៊ើបអង្កេត ចុះទៅសួរលោកដល់ភូមិរបស់លោកពេលនោះ លោកបានឆ្លើយថា លោកនៅក្នុងកងវរៈលេខ១។ កងធំលេខ៤ដែលប្រធានកងឈ្មោះ តាហុង។ អ៊ីចឹង ពីមុនដែលលោកឆ្លើយថា លោកបាននៅក្នុងកងវរៈលេខ១ កងធំលេខ៤ហ្នឹង ហើយឥឡូវហ្នឹងវាមានភាពខុសគ្នាយ៉ាងម៉េច? សូមលោករំឭកឡើងវិញមើលថា ពេលនោះលោកនៅក្នុងកងលេខប៉ុន្មាន? ហើយកងវរៈលេខប៉ុន្មាន បើលោកនៅចាំ?

**ឆ៖** កងធំលេខ៤ វរៈ១។

**ស៖** ចាស អរគុណ។ ចុះលោកនៅចាំបានទេថា នៅក្នុងកងវរៈលេខ១ ដែលគេចាត់តាំងឱ្យលោកធ្វើការនោះ ជាកងរបស់ថ្នាក់តំបន់ ឬក៏ថ្នាក់ភូមិភាគ ឬក៏ថ្នាក់ស្រុកដែរ ពេលនោះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់ឆ្លើយ! សូមអញ្ជើញឆ្លើយ!

**លោក ព្រុំ សារុន៖**

**ឆ៖** ថ្នាក់ស្រុក គ្មានតំបន់ទេ។

[១៣:៤០:០០]

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** មុននេះលោក មេកងពលលេខ៤ ឈ្មោះ តាហុង។ ចុះលោកនៅចាំបានទេថា មេវរៈលេខ១ហ្នឹង ឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ តាក្រច។

**ស៖** ចាស សូមអរគុណ។ លោកសាក្សី ឥឡូវនេះខ្ញុំចូលដល់ប្រធានបទថ្មីមួយទៀត ដែលនិយាយពាក់ព័ន្ធទៅនឹងរឿងហេតុ ដែលបានកើតឡើងនៅក្នុងតំបន់របស់លោកពាក់ព័ន្ធនឹងជនជាតិវៀតណាម។ ខ្ញុំចង់ឱ្យលោកប្រាប់ទៅអង្គសវនាការថា មានអ្វីបានកើតឡើងចំពោះជនជាតិវៀតណាមនៅក្នុងកងវរៈលេខ១ របស់លោក ឬក៏នៅក្នុងកងផ្សេងទៀតក្នុងតំបន់ ដែលលោកបានដឹង បានចងចាំ?

**ឆ៖** បាទ បើមានជនជាតិវៀតណាម គេវៃចោលនៅទួលតាត្រង់។ ខ្ញុំបាទចាំបានប៉ុណ្ណឹង។ គេបញ្ជូនទៅវៃចោលនៅទួលតាត្រង់ ជិតភ្នំកុយ។

**ស៖** ចាស អរគុណ។ ខ្ញុំនឹងសួរលម្អិតលើបញ្ហានេះទៀត។ ប៉ុន្តែចង់សួរលោកបញ្ជាក់បន្តិច តើប្រធានវរៈរបស់លោកដែលឈ្មោះ តាក្រច ហ្នឹងគាត់មានដែលធ្លាប់បានណែនាំ ឬក៏សួរនាំអំពីការកំណត់អត្តសញ្ញាណជនជាតិវៀតណាមនៅក្នុងវរៈរបស់លោក ឬក៏ដឹងអំពីការកំណត់អត្តសញ្ញាណរបស់ជនជាតិវៀតណាមនៅក្នុងវរៈផ្សេងទៀតដែលលោកបានដឹងទេ?

**ឆ៖** មានវរៈផ្សេង។ វរៈខ្ញុំអត់មានអ្នកណាវៃចោលទេ។ វរៈផ្សេង វរៈ២ វៃវៀតណាមចោលនៅទួលតាត្រង់។

**ស៖** អឺចេះទេ លោកសាក្សី ខ្ញុំចង់ជម្រាបសួរលោក តើប្រធានវរៈលេខ១ ដែលឈ្មោះ តាក្រច

ហ្នឹង គាត់មានធ្លាប់បានសួរនាំ ឬក៏ដេញដោលរឿងថាតើនៅក្នុងកងរបស់លោក ក្នុងកងពលរបស់លោក តាមដែលលោកដឹងហ្នឹងមានជនជាតិវៀតណាមអត់ទេ គាត់មានដែលសួរលោកអ៊ីចឹងទេ?

**ឆ៖** អត់ទេ មិនដែលសួរទេ។ បើវរៈ២ បានគេសួរ។ តាក្រច មិនដែលសួរទេ ព្រោះកងខ្ញុំអត់មានយួននៅ។

**ស៖** ចុះកងណាដែល -- លោកថាកងរបស់លោកអត់មានយួននៅ ចុះមានកងណាផ្សេងទេ?

**ឆ៖** វរៈ២ ដែលយួននៅច្រើន។ វរៈខ្ញុំអត់មាននៅទេ មានតែចិន។

**ស៖** ចាស អរគុណ។ លោកសាក្សី នៅត្រង់ឯកសារដដែល ដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេត នៅពេលដែលគេចុះទៅសួរលោកដល់ភូមិរបស់លោក គឺត្រង់ឯកសារ E3/5178 នៅ ERN ដដែលដែលខ្ញុំបានអានកាលពីមុននេះបន្តិច។ លោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេត ដែលទៅសម្ភាសលោកហ្នឹង លោកបានឆ្លើយថា៖ “នៅឆ្នាំ១៩៧៦ ពួកខ្មែរក្រហមបានសួររកជនជាតិយួន។ ក្រច ដែលជាប្រធានវរៈលេខ១ បានសួរខ្ញុំថា តើក្នុងកងរបស់មិត្តមានពួកយួនដែរឬទេ? បើមានសូមរាយ-ការណ៍ ដើម្បីឲ្យគេបញ្ជូនទៅថ្នាក់លើដើម្បីចាត់ការ។” ខ្ញុំចង់សួរបញ្ជាក់លោក លោកសាក្សី តើពេលនោះ នៅពេលដែល ក្រច និយាយថាមាន -- មកសួរលោកថា នៅក្នុងកងរបស់លោកមានជនជាតិយួនដែរឬទេហ្នឹង លោកចាំទេ ថាពេលហ្នឹងគាត់សួរលោកនៅកន្លែងណា? ហើយសួរនៅពេលណាដែរ?

**ឆ៖** សួរនៅក្នុងវរៈហ្នឹងឯង កន្លែងបុកកិនស្រូវ។ ថាមិនមានយួនទេ ខ្ញុំឆ្លើយថាអ៊ីចឹង។ កងខ្ញុំមានតែចិន។

[១៣:៤៥:៣២]

**ស៖** នៅពេលដែលគាត់សួរលោកនៅក្នុងកងវរៈហ្នឹង តើមានអ្នកណាផ្សេងនៅកន្លែងហ្នឹងដែរទេ? ហើយពេលហ្នឹងគាត់សួរលោកនៅក្នុងអង្គប្រជុំ ឬក៏ដើរទៅជួបកន្លែងណា ឬក៏សួរក្នុងស្ថានភាពណាដែរ? សូមលោកជួយបញ្ជាក់ផង។

**ឆ៖** សួរខ្ញុំតែម្នាក់ ដើរមកសួរខ្ញុំតែម្នាក់ឯង។ ខ្ញុំរាយការណ៍ប្រាប់ថាអ៊ីចឹងឯង ថាកងខ្ញុំមិនមានយួនទេ មានតែចិន។

**ឆ៖** ចាស អរគុណ។ ចុះនៅពេលដែលប្រធានវរៈឈ្មោះ ក្រច និយាយថា “បើមានជនជាតិវៀតណាម សូមរាយការណ៍ដើម្បីបញ្ជូនទៅថ្នាក់លើ”។ តើពេលនោះ ក្រច មានបានប្រាប់លោកទេថា តើអ្នកណាជាថ្នាក់លើ?

**ឆ៖** ថ្នាក់លើមានតែប្រធានវរៈហ្នឹងឯង ថ្នាក់លើគេហើយ។

**ស៖** ចុះមុននេះ ក្រែងលោកនិយាយថា ក្រច ហ្នឹងជាប្រធានវរៈ?

**ឆ៖** គឺប្រធានវរៈហ្នឹង ទៅថ្នាក់លើមានតែអណ្ដូងព្រីងហ្នឹង ថ្នាក់លើគេ បញ្ជូនទៅ តាឆាំ ទៅ។

**ស៖** សូមលោកបញ្ជាក់ឱ្យបានច្បាស់ជាងនេះបន្តិចបានទេថា ថ្នាក់លើហ្នឹងបញ្ជូនទៅណា? ហើយអ្នកណាឈ្មោះអី?

**ឆ៖** ថ្នាក់លើមានតែ តាឆាំ ហ្នឹងចៅហ្វាយស្រុកនោះ គណៈស្រុកគេនោះ។

[១៣:៤៨:១១]

**ស៖** ចាស អរគុណ។ នៅក្នុងពាក្យពេចន៍របស់ តាក្រច ហ្នឹងដដែល គាត់និយាយថា “បញ្ជូនទៅថ្នាក់លើដើម្បីចាត់ការ”។ តើពាក្យថា “ចាត់ការ” ហ្នឹងមានន័យថាម៉េចដែរ?

**ឆ៖** “ចាត់ការទៅ” សម្លាប់ មានតែ “សម្លាប់” ហ្នឹង។ ចាត់ការហ្នឹង ពាក្យ “ចាត់ការ” ហ្នឹង។

**ស៖** ចាស សូមអរគុណ។ ចុះនៅពេលដែល តាក្រច មកនិយាយជាមួយលោកនៅក្នុងកងវរៈសួរនាំរឿង មានយួននៅក្នុងកងរបស់លោកហ្នឹង តើពេលនោះគាត់មានសួរលោកថា ត្រូវធ្វើម៉េចដើម្បីកំណត់អត្តសញ្ញាណ ឬក៏ប្រាប់លោកត្រូវកំណត់អត្តសញ្ញាណអត់ទេ មុននឹងលោកឆ្លើយសំណួររបស់គាត់ថា អត់មានយួននៅក្នុងកងរបស់លោក?

**ឆ៖** មានតែ តាក្រច ក៏មិនសួរអីច្បាស់ណា សួរថា អត់យួនទេ មិនមានទេយួន មានតែចិន កងខ្ញុំមានតែខ្ញុំ។ ប៉ុណ្ណឹងគាត់ដើរទៅបាត់ទៅ ដែលសួរអីយើងច្រើន។

[១៣:៤៩:៥៦]

**ស៖** ចាស អរគុណ។ មុននេះលោកនិយាយថា នៅក្នុងកងវរៈរបស់លោក អត់មានយួនទេ ប៉ុន្តែនៅក្នុងកងកងវរៈលេខ២មាន។ លោកដឹងទេថា សមាជិកកងវរៈលេខ២ហ្នឹងមកពីភូមិ ឬក៏ឃុំណាដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ សាក្សី!

**លោកព្រុំ សារុន៖**

**ឆ៖** លេខ១ លេខ២ហ្នឹងនៅជាប់គ្នាហ្នឹង បន្តគ្នាហ្នឹង មួយភូមិហ្នឹង មានលេខ១ លេខ២។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** លោកនៅចាំឈ្មោះភូមិឃុំទេ?

**ឆ៖** ភូមិក្រពើខាងជើងនោះ វាមានពីរវរៈ វរៈលេខ១ លេខ២។

[១៣:៥១:១០]

**ស៖** ចុះមានវរៈផ្សេងទៀតទេ ឧទាហរណ៍លេខ៣ លេខ៤ អីអ៊ីចឹង?

**ឆ៖** ត្បូងភ្នំមានពីរវរៈទៀត វរៈលេខ១ លេខ២ អ៊ីចឹងដែរ។ អស់ត្រឹមហ្នឹងហើយ ប៉ុនមិនដឹងរបស់គេទេ ខ្ញុំមិនដឹងទេ។ ខ្ញុំក្ដាប់បានតែវរៈខ្ញុំ។

**ស៖** ចាស អរគុណ។ ក្រោយពី តាក្រច ដែលជាប្រធានកងវរៈលេខ១ បានសួរនាំលោកថា នៅក្នុងកងរបស់លោកហ្នឹងមានជនជាតិវៀតណាមអត់ហ្នឹង ក្រោយពីហ្នឹងមក តើលោកមានធ្លាប់បានឃើញមានការចាប់ខ្លួនជនជាតិវៀតណាមនៅក្នុងកងរបស់លោក ឬក៏នៅក្នុងកងវរៈផ្សេងទៀតដែរឬទេនៅក្នុងតំបន់?

**ឆ៖** វរៈ២មានយួនគេចាប់ៗបញ្ជូនទៅថ្នាក់លើ មិនដឹងថ្នាក់លើគេណា ស្រាប់តែទៅបាត់ទៅ។

**ស៖** មានការចាប់ខ្លួននៅក្នុងកងវរៈ២ តើលោកដឹងទេ ថាការចាប់ខ្លួនហ្នឹងមានប៉ុន្មាននាក់?

**ឆ៖** មានពីរនាក់ ចាប់ខ្លួន។ គេយកទៅបាត់ទៅ មិនដឹងទៅណា។

**ស៖** លោកសាក្សី នៅក្នុងចម្លើយរបស់លោកជាមួយនឹងអ្នកស៊ើបអង្កេតដែលលោកបានឆ្លើយកាលដែលគេទៅសម្ភាសលោកទៅដល់ភូមិរបស់លោកហ្នឹង គឺនៅត្រង់ឯកសារ និង ERN ដដែលហ្នឹងលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតថា៖ "ក្រច ដែលជាប្រធានវរៈលេខ១ បានមកសួរខ្ញុំថា តើនៅក្នុងកងរបស់មិត្តមានយួនដែរឬទេ? បើមានសូមរាយការណ៍ ដើម្បីបញ្ជូនទៅថ្នាក់លើចាត់ការ។ ក្នុងកងវរៈខ្ញុំគ្មានយួនទេ ប៉ុន្តែក្នុងកងវរៈលេខ២ មានយួនប្រហែល២០នាក់។ ខ្ញុំបានឃើញគេចាប់យួនចងស្លាបសេករួចបណ្ដើរទៅសម្លាប់ចោលនៅទួលតាត្រង់ នៅជិតភ្នំកុយ។" លោកសាក្សី មុននេះលោកបានឆ្លើយថាលោកបានឃើញគេចាប់យួននៅក្នុងកងវរៈលេខ២ ពីរនាក់ ប៉ុន្តែចម្លើយដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុ នៅពេលដែលគេទៅសម្ភាសលោកដល់ភូមិរបស់លោកហ្នឹង លោកឆ្លើយថា ប្រហែល២០នាក់។ អ៊ីចឹងខ្ញុំចង់ឲ្យលោករំឭកការចងចាំរបស់លោកឡើយងវិញថា ពេលនោះលោកបានឃើញគេចាប់យួននៅក្នុងកងវរៈលេខ២ប៉ុន្មាននាក់ ឲ្យពិតប្រាកដ?

[១៣:៥៥:០០]

**ឆ៖** វាយូរមកហើយដែរ វាយូរហើយ ភ្លេចអស់ហើយ។

**ស៖** មិនអីទេលោកសាក្សី ខ្ញុំនឹងព្យាយាមត្រឡប់មកសួរសំណួរនេះម្ដងទៀត។ នៅពេលដែល

លោកឃើញគេចាប់ជនជាតិវៀតណាមចេញទៅហ្នឹង តើលោកឃើញនៅកន្លែងណាដែរ?

ឆ៖ វរៈជាប់គ្នាហ្នឹង ឃើញគេចាប់ទៅទួលតាត្រង់ ជិតភ្នំកុយ ខាងលិចភូមិខ្ញុំ ឆ្ងាយបន្តិច។

ស៖ ចាស ខ្ញុំចង់សួរលោកបញ្ជាក់កន្លែងនេះបន្តិចសិន។ តើនៅពេលដែលលោកឃើញគេចាប់មនុស្សហ្នឹង លោកឃើញគេចាប់ដំបូងឡើង ឃើញនៅកន្លែងណា?

ឆ៖ ចាប់ក្នុងភូមិនោះឯង វរៈ២ ចាប់ក្នុងភូមិវរៈ២ហ្នឹង។

ស៖ ចាស អរគុណ។ តើលោកដឹងទេថាអ្នកណាជាអ្នកចាប់ជនជាតិវៀតណាមទាំងអស់នោះ?

ឆ៖ កូនកម្មាភិបាលក្មេងៗ មិនស្គាល់វាទេ។

ស៖ តើលោកចាំបានទេថាកូនកម្មាភិបាលក្មេងហ្នឹងចុះមកចាប់ហ្នឹង មកគ្នាប៉ុន្មាននាក់?

ឆ៖ បួននាក់ហ្នឹងអី ចាប់ទៅ មាននរណាហ៊ានធ្វើអីវា។

ស៖ សូមលោកជួយរៀបរាប់បន្តិចមើល ថានៅពេលដែលឃើញគេចុះមកចាប់ហ្នឹង តើសកម្មភាពហ្នឹង គេធ្វើយ៉ាងម៉េចដែរ? ហើយគេចាប់ហ្នឹងយកទៅដាក់នៅកន្លែងណា?

[១៣:៥៨:០៨]

ឆ៖ ឃើញគេចាប់បណ្ដើរយកទៅលិចទៅ មានទីកន្លែងគេពិឃាតនឹងទួលតាត្រង់ហ្នឹងឯង។ ក្បាលគរដូចដំបូក។

ស៖ តើពេលដែលកូនកម្មាភិបាលខ្ពស់ៗដែលចុះមកចាប់ហ្នឹង មានអាវុធមកជាមួយដែរឬទេ?

ឆ៖ មាន។ កាំភ្លើងស្ពាយអូសដីហ្នឹង ប៉ុនៗនេះ។

ស៖ ចុះអ្នកដែលត្រូវក្មេងកម្មាភិបាលហ្នឹងចាប់ហ្នឹង គេមានចង ឬក៏ឲ្យដើរធម្មតាទៅ?

ឆ៖ ចងក្រពាត់ដៃស្លាបសេក។ គេចាប់ គេចងហើយ។

ស៖ ចងមួយៗដាច់ពីគ្នា ឬក៏ចងយ៉ាចម៉េចដែរ ជាប់គ្នា?

ឆ៖ ចងមួយៗ មិនមែនចងជាប់គ្នាទេ។ ម្នាក់បណ្ដើរពីរទៅ។

ស៖ លោកចាំបានទេថា ពេលហ្នឹងគេយកអីមកចងស្លាបសេកពួកគាត់?

ឆ៖ កន្សែង។ ចងនឹងកន្សែងបណ្ដើរទៅ។

ស៖ ពេលដែលបណ្ដើរចេញទៅហ្នឹង លោកថាបណ្ដើរទៅទិសខាងលិច។ ហើយលោកដឹងទេថាគេយកទៅទុក ឬក៏ទៅកន្លែងណាដែរ?

ឆ៖ ឃើញតែក្បាលនៅទួលតាត្រង់ យកទៅកន្លែងហ្នឹងឯង។ ផ្ទាក់លើគេហើយនៅហ្នឹង។

**ស៖** លោកដឹងទេថា ទួលតាត្រង់ដែលលោកនិយាយថានៅជិតភ្នំកុយហ្នឹងមានទីតាំងស្ថិតនៅក្នុងភូមិ ឃុំ ហើយស្រុកណាដែរ?

[១៤:០១:២៣]

**ឆ៖** ឃុំខ្ញុំហ្នឹងឯង ខាងលិចវរៈហ្នឹង ហ្នឹងហើយទួលតាត្រង់ខាងភ្នំកុយ។

**ស៖** អ៊ីចឹងចង់សួរលោកបញ្ជាក់ថា ទួលតាត្រង់ហ្នឹងគឺស្ថិតនៅក្នុងភូមិ ឃុំ ដែលវរៈរបស់លោកស្ថិតនៅដដែលហ្នឹង?

**ឆ៖** គេជូនថាបាន៣គីឡូហ្នឹងនៅហ្នឹងឯង ពិឃាតនៅហ្នឹងឯង។

**ស៖** លោកសាក្សី ខ្ញុំចង់សួរបញ្ជាក់លោកបន្តិចថា ក្មេងៗដែលចុះមកបណ្ដើរយកជនជាតិវៀតណាមដែលនៅក្នុងវរៈ២ដែលលោកបានរៀបរាប់មុននេះ។ តើលោកដឹងទេថា ក្មេងៗដែលជាកូនកម្មាភិបាលជាន់ខ្ពស់ហ្នឹង គឺជាយោធា គឺជាកងចល័ត ឬក៏ជានរណាដែរ ហើយមកពីខាងណា?

**ឆ៖** កូនយោធានៅច្រមុះភ្នំក្រពើហ្នឹងឯង។ គណៈឃុំ កូនអីហ្នឹង។ តាវ៉ាក់ ហ្នឹងឃុំភ្នំសំពៅនៅនឹងខាងច្រមុះភ្នំក្រពើនោះឯង ជិតថ្នល់ហ្នឹង។

**ស៖** លោកសាក្សីលោកបានប្រាប់ទៅអង្គសវនាការថា អ្នកដែលគេបណ្ដើរយកទៅ ហើយឃើញសាកសពនៅទួលតាត្រង់ហ្នឹង គឺយួននៅក្នុងវរៈលេខ២។ ខ្ញុំចង់សួរលោកថាហេតុអ្វីបានជាលោកដឹងថា អ្នកដែលត្រូវគេបណ្ដើរចេញហើយឃើញសាកសពនៅទួលតាត្រង់ហ្នឹងជាជនជាតិវៀតណាម ឬក៏ជនជាតិយួនហ្នឹងដែលលោកហៅហ្នឹង?

[១៤:០៤:០៨]

**ឆ៖** ឮគេថាៗខ្មោចនៅហ្នឹង លលាដ៍ក្បាលនៅហ្នឹងឯង។ ថាដល់ទួលតាត្រង់បាត់ខ្លួន មកវិញទទេទេ អ្នកៗបណ្ដើរទៅ។ តែបណ្ដើរទៅហើយបាត់។

**ស៖** ខ្ញុំចង់សួរលោកថាអ៊ីចេះទេ លោកនិយាយថា អ្នកដែលគេបណ្ដើរយកទៅហ្នឹងជាយួន ឬក៏ជនជាតិវៀតណាម។ ខ្ញុំចង់សួរលោកបញ្ជាក់ថា ហេតុអីបានជាលោកប៉ាននិយាយថាពួកគាត់ហ្នឹងជាជនជាតិវៀតណាម?

**ឆ៖** ទេ បើជនជាតិវៀតណាមនៅហ្នឹងខ្លះមែន។ បណ្ដើរទៅ វៀតណាមនិយាយប៉ែឡាំៗ មិនដែលមិនដឹង។

**ស៖** ចុះមាន តើលោកមានស្គាល់អ្នកណាខ្លះក្នុងចំណោមមនុស្សដែលគេបណ្ដើរទៅហ្នឹងទេ?

**ឆ៖** អត់ទេ អត់ស្គាល់។ វរៈខុសគ្នា អត់ស្គាល់ តែវរៈឯងហ្នឹងស្គាល់មិនសព្វផង។

**ស៖** ចុះមុននេះបន្តិច លោកប្រាប់ទៅតុលាការថា មានជនជាតិវៀតណាមនៅក្នុងភូមិរបស់លោកហ្នឹង ហើយស្គាល់ដោយសារមានពួកគាត់ហ្នឹងនិយាយប៉ៃឡាំ។ មានប៉ុន្មាននាក់ដែរតាមដែលលោកចាំ តាមដែលលោកដឹងហ្នឹង នៅក្នុងភូមិរបស់លោកហ្នឹងដែលជាជនជាតិវៀតណាម?

**ឆ៖** វរៈខ្ញុំមានតែចិនទេ។ វរៈ២បានមានជនជាតិវៀតណាម មានប្រហែលបីបួនគ្រួសារប៉ុណ្ណឹងឯង។

[១៤:០៦:៥២]

**ស៖** បីបួនគ្រួសារហ្នឹង បើសរុបទៅប្រហែលជាប៉ុន្មាននាក់លោក? ចាំបានទេ ទាំងអស់នៅក្នុងគ្រួសារបីបួនហ្នឹង?

**ឆ៖** មិនដឹងគ្រួសារគេមានប៉ុន្មាននាក់ផង វានៅឆ្ងាយគ្នា គ្រាន់តែឃើញគេចងបណ្ដើរទៅ។

**ស៖** ចុះម៉េចបានលោកដឹងថា មានបីបួនគ្រួសារនៅក្នុងវរៈលេខ២ហ្នឹងដែលជាជនជាតិយួន?

**ឆ៖** បីបួនគ្រួសារ គេបណ្ដើរទៅនេះ គេចាប់បណ្ដើរទៅមានបីបួនគ្រួសារ ហើយមួយគ្រួសារមានមួយទេ។

**ស៖** អ៊ីចឹងនៅពេលដែលគេចាប់បណ្ដើរយកទៅទិសខាងលិចហ្នឹង លោកមានបានដើរតាម ឬក៏បានទៅមើល ឬក៏លួចមើលដែរទេ ពេលដែលគេចាប់បណ្ដើរមនុស្សយកទៅភ្លាមនោះ?

**ឆ៖** អត់បានទៅមើលភ្លាមទេ។ គ្រាន់តែឃើញគេបណ្ដើរទៅលិច ដឹងថា គេមកវិញដៃទទេហើយ។ ទៅមើលឃើញតែក្បាលនៅទួលតាត្រង់ហ្នឹង គេយកទៅពិឃាតតែហ្នឹងឯង។

**ស៖** ចុះពេលណាបានលោកទៅមើលឃើញក្បាលនៅទួលតាត្រង់ហ្នឹង? ខុសគ្នាប៉ុន្មានរយៈពេល ពីលោកមើលឃើញគេបណ្ដើរមនុស្ស ហើយបានលោកទៅឃើញសាកសពដែលជាក្បាលនៅទួលតាត្រង់ហ្នឹង?

**ឆ៖** ក្រប៊ី ឃើញនៅទួលតាត្រង់ហ្នឹងហើយក្បាល។

**ស៖** ខ្ញុំចង់ដឹងពីរយៈពេលលោក លោកសាក្សី លោកថាលោកឃើញគេចងមនុស្ស ហើយបណ្ដើរយកទៅ ហើយក្រោយមកលោកថា ឃើញសាកសពដែលជាក្បាលមនុស្សហ្នឹង នៅទួលតាត្រង់នៅជិតភ្នំកុយ។ ខ្ញុំចង់ដឹងថារយៈពេលប៉ុន្មានដែរក្រោយពីលោកបានគេឃើញបណ្ដើរហ្នឹង ហើយបានទៅឃើញសាកសពដែលជាក្បាលហ្នឹង វាឃ្លាតគ្នាប៉ុន្មាន ប៉ុន្មានម៉ោង ប៉ុន្មានថ្ងៃ ប៉ុន្មានអាទិត្យ ឬដែរ?

[១៤:១០:១៦]

**ធ៖** រំលងពីរថ្ងៃអីហ្នឹង ខ្ញុំដើរទៅឃើញតែក្បាល ចចកស៊ីអស់ហើយ។

**ស៖** រំលងបានពីរថ្ងៃបានជាលោកទៅដល់ទួលតាត្រង់ហ្នឹង ហើយឃើញក្បាល។ អ៊ីចឹងពេលដែលលោកទៅដល់ទួលតាត្រង់ហ្នឹង សូមលោកជួយប្រាប់តុលាការមើលថា លោកឃើញអីគេខ្លះ? ហើយក្បាលហ្នឹងក្បាលស្ថានភាពបែបណាដែរ ដែលលោកចាំបាន? ជួយរៀបរាប់ព្រឹត្តិការណ៍ហ្នឹងបន្តិចមក។

**ធ៖** ដំណាលបែបគេវាយហ្នឹង បានងាប់នោះ។

**ស៖** ពេលដែលលោកទៅដល់ទួលតាត្រង់ហ្នឹង លោកឃើញសាកសពប៉ុន្មានៗនាក់?

**ធ៖** បួននាក់។

**ស៖** ចុះសភាពសាកសពដែលលោកឃើញហ្នឹង យ៉ាងម៉េចដែរ?

**ធ៖** ហើមរលួយអស់ហើយ។

**ស៖** មានសាកសពមនុស្សប្រុស មនុស្សស្រី កុមារ ឬក៏មនុស្សចាស់ដែរទេ ដែលលោកបានឃើញហ្នឹង?

**ធ៖** ធំៗហើយហ្នឹង មានប្ដី មានប្រពន្ធអីហើយហ្នឹង។

[១៤:១២:៣៧]

**ស៖** លោកសាក្សី ខ្ញុំនឹងអានចម្លើយរបស់លោកដែលលោកធ្លាប់ឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតម្ដងនោះ កាលដែលគេទៅសម្ភាសលោកនៅភូមិរបស់លោកហ្នឹង គឺនៅឯកសារE3/5178, ERN ជាភាសាខ្មែរ 00197916, ជាភាសាអង់គ្លេស 00274178, ជាភាសាបារាំង 00274185។ លោកសាក្សីនៅពេលដែលគេចុះទៅសម្ភាសលោកហ្នឹង លោកបានឆ្លើយថា៖ "ខ្ញុំបានលួចមើលកន្លែងដែលគេបណ្ដើរយួនទាំងនោះទៅសម្លាប់ ហើយក៏បានឃើញសាកសពមនុស្សស្រីនិងកុមារ ដែលមានស្នាមវាយត្រង់ក្បាល ដោយចុងផ្កាន ហើយមានឈាមពាសពេញកន្លែងនោះ។ រីឯសពកុមារមានបែកក្បាល ដូចជាគេបោកក្បាលទៅនឹងគល់ឈើ។ ក្រោយពីការសម្លាប់យួនមួយខ្សែនេះ ខ្ញុំមិនដែលប្រទះឃើញមានយួននៅសេសសល់ទៀតទេ។" លោកសាក្សី លោកបានឆ្លើយជាមួយអ្នកស៊ើបអង្កេតថា មានសាកសពមនុស្សស្រី និងកុមារ ហើយកុមារហ្នឹង បែកក្បាលដូចបោកនឹងគល់ឈើ។ សូមឲ្យលោកជួយរៀបរាប់អំពីស្ថានភាពពេលនោះ យ៉ាងម៉េចដែរ ពេលលោកឃើញក្មេងហ្នឹងយ៉ាងម៉េច?

**ឆ៖** ព្រោះគេចាប់ទៅសម្លាប់នៅទួលតាត្រង់ គេ អាខ្លះខ្ញុំមិនដឹងទេ ឃើញតែខ្មោច។ បោកនឹងគល់ឈើ និងគល់អីក៏មិនដឹងដែរ វាឃើញតែលលាដ៍ក្បាលអី ច្រើនណាស់ មិនមែនតិចណា។ ខ្លះខ្ញុំឃើញទាន់ ខ្ញុំមិនឃើញក៏គេយកទៅសម្លាប់ដែរ។

**ស៖** លោកនិយាយថា ខ្លះលោកឃើញទាន់ ខ្លះលោកឃើញមិនទាន់ គេយកទៅសម្លាប់។ ចង់សួរបញ្ជាក់លោកថា តើអ្នកដែលលោកឃើញទាន់ហ្នឹង ឃើញយ៉ាងម៉េច? ហើយមានរឿងអ្វីកើតឡើងចំពោះពួកគាត់ហ្នឹង?

[១៤:១៥:២១]

**ឆ៖** ខ្ញុំឃើញទាន់ចាប់អាប្អូននាក់ហ្នឹងយកទៅទេ។ អាងទៃអីទៀត ខ្ញុំមិនបានឃើញទេ គឺឃើញតែលលាដ៍ក្បាលនៅហ្នឹង។ រកក្របីទៅ ឃើញលលាដ៍ក្បាលពាសពេញត្រង់ហ្នឹង ទៅទួលតាត្រង់ គេយកទៅសម្លាប់ត្រង់ហ្នឹងឯង។

**ស៖** ហើយលោកបាននិយាយថា មានឃើញឈាមពាសពេញកន្លែង នៅទួលតាត្រង់ តើឈាមហ្នឹង លោកឃើញច្រើនទេ? ហើយនៅលើសាកសពមនុស្សហ្នឹងតែម្តង ឬក៏នៅកន្លែងណាដែរ? សូមលោកជួយរៀបរាប់ប្រាប់តុលាការផង។

**ឆ៖** កកឈាមនៅនឹងដី នឹងអីឯង ដែលគេវ៉ៃគេអីទៅ ក៏មិនដឹង មិនបានលបមើលគេ ខ្លាចដែរនោះ។ គ្រាន់តែឃើញ គេចចេញបាត់ហើយ។

**ស៖** ចុះក្រោយពេលដែលលោកបានឃើញការចាប់ខ្លួន ហើយនិងក្រោយមក បានឃើញសាកសពនៅទួលតាត្រង់ តើលោកមានធ្លាប់បានឃើញជនជាតិវៀតណាមនៅក្នុងការដ្ឋាន ឬក៏នៅក្នុងឃុំ នៅក្នុងវរៈរបស់លោកទៀតទេ ក្រោយហេតុការណ៍ដែលលោកបានឃើញហ្នឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:១៧:១៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ នៅក្នុងការបកប្រែ ខ្ញុំបានឮថា គាត់ប្រើពាក្យ "គ្រោងឆ្អឹងនៅ" ហើយតែសហព្រះរាជអាជ្ញាបាននិយាយពាក្យ "សាកសព" ប៉ុន្តែការបកប្រែជាអង់គ្លេសទៅជា *"ស្គិល*

*ឡិតធិន"* បានន័យថា ជាគ្រោងឆ្អឹង ឬក៏អដ្ឋិធាតុ។ អ៊ីចឹងគឺថា នេះជាចំណុចសំខាន់ ពីព្រោះបើសហព្រះរាជអាជ្ញាសំដៅទៅលើសាកសព អាហ្នឹងជាន័យផ្សេង។ រីឯគ្រោងឆ្អឹង ឬក៏លលាដ៍ក្បាលផ្សេង។ ដូចជានៅពេលសាក្សីបានឃើញ គាត់បានឃើញការចាប់ខ្លួន ហើយបន្ទាប់មកគាត់បានឃើញគ្រោងឆ្អឹង ឬក៏ថា លលាដ៍ក្បាលនោះ គឺថាគាត់បានឃើញសាកសពដែលរលួយ គឺថានៅសល់តែឆ្អឹង។ បើនិយាយថាសាកសព អាហ្នឹងគឺថានៅទាំងមូល អត់ទាន់ឃើញឆ្អឹងទេ គឺន័យអ៊ីចឹង។

**សួរដោយកញ្ញា សុង ឆវ័ន្ត៖**

**ស៖** មុននេះ ខ្ញុំកំពុងបានពិភាក្សាជាមួយនឹងលោកសាក្សីអំពីសាកសពមនុស្សដែលស្លាប់ ដែលគាត់ថា គាត់បានឃើញ ហើយឃើញប្អូននាក់ហ្នឹង។ អ៊ីចឹងខ្ញុំសួរគាត់បញ្ជាក់ថា លោកសាក្សីនៅពេលដែលលោកទៅដល់ទួលតាត្រង់ហ្នឹង លោកថា លោកឃើញសាកសពមនុស្សដែលស្លាប់ហ្នឹង តើសាកសពហ្នឹងមានស្ថានភាពយ៉ាងម៉េចដែរ? ហើយតើសាកសពហ្នឹងស្ថានភាពយ៉ាងម៉េចដែរ?

**លោក ព្រុំ សារុន៖**

**ឆ៖** សាកសពហ្នឹងមានក្រៀម គេសម្លាប់អស់ហើយ មានក្រៀមធ្វើ *(ឮមិនច្បាស់)* អស់ហើយ មានអីទៀត។

**ស៖** ចុះមានសាកសពផ្សេង ក្រៅពីសាកសពនេះដែលមានស្ថានភាពនៅថ្មី ឬក៏អាចកត់សម្គាល់បានថា ជាមនុស្សប្រភេទណា ស្រី ប្រុស ក្មេង ចាស់ អីដែរទេ? និយាយថា ថ្មីៗដែលទើបតែនឹងស្លាប់?

[១៤:១៩:៤៥]

**ឆ៖** ស្លាប់ឡើងធុយ ស្អុយរលួយហើយ មានប៉ានដើរទៅជិតឯណា។

**ស៖** ចុះក្រោយពេលដែលលោកបានឃើញពីការចាប់ខ្លួនបណ្តើរមនុស្សយកទៅ ហើយក្រោយមកឃើញសាកសពដែលស្អុយរលួយ ដែលនៅទួលតាត្រង់ តើនៅក្នុងកងរបស់លោក ឬក៏នៅក្នុងកងវរៈ២ហ្នឹងមានជនជាតិវៀតណាមដទៃផ្សេងទៀតនៅសេសសល់ទេ?

**ឆ៖** អត់មានជនជាតិវៀតណាមសល់ទេ គេចាប់អស់ហើយ មានឯណា។

**ស៖** លោកសាក្សី តើប្រធានកងរបស់លោក ឬក៏មានថ្នាក់លើណាមួយរបស់លោកនៅក្នុងតំបន់របស់លោកហ្នឹង មានដែលធ្លាប់ពន្យល់ពីមូលហេតុអ្វីបានជាគេចាប់ប្រជាជនវៀតណាមយកទៅទេ?

**ឆ៖** មិនដឹងមានមូលហេតុអី ខ្ញុំមិនដឹងដែរ។ ឃើញតែគេចាប់ជនជាតិវៀតណាមគេចាប់។ រក

មូលហេតុអី ខ្ញុំនៅក្រោមគេដែរ មិនហ៊ានសួរដេញដោលទេ រកតែអាយុខ្លួនឯងដែរ។

**ស៖** ចុះកាលហ្នឹងប្រធានកង ឬក៏ប្រធានវរៈរបស់លោកហ្នឹងអត់ដែលប្រាប់លោកថា មូលហេតុអីបានជាត្រូវមកសួរលោកថា នៅក្នុងកងរបស់លោកមានជនជាតិវៀតណាម? ហើយហេតុអីបានជាមានការចាប់ជនជាតិវៀតណាមរហូតអស់ពីកងរបស់លោកនៅក្នុងកងវរៈ២ហ្នឹង ក៏អត់មានសល់អីចឹង? លោកមានដែលដឹង ឬក៏គាត់មានដែលពន្យល់ប្រាប់លោកទេ?

[១៤:២២:១៩]

**ឆ៖** មិនដែលដេញដោលគេផង។ សួរដេញដោលនោះ នាំតែយ៉ាប់ទាំងខ្លួនឯង។ សម្លាប់មនុស្សគ្មានមេត្តាយ៉ាងនេះ អ្នកណាដេញដោលវា។

**ស៖** លោកនិយាយថា "សម្លាប់មនុស្សគ្មានមេត្តា" ហ្នឹង លោកចង់និយាយដល់អ្នកណា?

**ឆ៖** ក្រុមហ្នឹងមានដែលមេត្តាយើងអ្ហ្ន! ប្រើទាំងយប់ទាំងថ្ងៃ។

**កញ្ញា សុង ឆវ័ន្ត៖**

ចាស លោកសាក្សីសូមអរគុណ។ សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ចប់សំណួររបស់ខ្ញុំ ហើយសូមផ្ទេរវេទិកានេះបន្តទៅសហព្រះរាជអាជ្ញាអន្តរជាតិ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពភាគីទាំងអស់។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីជម្រាបសួរ ខ្ញុំឈ្មោះ វាំងសង់ វ៉ាយដ៍ ខ្ញុំនឹងសួរបន្តទៅទៀត។ ជាដំបូងខ្ញុំសួរអំពីការចាប់ខ្លួន និងការសម្លាប់ជនជាតិវៀតណាម។ ខ្ញុំមានសំណួរបន្ថែមដើម្បីសួរលោកពាក់ព័ន្ធនឹងចំណុចនេះ។ លោកបាននិយាយថា នៅក្នុងវរៈរបស់លោក គឺមានតែចិន មិនមានវៀតណាមទេ។ នេះជាអ្វីដែលលោកប្រាប់ទៅមេរបស់លោក។ ចុះពួកជនជាតិចិនទាំងអស់នោះ គេមានចាប់ខ្លួនទេ?

[១៤:២៤:២២]

**លោក ព្រុំ សារុន៖**

**ឆ៖** អត់ដែលមាន។ ជាតិចិន អត់ដែលមាន គេគ្រាន់តែប្រើ បារអាចម៍បារអីទៅ ជនជាតិចិន។

**ស៖** ខ្ញុំសូមត្រឡប់មកនិយាយអំពីតួលេខដែលលោកបានប្រាប់កាលពីមុន លោកថាដំបូងឡើយ

នៅក្នុងវរៈលេខ២មានជនជាតិវៀតណាមជាច្រើន ហើយក្រោយមកទៀត មានគ្រួសារវៀតណាមបីបួននាក់ -- បីបួនគ្រួសារ។ ដូច្នេះខ្ញុំអាចនិយាយបានទេថា នៅក្នុងបីបួនគ្រួសារហ្នឹងបើយើងគិតទៅប្រហែលជាមានចំនួនមនុស្សគឺ ២០នាក់។ ត្រឹមត្រូវទេ?

**ឆ៖** មិនដល់២០ទេ បីបួនគ្រួសារនោះ។ មួយគ្រួសារមានប៉ុន្មាននាក់ បីបួននាក់ហ្នឹង។

**ស៖** បើសិនជាខ្ញុំស្តាប់មិនច្រឡំទេគឺថា លោកបានឃើញជនជាតិវៀតណាមពីរនាក់ ត្រូវបានគេចាប់ខ្លួន។ អ៊ីចឹងបើខ្ញុំរាប់គ្នាប្រហែលជាបីបួននាក់ក្នុងមួយគ្រួសារអ៊ីចឹងទៅ ខ្ញុំបូកទៅប្រហែលជាលើសពី១០នាក់។ ចុះជនជាតិវៀតណាមផ្សេងទៀត ដែលលោកមិនបានឃើញគេនាំខ្លួន និងចាប់ខ្លួននោះ តើមានរឿងអ្វីកើតឡើងចំពោះពួកគេដែរ?

**ឆ៖** ទេ អត់បានឃើញ ខ្ញុំអត់ដឹង។ មានអី ខ្ញុំឃើញតែប៉ុណ្ណឹង ខ្ញុំថាតែប៉ុណ្ណឹងឯង។

**ស៖** ក៏ប៉ុន្តែលោកថា លោកបាន លោកលែងបានឃើញពួកគេតទៅទៀតនៅក្នុងវរៈលេខ២ហ្នឹង។ អ៊ីចឹងមានអ្នកណាម្នាក់ ឬក៏មានអាជ្ញាធរណាមួយប្រាប់លោកថា មានរឿងអ្វីកើតឡើងចំពោះជនជាតិវៀតណាមផ្សេងទៀតទេ?

**ឆ៖** អត់ទេ។

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីសាកសពបួនដែលលោកបានឃើញនៅក្នុងព្រៃ នៅទួលតាគ្រង់ពេលដែលលោកឃើញសាកសពហ្នឹង លោកនៅចម្ងាយប៉ុន្មានពីសាកសពដែរ?

**ឆ៖** ប្រហែល១០ម៉ែត្រដែរហ្នឹង រកក្របី ទៅជួប។

[១៤:២៧:៥៤]

**ស៖** លោកច្បាស់ទេ ថាលោកឃើញសាកសពទាំងអស់នៅកន្លែងហ្នឹង ឬក៏លោកនៅឆ្ងាយពេកលោកមិនឃើញច្បាស់ទេ ឃើញតែសាកសពមួយចំនួនតែប៉ុណ្ណោះ?

**ឆ៖** បាទ មើលមិនច្បាស់ ឃើញតែប៉ុណ្ណឹងឯង។

**ស៖** លោកបានឃើញមនុស្សពីរនាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅតាមទិសដៅនោះ បន្ទាប់មកលោកឃើញសាកសពបួន។ តើសាកសពទាំងបួនហ្នឹងមានសម្លៀកបំពាក់ទេ?

**ឆ៖** មានអីឯណា វារលួយអស់ទៅហើយ មានសម្លៀកបំពាក់ឯណា រលួយអស់ហើយ ហើមប៉ោងហើយហ្នឹង។

**ស៖** លោកស្គាល់អ្នកណាម្នាក់ទេ ក្នុងចំណោមសាកសពទាំងបួនហ្នឹង? លោកដឹងច្បាស់ថា

ពិតជាសាកសពជនជាតិវៀតណាមដែលគេនាំយកទៅហ្នឹងទេ?

**ឆ៖** អត់ទេ។ មើលពីចម្ងាយដែរហ្នឹង សាកសពហ្នឹងមិនដែលទៅជិតផង ព្រោះក្របីទៅពើប ហ្នឹង កុំអីខ្ញុំមិនដឹងទេ។

**ស៖** អម្បាញ់មិញនេះ គេសួរថា លោកមានបានឃើញថា សាកសពកុមារដែរឬក៏អត់? លោក លោកថា ឃើញសាកសពកុមារហើយដែលគេវាយបំបែកក្បាល។ ដូច្នេះ ខ្ញុំចង់សួរបញ្ជាក់ឲ្យបានច្បាស់ ថា លោកមានបានឃើញសាកសពកូនក្មេងដែរឬក៏អត់នៅទួលតាត្រង់នោះ?

[១៤:៣០:១៧]

**ឆ៖** ឆ្កែវាពាំអស់ហើយ ខ្ចាត់រណែងទៅឯណាអស់ ខ្ចាត់ខ្ចាយទៅ។ សាកសពវាច្រើនដែរ។ ខ្ញុំមិន បានទៅពិនិត្យមើល ស្អុយ។

**ស៖** ដើម្បីឲ្យបានច្បាស់ អម្បាញ់មិញនេះលោកនិយាយថាមានសាកសពជាច្រើន។ ដូច្នេះខ្ញុំចង់ ដឹងថា ចំពោះលោកនេះតួលេខបួន សាកសពបួននេះ លោកយល់ថាច្រើន ឬក៏តិច?

**ឆ៖** ឃើញតែលលាដ៍ក្បាលនៅហ្នឹងខ្លះ អីខ្លះទៅ ហើយឆ្អឹងទៅ។ អ្នកថ្មីយកទៅវ៉ៃចោលនោះ ឃើញហើមទៅ។ ខ្ញុំមិនបានរាប់។

**ស៖** ដូច្នេះមានន័យថាលោកបានឃើញឆ្អឹង ឃើញលលាដ៍ក្បាល ហើយនិងបន្ទាប់មកទៀត លោកឃើញសាកសពហើមស្អុយរលួយ មានន័យថាជាស្ថានភាពពីរខុសគ្នា។ លោកបានឃើញសាកសព ស្អុយរលួយ និងមួយទៀត គឺលោកបានឃើញឆ្អឹង និងលលាដ៍ក្បាលមែនទេ?

**ឆ៖** បាទ ឃើញមានឆ្អឹង និងលលាដ៍ក្បាលហ្នឹងហើយ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីចំណុចនេះ តើលោកអាចបញ្ជាក់បានទេថា សាកសពប៉ុន្មាន ដែលហើមស្អុយរលួយ? ហើយលោកឃើញក្បាលខ្មោច ហើយនិងឆ្អឹងហ្នឹងប៉ុន្មាន? ទី១ គឺខ្ញុំចង់ដឹងថា សាកសពដែលស្អុយរលួយនោះមានប៉ុន្មាន ហើយនិងលលាដ៍ក្បាលមានប៉ុន្មាន?

**ឆ៖** មាននរណាបានរាប់។ ឃើញស្អុយរលួយ ដើរចេញដែរហ្នឹង មានរាប់អីកើត។

[១៤:៣៣:០៧]

**ស៖** ចុះលោកនិយាយថា សាកសពបួននោះ គឺមានន័យថាបួនសាកសពបួនហ្នឹង ជាសាកសព ដែលស្អុយរលួយហ្នឹង មែនទេ?

**ឆ៖** បាទ។ សាកសពបួនហ្នឹងទើបមកយកទៅវ៉ៃថ្មីៗ ស្អុយដែរ។ លលាដ៍ក្បាលឃើញលលាដ៍

ក្បាលសុសហើយ យកទៅវ៉ៃត្រង់ហ្នឹងឯង។ ខ្ញុំមិនបានរាប់ មិនបានអី។

**ស៖** ដូច្នេះគឺថាបានន័យថា លោកមិនបានរាប់លលាដ៍ក្បាលទេ។ សំណួរចុងក្រោយពាក់ព័ន្ធនឹងវៀតណាមដដែល។ អាជ្ញាធរឃុំ ឬក៏អាជ្ញាធរស្រុក ឬអាជ្ញាធរវរៈរបស់លោកហ្នឹង មានធ្លាប់និយាយថាជនជាតិវៀតណាមជាខ្មាំងនៃរបបទេ?

**ឆ៖** វាអត់ដែលនិយាយអី គេគ្រាន់តែគេសួរថា មានវៀតណាមនៅទេនេះ? ខ្ញុំថា អត់ទេ មានតែចិន។ គេក៏គាត់ដើរហួសទៅបាត់ទៅ។

**ស៖** មុនពេលឈប់សម្រាក ខ្ញុំចង់ចូលទៅនិយាយអំពីប្រធានបទផ្សេង គឺអាងទំនប់កំពីងពួយ។ លោកបាននិយាយអំពីការសាងសង់ទំនប់ជូនទៅសហចៅក្រមស៊ើបអង្កេត។ ដូច្នេះ តើលោកអាចរៀបរាប់ជាសង្ខេបអំពីទំហំនៃអាងកំពីងពួយនេះម្តងទៀតបានទេ ដើម្បីឲ្យយើងយល់ច្បាស់អំពីទំហំនៃអាងនេះ?

**ឆ៖** ទំហំនៃអាង ជើងវា១០០ម៉ែត្រ ខ្នងលើ៧០ម៉ែត្រ ហើយ៣គីឡូពីភ្នំខ្ពស់ទៅទល់កំពីងពួយ ៣,៥គីឡូ។

**ស៖** តើការសាងសង់ហ្នឹងមានជាទំនប់ទេ? ហើយប្រវែងហ្នឹងគឺរាប់គីឡូមែនទេ?

[១៤:៣៦:១៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំរង់ចាំស្តាប់សំណួរទី២របស់សហព្រះរាជអាជ្ញាដើម្បីឲ្យដឹងថាគាត់សួរអំពីអ្វី។ ដូច្នេះតាមរយៈសំណួររបស់គាត់ហ្នឹង គឺគាត់ចង់និយាយអំពីអាងកំពីងពួយ ក៏ប៉ុន្តែអាងកំពីងពួយហ្នឹងមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២នោះទេ។ ដូច្នេះខ្ញុំសូមជំទាស់នឹងសំណួរនេះលោកប្រធាន បើសិនជាគាត់នៅតែសួរអំពីអាងកំពីងពួយនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ នេះគ្រាន់តែជាសំណួរផ្តើមតែប៉ុណ្ណោះ ខ្ញុំគ្រាន់តែចង់ដឹងថាតើអ្នកណាខ្លះទៅទស្សនកិច្ចនៅទំនប់នោះ។ ជាពិសេសនោះតើមានកូនក្តីរបស់មេធាវី ហ្គីសសេ ឬក៏អត់?

ខ្ញុំនឹង -- ខ្ញុំមិនសួរអំពីការសាងសង់ទំនប់នេះទេ ខ្ញុំគ្រាន់តែសួរសំណួរផ្ដើមមួយពីរតែប៉ុណ្ណោះ ហើយបន្ទាប់មកទៀត ខ្ញុំនឹងចូលទៅនិយាយអំពីទស្សនកិច្ចរបស់មេដឹកនាំ ឬគណៈប្រតិភូបរទេសទៅទីនោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ប្រសិនបើទំនប់នេះមិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនោះទេ ខ្ញុំគិតថាការទស្សនកិច្ចរបស់មេដឹកនាំនៅទីនោះ ក៏មិនចូលទៅក្នុងវិសាលភាពដែរ។ ដូច្នេះសូមឲ្យគាត់ទៅសួរអ្វីដែលពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះក្ដីរបស់យើងនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

នេះជាតួនាទីរបស់ជនជាប់ចោទ និងវត្តមានរបស់ជនជាប់ចោទនៅទីនោះដែលគាត់អាចធ្វើទស្សនកិច្ចដូចជានៅត្រពាំងថ្មដែរ គឺយើងបង្ហាញឲ្យឃើញអំពីតួនាទីរបស់ជនជាប់ចោទនៅទំនប់នោះ។ ដូច្នេះខ្ញុំគិតថាសំណួរនេះវាចូលទៅក្នុងវិសាលភាពហើយ លោកប្រធាន។

[១៤:៣៨:២៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៩:៤៥]

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះសម្រេចថា បដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោកខៀវ សំផន ក្នុងជំទាស់ទៅនឹងការតាំងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិទៅសាក្សីរូបនេះ ដោយសារគោលដៅនៃការតាំងសំណួរនេះ គឺមានការពាក់ព័ន្ធទៅនឹងការអនុវត្តគោលនយោបាយ ហើយនិងតួនាទីរបស់ជនជាប់ចោទ។ ទន្ទឹមនេះដែរ អង្គជំនុំជម្រះសូមជម្រាបទៅខាងសហព្រះរាជអាជ្ញារងអន្តរជាតិថាគប្បីកំហិតនូវសំណួរដែលតាំងសំណួរនេះ ហើយចំពោះសាក្សីក្នុងករណីលក្ខខណ្ឌនៃការដ្ឋានទំនប់កំពីងពួយនេះ ដើម្បីចៀសវាងថាដំណើរការប្រព្រឹត្តទៅក្រៅអង្គហេតុដែលវាមិនពាក់ព័ន្ធនឹងវិសាលភាពនៃដីកាដំណោះស្រាយដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរតែមួយទៀតទេពាក់ព័ន្ធនឹងអាងកំពីងពួយនេះ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើអាងកំពីងពួយនេះមានឈ្មោះមួយទៀតថាជា "ទំនប់១៧មករា" មែនទេ?

**លោក ព្រុំ សារុន៖**

**ឆ៖** បាទ ខ្ញុំមិនដឹងដែរ ១៧មករាអី។

[១៤:៤១:១៨]

**ស៖** នៅកំពីងពួយហ្នឹងមានទំនប់ហ្នឹងតែមួយទេ មែនទេ?

**ឆ៖** បាទ មានតែមួយ។

**ស៖** តើមេដឹកនាំខ្មែរក្រហម ឬគណៈប្រតិភូបរទេសធ្លាប់ទៅទស្សនកិច្ចការដ្ឋានសាងសង់អាងកំពីងពួយទេ? លោកមានធ្លាប់ស្គាល់អ្នកណាខ្លះទេ?

**ឆ៖** អត់ដែលស្គាល់ទេ។ អ្នកថ្នាក់លើ អត់ដែលស្គាល់ មិនដឹងថាទៅទស្សនកិច្ចអី ក៏ខ្ញុំមិនដឹងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកចូលនៅកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីមុនពេលឈប់សម្រាក លោកបាននិយាយថា លោកមិនចាំថា មេដឹកនាំខ្មែរក្រហមណាខ្លះ ឬគណៈប្រតិភូបរទេសណាខ្លះមកទស្សនកិច្ចនៅអាងកំពីងពួយទេ។ ខ្ញុំចង់ដកស្រង់ឯកសារពីរ ដើម្បីរំឭកការចងចាំរបស់លោក។ ជាដំបូងគឺឯកសារ E3/1339 មានតែជាភាសាអង់គ្លេសទេគឺ 00168342 ជាការផ្សព្វផ្សាយតាមវិទ្យុ ចុះឆ្នាំ៧៧។ នេះជាការផ្សាយតាមវិទ្យុអំពីឧបនាយករដ្ឋមន្ត្រីចិន ឈ្មោះ ឆឹង យឹងគួយ នៅបាត់ដំបង នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ១៩៧៧ គឺមានអមដំណើរដោយ ប៉ុល ពត, រស់ ញឹម ហៅ មូល សម្បត្តិ និង អៀង សារី, វន វ៉េត, ម៉ី ប្រាង និង ជួន ជឿន។ មានការផ្សាយថា បុគ្គលទាំងអស់នេះបានទៅទស្សនកិច្ចទំនប់១៧មករា ស្ថិតនៅភ្នំសំពៅ ឃុំភ្នំសំពៅ។ លោកសាក្សីតើនៅខែធ្នូ ឆ្នាំ១៩៧៧ លោកនៅធ្វើការនៅអាងកំពីងពួយទេ? ហើយពេលដែលខ្ញុំនិយាយបែបនេះធ្វើឲ្យលោកនឹកឃើញឡើងវិញអំពីទស្សនកិច្ចរបស់ចិនដែលឈ្មោះ ឆឹង យឹងគួយ ហ្នឹងទេ?

**លោក ព្រុំ សារុន៖**

**ឆ៖** អត់ដែលឃើញផង។ ខ្ញុំនៅធ្វើការឯណោះ ម៉េចនឹងឃើញគេអ្នកធំៗ នៅរែកដី។

[១៥:០៤:៣៦]

**ស៖** ឯកសារទី២ ដែលខ្ញុំចង់ដកស្រង់ គឺឯកសារ E3/18 ជាសៀវភៅដែលសរសេរដោយលោក ខៀវ សំផន ដែលមានចំណងជើងថា៖ “ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងជាគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់”។ សម្រង់ដែលខ្ញុំចង់ដកស្រង់នោះគឺជាទំព័រជាភាសាបារាំង 00595487, ជាភាសាអង់គ្លេសគឺ 00103780, ជាភាសាខ្មែរគឺ 00103875។ នៅក្នុងសម្រង់នោះ ខៀវ សំផន គាត់បានរៀបរាប់អំពីទស្សនកិច្ចរបស់គាត់នៅអាងកំពីងកំពួយ។ គាត់បានសរសេរដូចតទៅ៖ “ម្យ៉ាងទៀត ខ្ញុំមិនសូវមានឱកាសចេញដើរក៏ពិតមែន នៅឆ្នាំ៧៥ ដល់៧៩ ប៉ុន្តែក៏ខ្ញុំបានឃើញផ្ទាល់នឹងភ្នែកនូវសមិទ្ធិផលខ្លះដែលខ្ញុំចង់បានយូរមកហើយ គឺការដោះស្រាយទឹកជាបញ្ហាសម្រាប់ស្រោចស្រពជនបទយើង ដូចជាអាងត្រពាំងថ្មនៅក្នុងស្រុកភ្នំស្រុក ខេត្តសៀមរាប និងអាងកំពីងកំពួយ ខាងលិចបាត់ដំបង។ ព្រមទាំងវាលស្រែរាបស្មើជាក្រឡាឈើត្រង់ដាច់កន្ទុយភ្នែក។ ទាំងអស់នេះហើយដែលនាំឲ្យខ្ញុំជឿទុកចិត្តលើរបបនេះ ហើយគោរពដល់វិញ្ញាណក្ខន្ធរបស់យុទ្ធជនរាប់សែននាក់ដែលបានធ្វើពលីកម្មទៅ។ ព្រមទាំងគោរព

ដល់បងប្អូនទាំងអស់ ដែលកំពុងខិតខំនឿយហត់ធ្វើការតាមការដ្ឋាន និងតាមសហករណ៍។ ឯខ្លួនខ្ញុំផ្ទាល់មិនបានដែលទៅនឿយហត់នឹងគេ។ ខ្ញុំយល់ឃើញថា ខ្ញុំត្រូវតែខិតខំធ្វើអ្វីដែលខ្ញុំអាចធ្វើបានដើម្បីរួមចំណែកជាមួយគេ ដូចជាខិតខំសន្សំសំចៃក្នុងការរស់នៅប្រចាំថ្ងៃ ហើយអាចយ៉ាងហោចណាស់ ខំជៀសវាងមិនធ្វើអ្វីដែលអាចនាំអំពល់រវល់ដល់គេ។ ខ្ញុំខិតខំតែបំពេញភារកិច្ចរបស់ខ្ញុំឲ្យបានត្រឹមត្រូវតែប៉ុណ្ណោះ។ ខ្ញុំនឹកស្មានថា វិន័យដ៏តឹងរ៉ឹងនេះ គ្រាន់តែជាបណ្ដោះអាសន្នទេ ដោយសភាពការណ៍ដែលប្រទេសយើងត្រូវខ្ទេចខ្ទាំដោយសង្គ្រាម តម្រូវឲ្យអ្នកណាដែលនៅកន្លែងនោះ នៅកន្លែងនោះសិន ហើយវិន័យនោះ នឹងបានបន្ធូរបន្ថយទៅវិញជាបណ្ដើរៗ នៅពេលដែលសភាពការណ៍កាន់តែប្រកាន់ប្រសើរឡើងជាបណ្ដើរៗវិញ។”

[១៥:០៧:០៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ក្រៅពីសហព្រះរាជអាជ្ញា គាត់ចង់អាននូវឃ្លាដែលដកស្រង់ចេញពីសៀវភៅរបស់លោក ខៀវ សំផន ដែលវាមិនមានជាប់ពាក់ព័ន្ធទៅនឹងវិសាលភាពនៃការប្រព្រឹត្តចំពោះជនជាតិវៀតណាមទេ។ ក៏ប៉ុន្តែសាក្សីហ្នឹង ក៏គាត់បានបញ្ជាក់ហើយថា គាត់មិនបានឃើញមេដឹកនាំណាម្នាក់ទេ។ អ៊ីចឹង ខ្ញុំគិតឃើញថា ដូចជាមិនមានប្រយោជន៍អីដែលគាត់អាននូវឃ្លាហ្នឹងទេ។ គឺថាមានតែធ្វើឲ្យយើងបង្ហិនតែពេលវេលាតែប៉ុណ្ណោះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំមិនទាន់សួរសំណួរនៅឡើយទេ។ ខ្ញុំគិតថា ការជំទាស់នោះដូចជាលឿនពេក។ ខ្ញុំអាចបន្តបានទេ លោកប្រធាន?

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរលោកថា តើលោកដឹងទេ នៅសម័យនោះអ្នកណាជា ខៀវ សំផន? លោកដឹងថា គាត់មានមុខងារអ្វីទេ?

**លោក ព្រុំ សារុន៖**

**ឆ៖** ខ្ញុំមិនធ្លាប់ស្គាល់គាត់ផង។ លោក ខៀវ សំផន មិនដឹងណាមួយផង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចូលទៅប្រធានបទថ្មី។ មុននេះលោកនិយាយថា តាឆាំ ជាមេស្រុកបាណន់។ លោកដឹងទេថា អ្នកណាគេជាប្រធានតំបន់៣ នៅពេលដែលលោកនៅធ្វើការនៅទីនោះ?

**ឆ៖** ខ្ញុំស្គាល់ តាឆាំ មែន។ តំបន់៣ មិនដឹងអ្នកណា។

**ស៖** ពាក់ព័ន្ធនឹង តាឆាំ នេះ តើគាត់ផ្ទាល់ និងកម្មាភិបាលបក្សផ្សេងទៀត មានបានរៀបចំការរៀបអាពាហ៍ពិពាហ៍នៅក្នុងស្រុកបាណន់ទេ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ នោះ?

**ឆ៖** សួររៀបអាពាហ៍ពិពាហ៍អ្វី? មិនមែនរៀបទេក្នុងជំនាន់ហ្នឹងនោះ អត់មានរៀបអាពាហ៍-ពិពាហ៍ទេ មានតែប្ដេជ្ញា ចាប់ដៃគ្នា គ្មានអាពាហ៍ពិពាហ៍រៀបទេ។

**ស៖** បាទ ពិតណាស់នេះជាពាក្យដែលគេប្រើក្នុងសម័យនោះ គឺពាក្យថា "ប្ដេជ្ញា"។ ដូច្នេះខ្ញុំចង់និយាយអំពីការប្ដេជ្ញានេះហើយ។ ខ្ញុំចង់ដឹងថានៅក្នុងពេលប្ដីប្រពន្ធ គេឲ្យប្ដេជ្ញាហ្នឹង គឺពួកគាត់ប្ដីប្រពន្ធហ្នឹងគាត់ស្គាល់គ្នាពីមុនមកទេ? ហើយអ្នកណាជាអ្នករើសឲ្យពួកគាត់?

**ឆ៖** គេត្រូវគ្នាទៅ គេបបួលទៅប្ដេជ្ញា ចាប់ដៃគ្នាទៅ។ ឃើញគេធ្វើអីចឹងហើយ គេត្រូវគេទៅ គេបបួលគ្នាទៅប្ដេជ្ញា ចាប់ដៃគ្នាទៅ។ តែប៉ុណ្ណឹង មិនមែនអារៀបអាពាហ៍ពិពាហ៍ទេ។

[១៥:១១:០៩]

**ស៖** លោកខ្លួនឯងផ្ទាល់ លោកធ្លាប់ចូលរួមក្នុងពិធីប្ដេជ្ញាហ្នឹងទេ?

**ឆ៖** អត់បានទៅចូលទេ គេរៀបប្ដេជ្ញាអី ខ្ញុំមិនដែលទៅចូលទេ គេចាប់ដៃគ្នាអី។ តែគណៈឃុំ គណៈអីទេ គេទៅ យើងកំប៉ិចកំប៉ុកអត់បានទៅជិតគេទេ។

**ស៖** បាទ អីចឹងនៅពេលដែលលោកនិយាយថា ពេលប្ដេជ្ញាហ្នឹង គឺប្ដីប្រពន្ធព្រមព្រៀងគ្នា។ អីចឹងលោកដឹងទេថា ពួកគាត់ហ្នឹងព្រមព្រៀងស្រឡាញ់គ្នាហ្នឹងដោយសេរីទេ?

**ឆ៖** គេនិយាយត្រូវគ្នា គេទៅចាប់ដៃគ្នា ណាត់គ្នាទៅ។ គេចាប់ដៃគ្នាឲ្យគណៈឃុំគេដឹងឮទៅ។ ទៅចាប់តែកន្លែងជិតល្វីហ្នឹងឯង វាលហ្នឹងឯង គេទៅចាប់ដៃគ្នាត្រង់ហ្នឹងឯង។ មិនបានទៅជិតទេ ខ្ញុំ។ រវល់តែធ្វើការ សកម្មការងារ។

**ស៖** បាទ ដោយសារតែលោកមិនធ្លាប់ចូលរួមក្នុងការប្ដេជ្ញានេះ អីចឹងខ្ញុំមិនសួរអ្វីច្រើនតទៅទៀតទេ។ ឥឡូវនេះខ្ញុំចង់សួរអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធទៅនឹងការប្រព្រឹត្ត

ចំពោះអតីតយោធាដែលមានបណ្ដាស័ក្តិ និងមន្ត្រីរដ្ឋការ លន់ នល់។ ជាដំបូងគឺនៅក្នុងតំបន់បាត់ដំបង និងជាពិសេសនៅស្រុកបាណន់។ តើលោកដឹងទេថា មានរឿងអ្វីកើតឡើងចំពោះទាហានមានបណ្ដាស័ក្តិ នៅក្នុងរបប លន់ នល់ ហើយនិងមន្ត្រីរដ្ឋការនៃរបប លន់ នល់ ក្នុងរយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានខែក្រោយ ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ មកនោះ?

[១៥:១៣:៤៥]

**ឆ៖** ថ្ងៃ០៧ មេសា ឆ្នាំ៧៥ នោះឃើញទាហានមកនឹងភូមិខ្ញុំ ហើយដើរទៅនៅអូរពងមាន់ណោះ ទីតាំងគេ។ ហើយមានអាមួយនោះបែបគេស្គាល់បណ្ដាស័ក្តិអីដឹង បានគេចាប់យកទៅបាញ់នឹងភ្នំក្រពើ ច្រមុះក្រពើហ្នឹងឯង។ បាញ់ប្ដីងាប់ទៅ ប្រពន្ធយំពិបាកពេក បាញ់ទាំងប្រពន្ធចោលត្រង់ហ្នឹងឯង ច្រមុះភ្នំក្រពើ។ ដឹងតែប៉ុណ្ណឹងឯង។ ទៅមើលទៅ ឃើញនៅរងោក ពីរនាក់ហ្នឹងឯង។

**ស៖** លោកស្គាល់អ្នកដែលគេនាំយកទៅបាញ់ចោលហ្នឹងទេ?

**ឆ៖** ប៉ុនឥឡូវ ទៅអាមេរិកបាត់ហើយ ថាឆ្កួតល្ងីល្ងើផង អាតារុំ ខ្វាក់ ស្គាល់ នៅភូមិខ្ញុំ។ តារុំ ខ្វាក់ ទៅអាមេរិកបាត់ហើយ។

**ស៖** ខ្ញុំនិយាយអំពីអ្នកដែលគេបាញ់ចោលនៅថ្ងៃនោះ ហើយដែលមានប្រពន្ធ នាំគ្នាស្រែកយំនោះ។ លោកស្គាល់ឈ្មោះជនរងគ្រោះទាំងអស់នោះទេ?

**ប្រធានអង្គជំនុំ៖**

ឆ្លើយៗ សាក្សីឆ្លើយ!

**លោក ព្រុំ សារុន៖**

**ឆ៖** ខ្ញុំអត់ស្គាល់ទេ អត់ស្គាល់ឈ្មោះមនុស្សហ្នឹងទេ។ គេបញ្ជូនមកកាត់ភូមិខ្ញុំមួយខ្សែ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាងលេ៖**

**ស៖** លោកនិយាយថា នៅបញ្ជូនជិតភូមិលោកហ្នឹង លោកសំដៅលើភ្នំក្រពើហ្នឹងមែនទេ?

[១៥:១៦:១៣]

**ប្រធានអង្គជំនុំ៖**

កុំទាន់អាលឆ្លើយសាក្សី!

**លោក ព្រុំ សារុន៖**

**ឆ៖** កាត់ភូមិខ្ញុំហ្នឹង គេទៅនៅអូរពងមាន់ បញ្ជូនកាត់ភូមិខ្ញុំហ្នឹង ទាហានមួយខ្សែ។ ដឹងគេ

ស្គាល់ មានបណ្ដាស័ក្ដិអីហ្នឹង បាន តារុំ ហ្នឹងកេះយកទៅបាញ់ចោល។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកធ្លាប់ឮគេនិយាយអំពីការសម្លាប់នៅកន្លែងមួយដែលហៅថា ចន្លោះក្ដោងទេ?

**ឆ៖** សម្លាប់មួយឈ្មោះមេកង អឿម មេខ្ញុំ កាលសម័យយើងធ្វើទាហាននោះ មេខ្ញុំ។ មេកង អឿម។ វ៉ៃគ្នានៅចន្លោះក្ដោងងាប់បាត់ទៅ។

**ស៖** គាត់មានមុខងារអ្វី? ហើយមានស័ក្ដិប៉ុន្មាន? គាត់ជាមនុស្សសំខាន់ទេ នៅក្នុងកងទ័ពនោះ?

**ប្រធានអង្គជំនុំ៖**

កុំទាន់សាក្សី!

**លោក ព្រុំ សារុន៖**

**ឆ៖** គាត់មេខ្ញុំ កាលសម័យ លន់ នល់ គេរើសទាហាន ស្រែ ស្រី គាត់រើសទាហាន គាត់មេកង ខ្ញុំ។ សន្ដិភាពហ្នឹង គេវ៉ៃចោលនៅចន្លោះក្ដោងហ្នឹងទៅ។

[១៥:១៨:២២]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ម៉េចបានជាលោកដឹងថា តាអឿម ហ្នឹងត្រូវបានគេសម្លាប់ចោល?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក ព្រុំ សារុន៖**

**ឆ៖** ខ្ញុំទៅរកលីក្រូចអីពោធិ៍សាត់អីនោះមក បានមកឃើញខ្មោចហ្នឹង នៅទ្រោមហើយតាអឿម ហ្នឹង ទ្រោមអស់ហើយ។ ចង់បាត់ក្លិនស្អុយហើយ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ពេលដែលលោកឃើញសាកសពគាត់ហ្នឹង គាត់មានឯកសណ្ឋានយោធាទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក ព្រុំ សារុន៖**

**ឆ៖** ស្លៀកពាក់ខោអាវធម្មតា រហែកអស់ហើយ ឆ្អែទាញហែកអស់ហើយ។ អត់មានអ្នកណា

កប់ ណាអីទេ។

[១៥:២០:០០]

**សៈ** អម្បាញ់មិញនេះ លោកនិយាយអំពីមេវរៈរបស់លោកឈ្មោះ ក្រច។ តើលោកធ្លាប់ទទួលបញ្ជាអំពីមេរបស់លោក--

**ឆៈ** បាទ។

**សៈ** លោកសាក្សីពេលដែលលោកចង់និយាយ សូមលោកចាំមើលភ្លើងក្រហមសិន ចាំលោកនិយាយ។ ខ្ញុំសួរសិន កុំអាលឆ្លើយ។ លោកបាននិយាយអំពីមេវរៈរបស់លោកឈ្មោះ ក្រច តើលោកធ្លាប់ទទួលបញ្ជាពីគាត់ឱ្យស្វែងរកអ្នកណាជាអតីតទាហានមានបណ្ដាស័ក្តិនៅក្នុងសម័យ លន់ នល់ ទេ?

**ឆៈ** គាត់អត់ដែលបានទទួលបញ្ជាពីគាត់ទេ ព្រោះខ្ញុំទាហានដែរ។

**សៈ** ខ្ញុំនឹងអានទូវចម្លើយរបស់លោកចំពោះសហចៅក្រមស៊ើបអង្កេត ដើម្បីបញ្ជាក់អំពីចំណុចនេះ គឺឯកសារ E3/5187 ជាភាសាបារាំងទំព័រ៤, ជាភាសាខ្មែរទំព័រ៣, ៤ និងជាភាសាអង់គ្លេសទំព័រ៤។ លោកបានឆ្លើយដូចតទៅ៖ “គេចង់កម្ទេចអ្នកដែលមានបណ្ដាស័ក្តិខ្ពស់ក្នុងសម័យ លន់ នល់។ ខ្ញុំដឹងថាទាហាន និងក្រុមគ្រួសាររបស់ពួកគេត្រូវបានគេជម្លៀសពីខេត្តបាត់ដំបង។ ខ្ញុំឮ ក្រច និយាយថា (ខ្ញុំសូមដកស្រង់) ប្រសិនបើអ្នកណាម្នាក់ស្គាល់ទាហានដែលមានបណ្ដាស័ក្តិត្រូវរាយការណ៍មកខ្ញុំ។” នេះជាចម្លើយរបស់លោកកាលពេលដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយល័យសហចៅក្រមស៊ើបអង្កេត។ តើលោកអាចពន្យល់បានទេ ថា ក្រច ហ្នឹងនិយាយអ្វីខ្លះពាក់ព័ន្ធនឹងការដែលត្រូវរាយការណ៍ថាអ្នកណាជាអ្នកដែលមានបណ្ដាស័ក្តិក្នុងសម័យលន់ នល់ នោះ?

**ឆៈ** ខ្ញុំមិនបាននិយាយអីទេ គ្រាន់តែថាខ្ញុំមិនដឹងទេ អ្នកមានបណ្ដាស័ក្តិនោះ។ តែប៉ុណ្ណឹងឯង។

[១៥:២២:៤៦]

**សៈ** តើកម្មាភិបាលមូលដ្ឋានធ្វើយ៉ាងម៉េច ដើម្បីអាចដឹងថាអ្នកណាជាអតីតមន្ត្រីជាន់ខ្ពស់ ឬក៏ជាអតីតទាហានដែលមានបណ្ដាស័ក្តិខ្ពស់ក្នុងសម័យ លន់ នល់? គេមានវិធីអីដើម្បីស្រាវជ្រាវរកអ្នកទាំងអស់ហ្នឹង?

**ឆៈ** មានវិធីហ្នឹង យកទៅវៃចោល មានស្អី មានតែវៃ មិនមានជំនុំជម្រះអីទេ សម័យនោះ។ មើល តាអៀម មេខ្ញុំយកទៅវៃ ចាប់ៗយកទៅវៃបាត់។

**សៈ** មុនពេលនាំអ្នកទាំងអស់ហ្នឹងទៅ គេមានបាននិយាយអ្វីប្រាប់អ្នកទាំងអស់ហ្នឹងដើម្បីបញ្ចុះ

បញ្ចូលឲ្យអ្នកទាំងអស់ហ្នឹងដើរតាមកម្មាភិបាលខ្មែរក្រហមទេ? គេមានប្រាប់យ៉ាងម៉េច បានជាអ្នកទាំងអស់ហ្នឹងព្រមដើរទៅតាមពួកខ្មែរក្រហមនោះ?

**ឆ៖** និយាយស្តាប់មិនបាន ម៉េច? មានប្រសាសន៍ម្តងទៀតមើល។

**ស៖** ខ្ញុំនឹងសួរតាមរបៀបផ្សេងវិញ។ លោកនិយាយថា គេនាំទាហានជាន់ខ្ពស់សម័យលន់ នល់ហ្នឹងទៅកម្ទេច។ អ៊ីចឹងខ្ញុំចង់ដឹងថាតើខ្មែរក្រហមគេធ្វើយ៉ាងម៉េច បានអាចបញ្ចុះបញ្ចូលទាហាន លន់ នល់ ហ្នឹងឲ្យព្រមទៅដើរទៅតាមគេនោះ ដោយមិនឲ្យពួកហ្នឹងងើបបះបោរប្រឆាំងនឹងខ្មែរក្រហមនោះ?

**ឆ៖** មិនដឹងឆ្លើយទេ។

**ស៖** ខ្ញុំគិតថាប្រហែលជាខ្ញុំសួរមិនច្បាស់ ហើយអ៊ីចឹងខ្ញុំចូលទៅសំណួរផ្សេងតែម្តងទៅ។ លោកនិយាយថា ទាហានដែលមានបណ្តាស័ក្តិហ្នឹងត្រូវបានគេនាំយកទៅកម្ទេចចោល ចុះក្រុមគ្រួសាររបស់ទាហានទាំងនោះ កូន ប្រពន្ធ ឪពុកម្តាយអីនោះ មានគេចាប់ខ្លួនដែរទេ?

**ឆ៖** អត់មានទេ មិនដែលមានទេ វរៈខ្ញុំ។ មិនដែលមានគេចាប់ខ្លួនយកទៅទេ។

[១៥:២៥:៥២]

**ស៖** មានសាក្សីមួយនៅក្នុងតំបន់នោះដែរ គឺឈ្មោះ ជុច ពន្លក គឺឯកសាររបស់គាត់ E3/5211 គាត់និយាយអំពីការស្វែងរកទាហានលន់ នល់ យកទៅសម្លាប់ចោលនៅភ្នំសំពៅ ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥។ ជាដំបូង ខ្ញុំចង់សួរលោកថា លោកស្គាល់ឈ្មោះ ជុច ពន្លក នេះទេ?

**ឆ៖** អត់ដែលស្គាល់ទេ។

**ស៖** បាទ មិនអីទេ។ គាត់និយាយអំពី តាឆាំ និងតួនាទីរបស់ តាឆាំ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់គឺ E3/5211 គឺនៅទំព័រទី៣ ជាភាសាអង់គ្លេស, ទំព័រ៣ជាភាសាបារាំង និងទំព័រ ២-៣ ជាភាសាខ្មែរ។ គាត់រៀបរាប់ដូចតទៅថា៖ "តាឆាំ បានបញ្ជាឲ្យអតីតទាហានលន់ នល់ ដែលជាខ្មាំងឲ្យទៅជួបជុំគ្នានៅវត្តភ្នំសំពៅ។ បន្ទាប់មកទៀតគាត់បាននិយាយថា ក្រោយមកខ្ញុំដឹងថា ពួកគេស្រាវជ្រាវនៅក្នុងចំណោមប្រជាជននៅឃុំភ្នំសំពៅ ដើម្បីរកមើលរកថាតើអ្នកណាជាមន្ត្រីរដ្ឋការនៅរបបលន់ នល់។ ការស្រាវជ្រាវហ្នឹង គឺធ្វើបានយ៉ាងជោគជ័យ។ ខ្ញុំឃើញកូនចៅរបស់ តាឆាំ គឺពួកទាហានហ្នឹង គឺចាប់ខ្លួនពួកអតីតទាហានលន់ នល់ ហើយចាប់យកទៅដាក់ក្នុងឡាន ហើយប្រាប់ថាបញ្ជូនឲ្យទៅរៀននៅអង្គការថ្នាក់លើ។ ក្នុងចំណោមអ្នកដែលចាប់ខ្លួនបានហ្នឹង គឺមានដូចជា មេឃុំភ្នំសំពៅ ឈ្មោះ ក្លូត ចាន់ -- គឺ ក្លូត ឆន, មី វឿត ជាមេភូមិភ្នំសំពៅលិច, គ្រូបង្រៀនភ្នំសំពៅ ឈ្មោះ ចាន់

មូល។ល។ បន្ទាប់មកទៀត គាត់បានរៀបរាប់ថា អ្នកទាំងអស់ហ្នឹងត្រូវបានគេបាញ់សម្លាប់ចោល។" ខ្ញុំមិនទាន់បានសួរផង ឥឡូវគាត់ងើបឈរជំទាស់ទៅហើយ លោកប្រធាន។

[១៥:២៨:៤៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគឺថា ខ្ញុំស្ដាប់មួយរយៈ ហើយអ្វីដែលត្រូវសួរ គឺសួរសំណួរដោយបើកចំហ។ ហើយសាក្សីជាក់លាក់ហ្នឹង គឺថាគាត់បាននិយាយអំពី តាឆាំ ប៉ុន្តែគឺសហព្រះរាជអាជ្ញា គឺថាអានសេចក្ដីដកស្រង់ពីបុគ្គលផ្សេងមកទាំងស្រុង ដែលថាសាក្សីមិនមានការដឹង ហើយការអានសម្រង់ដ៏វែង ដោយមិនបង្ហាញពីគោលបំណង ហើយដោយគ្មានការធ្វើសេចក្ដីផ្ដើម។ ហើយដូច្នេះ គឺថាសំណួរបន្ទាប់ពីសម្រង់ដ៏វែងបែបនេះ គប្បីតែមានការហាមឃាត់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកគ្រាន់តែនិយាយថា សម្រង់វែងមិនមានសំណួរត្រូវការហាមឃាត់ តើដូចម្ដេច?

**លោក វ៉ិចទ័រ កូប៉េ៖**

ថាតើអ្វីឆ្លើយតបជាប្រតិកម្មហ្នឹង គឺរបស់ខ្ញុំ គឺថានៅក្នុងការអនុវត្តនៅតុលាការ គឺថាគប្បីតែមានមូលដ្ឋានមួយចំនួនដើម្បីឱ្យយល់ដឹងអំពី តាឆាំ ឬក៏សាក្សីរូបណាដែលនឹងត្រូវដកស្រង់ដើម្បីឱ្យសាក្សីគាត់អាចនឹងមានគំនិត។ ប៉ុន្តែសំណួរដែលសហព្រះរាជអាជ្ញានឹងសួរហ្នឹង គឺអាចនឹងថាតើសាក្សីមានមតិយោបល់ដូចម្ដេចលើសម្រង់ដ៏វែងបែបនេះ។ នេះតាមអ្វីដែលខ្ញុំគិត។

[១៥:៣០:២៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធាន ខ្ញុំនឹងមិនសួរបែបហ្នឹងទេ។ នេះគឺជារបៀបដែលសួរដោយមេធាវី នួន ជា ទេ។ ពួកគាត់ជាទូទៅហ្នឹង គាត់ច្រើនតែអានសម្រង់យ៉ាងវែងៗ ហើយបានសួរយោបល់ពីសាក្សី។ ចំពោះខ្ញុំ ខ្ញុំមិនសួរអ៊ីចឹងទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំចង់សួរដូចតទៅ៖ លោកសាក្សី តើលោកមានចាំថាមានការប្រមូលផ្ដុំមន្ត្រី និងទាហាន

លន់ នល់ នៅវត្តភ្នំសំពៅដែរឬទេ? លោកគ្រាន់តែប្រាប់ថាលោកធ្លាប់ឮ ឬក៏មិនឮ ថាមានការប្រមូលផ្តុំមន្ត្រី និងទាហានជាន់ខ្ពស់នៅវត្តនោះ។ បើលោកមិនធ្លាប់ឮ សូមប្រាប់ថាមិនធ្លាប់ឮទៅ។

**លោក ព្រុំ សារុន៖**

**ឆ៖** មិនធ្លាប់ឮគេសួរទេ មិនដែលឃើញគេសួរ។ អត់ដែលឃើញទេ។

**ស៖** ខ្ញុំមានសំណួរសួរបន្តពាក់ព័ន្ធនឹងឈ្មោះដែលលើកឡើងដោយសាក្សីរូបនោះ គាត់បាននិយាយថា ឈ្មោះ ក្លូត ឆន ហ្នឹងជាមេឃុំភ្នំសំពៅ។ តើលោកស្គាល់ឈ្មោះ ក្លូត ឆន នេះទេ? ហើយលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះគាត់ទេ?

**ឆ៖** គេធ្វើមេឃុំ ហើយស្មៀនក៏គេយកទៅវ៉ៃចោលនៅនឹងគាត់។ ក្លូត ឆន ក៏គេវ៉ៃ សម្លាប់អស់ពួកហ្នឹង។

**ស៖** ចុះមេភូមិភ្នំសំពៅលិច ឈ្មោះ មី វឿត នេះ លោកស្គាល់គាត់ទេ? ហើយលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះគាត់ទេ?

**ឆ៖** អ្ហែ! អត់ដឹងទេ។

[១៥:៣២:៤១]

**ស៖** លោកចាំទេថា ក្លូត ឆន ហ្នឹងត្រូវបានសម្លាប់នៅពេលណាក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង?

**ឆ៖** ក្លូត ឆន សម្លាប់ដែលគេចូលមកជាន់ដីហ្នឹង គេសើរើទៅដឹងឈ្មោះមេឃុំ គេយកទៅវ៉ៃចោលទៅ។

**ស៖** ខ្ញុំនៅមានសំណួរមួយចំនួនទៀត ប្រសិនបើសហមេធាវីនាំមុខមិនយល់ទាស់អីទេ។ លោកលោកជាអតីតទាហានលន់ នល់ តើលោកខ្លាចទេ? លោកខ្លាចថាគេចាប់ខ្លួនលោកទេនៅសម័យនោះ?

**ឆ៖** ខ្លាចដែរ ប៉ុន្តែខ្ញុំបានធ្វើការណាស់។ គេឲ្យធ្វើមេកងធ្វើការស្ទូងដកអីណ៎ា គេមិនវ៉ៃចោលទេ គេអនុគ្រោះ។ ខ្ញុំក៏ទាហានដែរ។

**ស៖** កាលពីព្រឹកមិញនេះ លោកនិយាយអំពី តាដោក ដែលត្រូវបានគេសម្លាប់ចោល។ តើគាត់ខុសអី តាដោក នេះ? ហើយគាត់ជាទាហានលន់ នល់ ឬក៏ជាមន្ត្រីនៃរបបលន់ នល់ទេ? លោកដឹងទេហេតុអីបានជាគេសម្លាប់គាត់?

**ឆ៖** ព្រោះគេសម្លាប់នោះ គេថាគាត់មានអាវុធបង្កប់។

**សៈ** ដោយសារតែគាត់មានអាវុធអ៊ីចឹង តើគាត់ជាអតីតទាហានលន់ នល់ មែនទេ?

**ឆៈ** ប្រហែលហើយគាត់ ធ្វើទាហានលន់ នល់ ដែរហ្នឹង គាត់លាក់អាវុធ។

**សៈ** ហើយអ្នកណាជាអ្នកសម្លាប់គាត់? លោកបានឃើញគេសម្លាប់គាត់ផ្ទាល់ភ្នែកទេ?

[១៥:៣៥:៤៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ព្រុំ សារុន៖**

**ឆៈ** គេទៅប្រជុំមួយឃុំភ្នំសំពៅ ទៅប្រជុំនៅសាលាសម្តេចឪ "ប្រជុំកម្ទេចមនុស្ស" គេថាអ៊ីចឹង។ ពាក្យ "កម្ទេច" អាហ្នឹង "សម្លាប់" ថា "កម្ទេចមនុស្ស"។ ថា តាដោក ហ្នឹងមានកាំភ្លើងប្រុងតដៃនឹងគេ គេចោទថាមានកាំភ្លើង។ បានគេវាយចោល តាដោក ហ្នឹង ខ្ញុំឃើញ ខ្ញុំទៅប្រជុំដែរ។ តាដោកជាមួយកូនគាត់ម្នាក់ វាយទាំងពីរហ្នឹងឯង ចុងផ្គាន ច្បាស់។

**សួរដោយលោក វាំងសង់ វ៉ាយឌ៍ ដេស្នាងលៈ**

**សៈ** តើលោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំណាមួយដែលដឹកនាំដោយ មូល សម្បត្តិ ហៅ រស់ ញឹម ដែលជាមេភូមិភាគពាយ័ព្យទេ?

**ឆៈ** ទៅប្រជុំនឹងសាលាវត្តភ្នំសំពៅ គេធ្វើសាលាធំ មូល សម្បត្តិ ហ្នឹងមកប្រជុំម្តង។ មិនបានឃើញមុខគេផង ខ្ញុំនៅឆ្ងាយពីគេ អង្គុយក្រោយគេ។ មូល សម្បត្តិ ហ្នឹងមកប្រជុំម្តង ខ្ញុំមកប្រជុំដែរ។

**សៈ** ពេលប្រជុំនោះ គាត់មាននិយាយអំពីបញ្ហាសន្តិសុខ អំពីវត្តមានខ្មាំង ឬគេមានប្រាប់ថាត្រូវឲ្យប្រុងប្រយ័ត្នបដិវត្តន៍ដែរឬទេ?

**ឆៈ** គេប្រជុំឲ្យតែបង្កបង្កើនផលទេ និយាយនោះ មិនមែនប្រជុំឲ្យប្រឆាំងជាមួយគេទេ ប្រជុំឲ្យប្រឹងបង្កបង្កើនផល។ ពាក្យគេនិយាយហ្នឹង។

[១៥:៣៨:]

**លោក វាំងសង់ វ៉ាយឌ៍ ដេស្នាងលៈ**

សូមអរគុណលោកសាក្សី។ លោកប្រធាន សហព្រះរាជអាជ្ញាអស់សំណួរហើយ សូមប្រគល់វេទិកានេះជូនសហមេធាវីនាំមុខ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រី ចៅក្រម និងភាគីទាំងអស់។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំបាទ ឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួន សម្រាប់សួរទៅលោកដើម្បីបំភ្លឺបន្ថែម។ ជាបឋមពាក់ព័ន្ធទៅនឹងការប្រើប្រាស់ពាក្យ "វរៈ កងធំ កងតូច ឬក៏ កង" ជាដើមហ្នឹង ថាតើលោកអាចបញ្ជាក់បានទេ ថាតើហេតុអ្វីបានជាគេប្រើប្រាស់ពាក្យនេះចំពោះក្រុមលោកដែលជាអ្នកប្រជាជន? តើលោកអាចដឹងហេតុផលទេ ហេតុអ្វីបានប្រើប្រាស់ពាក្យទាំងអស់នេះ?

[១៥:៣៩:៤០]

**លោក ព្រុំ សារុន៖**

**ឆ៖** មិនដឹងដែរ តែគេហៅៗតាមគេទៅ។ កងធំ កងតូចអី ហៅតាមគេទៅ ទៅកើត មកពីកើតមកពីណាមក គេនិយមហៅកងធំ កងតូច ប្រធានវរៈ ប្រធានអីអីចឹងៗ។ ខ្ញុំហៅតាមគេទៅអីចឹង។

**ស៖** តើពាក្យពេចន៍នេះ គេប្រើសំដៅទៅលើអ្នកដែលធ្វើការនៅជីកទំនប់ទឹកហ្នឹង ឬក៏ប្រើជាទូទៅតែម្តង នៅមូលដ្ឋានរបស់លោក ឬក៏មូលដ្ឋានជិតៗហ្នឹង គេប្រើពាក្យហ្នឹងដូចគ្នា ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយ!

**លោក ព្រុំ សារុន៖**

**ឆ៖** ប្រើពាក្យដូចគ្នា កងធំ កងតូច ប្រធានវរៈ ប្រធានអីចឹងឯង វរៈ១ វរៈ២អី ប្រើអីចឹងឯង។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ អរគុណ។ ខ្ញុំចូលទៅដល់សំណួរផ្សេងទៀត តើលោកអាចបញ្ជាក់បានទេ តាមការពិត លោកមានប្រសាសន៍ថា លោកនៅភូមិក្រពើជើង អីចឹងមែនទេ លោក?

**ឆ៖** បាទ។

**ស៖** តើលោកស្គាល់ភូមិក្រពើត្បូងទេ?

**ឆ៖** ស្គាល់ភូមិក្រពើត្បូង នៅខាងត្បូងភ្នំ។

[១៥:៤១:២៣]

**ស៖** តើលោកមានដឹងពីប្រជាជនដែលរស់នៅទីនោះ តើមានប្រជាជនជាតិសាសន៍វៀតណាម គាត់រស់នៅភូមិក្រពើខាងត្បូងហ្នឹងដែរទេ ពេលដែលលោកនៅក្រពើខាងជើងហ្នឹង?

**ឆ៖** មិនដែលឆ្លងគ្នាទេ។ ក្រពើជើងនៅក្រពើជើង វរៈផ្សេងគ្នា។

**ស៖** បាទ សូមអរគុណ។ ចំពោះកន្លែងដែលលោកបានមានប្រសាសន៍អំពីទួលតាត្រង់ ជិតភ្នំកុយ ដែលជាកន្លែងសម្លាប់មនុស្សដែលលោកទៅដល់ឃើញមានខ្មោច មានសាកសពហ្នឹង។ តើលោកអាចដឹងដែរទេ លោកអាច -- លោកដឹងទេ ថាតើនៅជិតនោះមានអូរមួយ ដែលគេហៅថា "អូរតូច" មានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ!

**លោក ព្រុំ សារុន៖**

**ឆ៖** នៅខាងកើតអូរតូចហ្នឹងហើយ ទួលតាត្រង់នោះ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** អ៊ីចឹងទួលតាត្រង់ហ្នឹង គឺនៅកន្លែងអូរតូចតែម្តង អ៊ីចឹងណេះ បើសិនថាខ្ញុំយល់ច្បាស់?

**ឆ៖** ទួលតាត្រង់នៅខាងកើតអូរតូច អូរតូចពីលិច មានអូរតូច។

**ស៖** អ៊ីចឹង បើសិនបើថាលោកស្គាល់អូរតូចហ្នឹង លោកមានដឹងថា នៅកន្លែងអូរតូចនោះ មានកន្លែងដែលគេសម្លាប់មនុស្សនៅកន្លែងនោះទេ?

**ឆ៖** មានជម្លៀសពីប៉ៃលិនមក នៅនឹងអូរតូចហ្នឹងឯង ប៉ុនខ្ញុំមិនដឹងគេសម្លាប់ មិនសម្លាប់ទេ ប៉ុន្តែឃើញតែដើរសុំអង្ករសុំអី វរៈខ្ញុំ។ មកពីប៉ៃលិនមក អត់បាយអត់អីហ្នឹង។ ពីស្ទឹង គេបញ្ជូនទៅហ្នឹងឯង។

[១៥:៤៤:០៥]

**ស៖** បាទ អ៊ីចឹង ខ្ញុំសូមអានឃ្លាមួយនៃកិច្ចសម្ភាសន៍របស់សាក្សីដែលមានឯកសារលេខ E3/7737 កិច្ចសម្ភាសន៍របស់សាក្សីជាព្រះសង្ឃដែលមានព្រះនាម អ៊ឹម អាន់។ នៅក្នុងឯកសាររបស់

សម្គាសនោះ គឺជាភាសាខ្មែរលេខ 00197883, ជាភាសាអង់គ្លេស 00274160, ជាភាសាបារាំង 00226156។ ខ្ញុំសូមស្រង់ ដកស្រង់ដូចតទៅ គាត់ថា៖ "មានជនជាតិវៀតណាមចំនួន៣០គ្រួសារ រួមទាំងកូនក្មេងផង ស្ថិតក្នុងក្រពើត្បូង ឃុំភ្នំសំពៅ ត្រូវបានយោធាខ្មែរក្រហមសម្លាប់ចោលនៅក្នុងឆ្នាំ ១៩៧៦ នៅកន្លែងអូរតូចខាងត្បូងភ្នំកុយ ចម្ងាយ៧គីឡូម៉ែត្រពីភូមិក្រពើត្បូង ដែលអ្នកភូមិបាននិយាយពីរឿងនេះ។" អ៊ីចឹងសំណួររបស់ខ្ញុំ ចង់សុំសួរលោកថាតើលោកមានធ្លាប់ទទួលព័ត៌មានពីការយកមនុស្សទៅសម្លាប់ ដែលជាជនជាតិវៀតណាមទៅសម្លាប់នៅកន្លែងអូរតូច នៅកន្លែងជិត -- នៅកន្លែងអូរតូចហ្នឹងដែរទេ? លោកធ្លាប់ឮទេ?

**ប្រធានអង្គជំនុំ៖**

កុំទាន់! កុំអាលទាន់!

**លោក ព្រុំ សារុន៖**

**ឆ៖** មានអ្នករត់ពីប៉ៃលិនមកនៅ បើទួលតាត្រង់កន្លែងគេវៃចោល។ អូរតូចមិនមានទេ បើងាប់នឹងឈឺ អត់បាយអី មាន។

[១៥:៤៦:០៧]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោក ចំពោះអ្នកដែលលោកមានប្រសាសន៍ថារត់មកពីប៉ៃលិនហ្នឹង តើពួកគាត់មានបានទៅរស់នៅភូមិក្រពើត្បូងដែរឬទេ?

**ឆ៖** អត់រស់នៅភូមិក្រពើត្បូងទេ អានេះនៅប្រជាជនយើងនៅនេះ។ បើថារត់ពីនោះមក នៅអូរតូច អត់បាយក្រហាយទឹកស្លាប់អីទៅ ឈឺទៅ ពិបាកណាស់។

**ស៖** បាទ លោករស់នៅស្រុកបាណន់ លោកអាចបញ្ជាក់បានទេ នៅឆ្នាំ១៩៧៦ ឬក៏ក្រោយពីឆ្នាំនោះ ឆ្នាំ១៩៧៧ ឬក៏៧៨ ថាតើមានខ្មែរកម្ពុជាក្រោមនៅមានរស់រាននៅស្រុកបាណន់ហ្នឹង ឬក៏ថានៅភូមិឃុំនៅជិតលោកហ្នឹង មានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយលោកសាក្សី!

**លោក ព្រុំ សារុន៖**

**ឆ៖** អត់មានរត់ទៅនៅជាមួយពួកខ្ញុំទេ ស្រុកបាណន់ នៅឆ្ងាយគ្នា។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** តើមានកម្ម -- ពេលឆ្នាំ៧៥ មានខ្មែរកម្ពុជាក្រោមរស់នៅជិតៗលោកដែរឬទេ ឬក៏ភូមិឃុំជិតៗគ្នាមានទេ?

**ឆ៖** អត់មានទេ ខ្មែរកម្ពុជាក្រោមអត់មានទៅមក។

**ស៖** បាទ អ៊ីចឹងខ្ញុំសូមលោកប្រធានអនុញ្ញាត ដើម្បីខ្ញុំអានឃ្លាខ្លីមួយរបស់ -- នៅក្នុងឯក -- ចេញពីឯកសារលេខ E3/5185 ជាឯកសាររបស់សាក្សីឈ្មោះ អ៊ឹម ជឿន។ នៅក្នុងឯកសារជាភាសាខ្មែរ ERN 00197889, ជាភាសាអង់គ្លេស 00274166, ជាភាសាបារាំង 00226163 ដែលនៅក្នុងឃ្លានោះបាននិយាយថា៖ "ខ្ញុំបានឃើញគេសម្លាប់ខ្មែរក្រោមមួយខ្សែ មាន២០នាក់នៅអូរតូច ក្បែរភ្នំកុយ ដែលមានមនុស្សប្រុសស្រី និងកុមារផងដែរ។ ខ្ញុំបានឃើញកងរបស់ ឆេង ប្រាំឬប្រាំមួយនាក់បានយកអ្នកទាំងនោះទៅសម្លាប់។" អ៊ីចឹងខ្ញុំចង់សួរលោក ថាតើលោកមានស្គាល់ មានធ្លាប់ឮរឿងហ្នឹងដែរឬទេ ពីបញ្ហាសម្លាប់ខ្មែរកម្ពុជាក្រោមនៅអូរតូចក្បែរភ្នំកុយហ្នឹង លោកមានធ្លាប់ឮទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៥:៤៩:៥០]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំជំទាស់នឹងសំណួរនេះ។ ជាបឋមគឺថាមិនមានមូលដ្ឋាននៃការដឹងរបស់សាក្សីនេះទេ ទាក់ទងទៅនឹងហេតុការណ៍ដែលទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិក្រោមដែលជាការអះអាង ឬក៏ការសម្លាប់នោះ ដោយអង្គជំនុំជម្រះសម្រេចថា ក្រៅពីវិសាលភាព ហើយនិងនិយាយអំពីប្រល័យពូជសាសន៍ជនជាតិវៀតណាម ខ្មែរក្រោម ការប្រព្រឹត្តលើជនជាតិខ្មែរក្រោមគឺជាត្រូវបានដកចេញពីវិសាលភាព។ ដោយផ្អែកលើមូលដ្ឋាននេះ ខ្ញុំសូមជំទាស់ សំណួរដែលមេធាវី សហមេធាវីនាំមុខបានសួរ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់លើចំណុចនេះ។ ពីព្រោះថាយើងមិនយល់ដូចគ្នាចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដូច នួន ជា ទេ។ ខ្ញុំសូមយោងទៅសេចក្តីសម្រេចជាផ្ទាល់មាត់នៅថ្ងៃទី២៥

ឧសភា ឆ្នាំ២០១៥។ ច្បាស់ណាស់ថា អង្គជំនុំជម្រះបានដកចេញពីវិសាលភាពនូវក្រុមខ្មែរក្រោមដែលជាក្រុមដាច់ដោយឡែកមួយ ក៏ប៉ុន្តែវាអាចឲ្យយើងសម្រេចថា ខ្មែរក្រោមហ្នឹង ក៏ដូចជាក្រុមនៃជនជាតិវៀតណាមដែរ។ នេះជាការយល់នូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ លេខ E1/304.1។

[១៥:៥១:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៥២:២៨]

**ប្រធានអង្គជំនុំ៖**

បាទ ហើយសេចក្តីជំទាស់ និងមូលហេតុនៃសេចក្តីជំទាស់របស់សហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ចំពោះការសំណួរ ហើយនិងការដាក់បង្ហាញនេះគឺមានមូលដ្ឋានត្រឹមត្រូវ។ ហើយការដែលលើកឡើងពាក់ព័ន្ធជាមួយនឹងខ្មែរកម្ពុជាក្រោមនោះ គឺក្រៅវិសាលភាពនៃអង្គហេតុដែលអង្គជំនុំជម្រះកំណត់ឲ្យធ្វើសវនាការ មិនអាចយកមកសួរដេញដោលបានទេ។

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ!

**សួរដោយលោក ពេជ អង្គ៖**

បាទ ខ្ញុំសូមសួរបន្តទៀត ប៉ុន្តែខ្ញុំមិននៅសល់សំណួរច្រើនប៉ុន្មានទេ។

**ស៖** លោកសាក្សី លោកបាននិយាយថា វៀតណាមចំនួនបីបួនគ្រួសារដែលនៅក្នុងវរៈទី២ ដែលលោកនិយាយថា លោកសម្គាល់គាត់ដោយគាត់និយាយប៉ៃឡាំ។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមទៀតថា តើលោកធ្វើយ៉ាងដូចម្តេចបានដឹងថា បានឮពួកគាត់និយាយប៉ៃឡាំ ឬមួយលោកបានជួបពួកគាត់ផ្ទាល់ និងនិយាយជាមួយពួកគាត់ផ្ទាល់ បានដឹងគាត់និយាយប៉ៃឡាំ ឬក៏យ៉ាងណា?

**លោក ព្រុំ សារុន៖**

**ឆ៖** ទេ ដូចមិនបានសួររឿងប៉ៃឡាំ ប៉ៃអីផង មិនបានថាផង។

[១៥:៥៤:១១]

**ស៖** ខ្ញុំសុំលើកសំណួរឡើងវិញ ប្រហែលជាសំណួរខ្ញុំវែងពេក។ លោកបានមានប្រសាសន៍ថា គ្រួសារវៀតណាមបីទៅបួនគ្រួសារនៅក្នុងវរៈទី២ ត្រូវបានគេយកទៅសម្លាប់នៅទួលតាកុយ។ តើខ្ញុំនិយាយអ៊ីចឹងត្រូវដែរឬទេ?

**ឆ៖** មានដែលថាសម្លាប់នៅទួលតាកុយផង។ ខ្ញុំមិនដែលឮផង។

**ប្រធានអង្គជំនុំ៖**

មេធាវីក្ដាប់អង្គហេតុសួរដេញដោលហ្នឹងមិនបានទេ ហើយតាំងសំណួរសាក្សីៗឆ្លើយច្បាស់លាស់ហើយ ហើយលោកដកស្រង់មកមិនត្រូវផង។ មិនបាច់ជួយទេ មិនអនុញ្ញាតទេ!

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ខ្ញុំសូមសួរលោកឡើងវិញ។ តើលោកមានបានមានប្រសាសន៍ថា មានជនជាតិវៀត-ណាមបីប្អូនគ្រួសារត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចេញពីវរៈទី២ មែនទេ?

**លោក ព្រុំ សារុន៖**

**ឆ៖** ខ្ញុំថាបីប្អូននាក់តើ! យកទៅសម្លាប់នៅទួលតាត្រង់។

**ប្រធានអង្គជំនុំ៖**

អរគុណ។ អញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៥៦:១១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាជាប្រភេទសំណួរ ដូចសំណួរមុនដដែលទេ។ ហើយបញ្ហាគឺថាសាក្សីគាត់បានបញ្ជាក់ខាងដើមថាគាត់បានឃើញគេចងបណ្ដើរ មិនមែនបានឃើញការសម្លាប់ទេ។ ដូច្នេះព័ត៌មាននេះវាខុសគ្នា។ បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ពេជ អង្គ៖**

បាទ អរគុណ។

**ស៖** បាទអម្បាញ់មិញលោកសាក្សីថា បានសម្លាប់នៅទួលតាត្រង់។ ខ្ញុំចង់សូមសួរបញ្ជាក់ត្រង់កន្លែងហ្នឹងថា ដែលលោកសាក្សីនិយាយថាគាត់វៀតណាម ជាវៀតណាមហ្នឹង លោកសាក្សីអាចបញ្ជាក់បន្ថែមទេ ថាកន្លែងណាដែលលោកសម្គាល់ថាគាត់ជាវៀតណាម លោកអាចបញ្ជាក់ថែមបានទេ?

**លោក ព្រុំ សារុន៖**

**ឆ៖** អាចស្គាល់បានអីថា គេនិយាយប៉ែឡាំៗ គេចាប់យកទៅ។

**លោក ពេជ អង្គ៖**

តើ -- បាទ ខ្ញុំមិនសួរបន្តទៀតទេ។ បាទ សូមអរគុណលោកប្រធាន សូមអរគុណសាក្សី។

**ប្រធានអង្គជំនុំ៖**

សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៩ ខែធ្នូ ឆ្នាំ២០១៥ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ព្រុំ សារុន បញ្ចប់ ហើយនិងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-949 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក ព្រុំ សារុន ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក ព្រុំ សារុន ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងសូមឲ្យអញ្ជើញគាត់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៨ នាទី)*